សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

Université Royale de Droit et des Sciences Economiques

*Royal University of Law and Economics*


**សារណាបញ្ចប់ការសិក្សា**

# សេរីភាពបញ្ចេញមតិ

ស្រាវជ្រាវពីថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៦ ដល់ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៦


តាក់តែងឡើងដោយ

និស្សិតឈ្មោះ **ទឹម ចាន់សូរិយ៉ា**

សាស្ត្រាចារ្យណែនាំ

ឯកឧត្តម **ឆឹង ស៊ីនៀង**



ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី ១៦

ឆ្នាំចូលសិក្សា ២០១២

ឆ្នាំសរសេរសារណា ២០១៦

# អារម្ភកថា

ចាប់តាំងពីបានសិក្សាលើផ្នែកទ្រឹស្តី ដែលបានប្រើរយៈជាច្រើនឆ្នាំកន្លងមក ដើម្បីទុកជាបទពិសោធន៍ ក៏ដូចជាការវាស់ស្ទង់នូវចំណេះដឹង និងជាភស្តុតាងបញ្ជាក់លទ្ធផលបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ ខ្ញុំបាទបានសម្រេចចិត្តសរសេរសារណាទាក់ទងនឹងប្រធានបទ ដែលស្ថិតនៅក្នុងចង្កោមនៃនីតិសាធារណៈផ្នែកសិទ្ធិមនុស្ស គឺ "**សេរីភាពបញ្ចេញមតិនៅក្នុងប្រទេសកម្ពុជា**" ។ ចំពោះការតាក់តែងនូវប្រធានបទមួយនេះ គឺធ្វើឡើងដោយមើលឃើញពីតម្រូវការចាំបាច់របស់ប្រជាពលរដ្ឋ និងសង្គមជាតិទាំងមូលនូវសិទ្ធិសេរីភាពនេះ។

ស្នាដៃចងក្រងនេះ មានគោលបំណង ដើម្បីចូលរួមចំណែកក្នុងការអភិវឌ្ឍពង្រឹងការការពារ លើកស្ទួយវិស័យសិទ្ធិមនុស្ស និងលទ្ធិប្រជាធិបតេយ្យឲ្យកាន់តែប្រសើរឡើងនៅកម្ពុជា ដោយពុំមានគោលបំណងរិះគន់ ទិតៀនក្រុមណាមួយ ឬបក្សណាមួយឡើយ។ ដោយឈរលើគោលការណ៍ឯករាជ្យ ស្នាដៃនេះ បានបង្ហាញខ្លឹមសារ និងបញ្ហាសំខាន់ៗមួយចំនួន ដែលទាក់ទងនឹងសេរីភាពក្នុងការបញ្ចេញមតិនេះ។

ខ្លឹមសារ និងបញ្ហាទាំងនេះរួមមាន ការស្វែងយល់អំពីសេរីភាពបញ្ចេញមតិ ការអនុវត្ត និងការទទួលខុសត្រូវ ចំពោះសេរីភាពនេះ ព្រមទាំងផលវិបាកមួយចំនួន ដែលបាន និងកំពុងតែកើតឡើងនៅក្នុងប្រទេសកម្ពុជា។

ចំណោទទាំងនេះ គឺជាកូនសោរសម្រាប់ទំលាយនូវភាពសង្ស័យទាំងឡាយ ដើម្បីឱ្យប្រជាពលរដ្ឋ អង្គការ សង្គមស៊ីវិល ឬស្ថាប័ននានា បានយល់ច្បាស់ពីបញ្ហានេះ ដើម្បីឈានដល់ទៅរកការអនុវត្តនូវសេរីភាព ក្នុងការបញ្ចេញមតិប្រកបដោយភាពត្រឹមត្រូវតាមគន្លងនៃលទ្ធិប្រជាធិបតេយ្យ។

ខ្ញុំបាទសង្ឃឹមថា ស្នាដៃនេះ នឹងបានជាគុណប្រយោជន៍សម្រាប់មិត្តអ្នកអាន និងអ្នកសិក្សាស្រាវជ្រាវគ្រប់មជ្ឈដ្ឋានទាំងឡាយទុកជាគំនិតយោបល់ ជាឯកសារជំនួយស្មារតី និងជាឯកសារពិគ្រោះយោបល់ សម្រាប់ធ្វើការពិចារណា និងសិក្សាស្វែងយល់បន្ថែមទៀត ទាក់ទងនឹងសេរីភាពក្នុងការបញ្ចេញមតិនេះ។

ជាទីបញ្ចប់ ខ្ញុំបាទជឿជាក់ថា សារណានេះ ពិតជានៅមានចំណុចខ្វះខាតត្រង់ចំណុចមួយចំនួនទាំងផ្នែកអក្ខរាវិរុទ្ធ ខ្លឹមសារ ក៏ដូចជាការរៀបរៀងចងក្រងសារណានេះឡើង។ ខ្ញុំបាទ រង់ចាំទទួលនូវមតិរិះគន់ស្ថាបនាពីមិត្តអ្នកអាន អ្នកសិក្សាស្រាវជ្រាវ និស្សិត លោក លោកស្រី សាស្ត្រាចារ្យ និងបណ្ដាប្រជាពលរដ្ឋគ្រប់យ៉ាងដោយក្ដីសោមនស្សរីករាយ។

# សេចក្តីថ្លែងអំណរគុណ

ខ្ញុំបាទឈ្មោះ ទឹម ចាន់សូរិយ៉ា ជានិស្សិតឆ្នាំទី៤ ជំនាន់ទី១៦ ផ្នែកនីតិសាស្ត្រ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានសរសេរសារណាបញ្ចប់ការសិក្សាក្រោមប្រធានបទ "**សេរីភាពបញ្ចេញមតិនៅក្នុងប្រទេសកម្ពុជា**"។ នៅក្នុងការសរសេរសារណាមួយនេះ គឺអាចកើតចេញឡើងប្រកបដោយភាពរលូនទៅបានដោយសារការខិតខំប្រឹងប្រែងជាកម្លាំងកាយ កម្លាំងចិត្ត និងចំណេះដឹង ជាពិសេសដោយ ការប្តេជ្ញាចិត្តចំណាយពេលវេលាដ៏មានតម្លៃ និងអនុសាសន៍ ក៏ដូចជាការរិះគន់មួយចំនួនពីសំណាក់អ្នកដែលមានគុណទាំងឡាយដូចជា៖

កូនសូមសម្តែងនូវសេចក្តីអំណរគុណនូវគុណូបការៈដ៏ថ្លៃថ្លា និងមិនអាចកាត់ថ្លៃបានរបស់ **លោកឪពុក ទឹម ម៉ៃ** និង **អ្នកម្តាយ វ៉ែន គន** ដែលបានចិញ្ចឹមបីបាច់ថែរក្សារូបកូនរហូតដល់ធំដឹងក្តី និងខិតខំតស៊ូពុះពារឆ្លងកាត់រាល់ឧបសគ្គ ដើម្បីឲ្យកូនរស់នៅប្រកបដោយភាពសុខសាន្ត និងបានសិក្សាយកចំណេះដឹងជាច្រើនរហូតដល់សព្វថ្ងៃនេះ ព្រមទាំងផ្តល់នូវសេចក្តីស្រលាញ់ មេត្តា ករុណាជាពិសេស គឺការផ្តល់នូវកំលាំងចិត្ត ការអប់រំ ទូន្មាន ប្រៀនប្រដៅ ផ្គត់ផ្គង់សព្វគ្រប់បែបយ៉ាងទាំងផ្នែកសម្ភារៈ ថវិការ និង ស្មារតី ។

**ឯកឧត្តម លុយ ចណ្ណា** ជាសាកលវិទ្យាធិការនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានប្តេជ្ញាចិត្តទាំងកម្លាំងកាយចិត្ត ទាំងស្មារតី ទាំងសមត្ថភាព និងលទ្ធភាព ក្នុងការគ្រប់គ្រងស្ថាប័នមួយនេះឲ្យដំណើរការទៅយ៉ាងជោគជ័យកន្លងមករហូតដល់បច្ចុប្បន្ននេះ។ លើសពីនេះទៅទៀត លោកក៏បានលើកស្ទួយនូវប្រព័ន្ធរដ្ឋបាលឱ្យស្ថាប័ននេះដំណើរការទៅប្រកបដោយនិរន្តភាព និងប្រសិទ្ធភាពខ្ពស់ទៀតផង។

**ឯឧត្តមសាស្ត្រាចារ្យ ឆឹង ស៊ីនៀង** ជាសាស្ត្រាចារ្យណែនាំក្នុងការសរសេរសារណានេះ ដែលលោកបានបង្ហាត់បង្ហាញ ក៏ដូចជាផ្តល់ដំបូន្មានក្នុងការជ្រើសរើសនូវប្រធានបទមួយ ដែលសមស្របទៅនឹងសមត្ថភាព និងសេចក្តីត្រូវការរបស់សង្គមបច្ចុប្បន្ន។ ទន្ទឹមនឹងនេះ លោកសាស្ត្រាចារ្យ បានលះបង់នូវពេលវេលាដ៏មានតម្លៃរបស់ខ្លួនក្នុងការណែនាំ និងកែតម្រូវទៅលើការសរសេរ អក្ខរាវិរុទ្ធ និងខ្លឹមសារនៃសារណាទាំងមូល។

ជាចុងក្រោយគឺ **បណ្តាសាស្ត្រាចារ្យខ្មែរ** និង **បរទេស** ដែលបានខិតខំអស់ពីកំលាំងកាយកំលាំងចិត្ត និងកំលាំងប្រាជ្ញា ក្នុងការផ្ទេរនូវចំនេះដឹងដ៏វិសេសវិសាលមានតម្លៃមហិមាដល់ខ្ញុំបាទក្នុងរយៈ ពេល៤ឆ្នាំកន្លងមក។

# មាតិកា

**សេចក្ដីផ្ដើម**
**ជំពូកទី១៖ សញ្ញាណទូទៅនៃសេរីភាពបញ្ចេញមតិ**.................................................... ៣
ផ្នែកទី១៖ និយមន័យទូទៅ និងទស្សនៈទានអ្នកប្រាជ្ញ............................................ ៣
១. ពន្យល់ពាក្យ.............................................................................................. ៣
១.១. សេរីភាព.............................................................................................. ៤
១.២. សេរីភាពបញ្ចេញមតិ.............................................................................. ៤
២. ការស្វែងយល់ទស្សនៈទានអ្នកប្រាជ្ញ............................................................. ៤
២.១. Jean-Jacques Rousseav......................................................................... ៤
២.២. John Locke........................................................................................ ៥
២.៣. Thomas Hobbes.................................................................................. ៦
ផ្នែកទី២៖ ប្រភពដើម និងការវិវត្តន៍នៃសិទ្ធិមនុស្ស.................................................... ៧
១. ការវិវត្តន៍នៃសិទ្ធិមនុស្ស................................................................................ ៧
២. កំណើតនៃអង្គការសហប្រជាជាតិ...................................................................... ៨
៣. ឯកសារសិទ្ធិមនុស្សសតវត្សទី២០.................................................................... ៩
៤. កតិកាសញ្ញាសិទ្ធិមនុស្ស................................................................................ ១១
៥. សេចក្ដីប្រកាសជាសកលស្ដីពីសិទ្ធិមនុស្ស........................................................... ១១
៦. ឯកសារសិទ្ធិមនុស្សជាបន្តបន្ទាប់..................................................................... ១២
៧. តួនាទីរបស់អង្គការមិនមែនរដ្ឋាភិបាល.............................................................. ១៣
ផ្នែកទី៣៖ បទបញ្ញត្តិទូទៅស្ដីពីសេរីភាពបញ្ចេញមតិ.................................................. ១៣
១. បទដ្ឋានគតិយុត្តអន្តរជាតិ................................................................................ ១៣
១.១. សេចក្ដីប្រកាសជាសកលស្ដីពីសិទ្ធិមនុស្ស....................................................... ១៣
១.២. កតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ................ ១៤
១.៣. កតិកាសញ្ញាអន្តរជាតិស្ដីពីសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌................. ១៦
២. បទដ្ឋានគតិយុត្តជាតិ...................................................................................... ១៨
២.១. រដ្ឋធម្មនុញ្ញ......................................................................................... ១៨
២.២. ច្បាប់ស្ដីរបបសារពត៌មាន....................................................................... ១៩
២.៣. ច្បាប់ស្ដីពីការធ្វើបាតុកម្មដោយសន្តិវិធី......................................................... ២០

**ជំពូកទី២៖ ការប្រព្រឹត្តទៅនៃការអនុវត្តសេរីភាពបញ្ចេញមតិនៅកម្ពុជា**............... ២២
ផ្នែកទី១៖ មូលដ្ឋានគ្រឹះនៃសេរីភាពបញ្ចេញមតិ.................................................... ២២
១. សិទ្ធិទទួលបានពត៌មាន.................................................................................២២
២. សិទ្ធិស្វែងរកពត៌មាន.................................................................................... ២៣
៣. សិទ្ធិផ្សព្វផ្សាយពត៌មាន...............................................................................២៤
ផ្នែកទី២៖ មធ្យោបាយក្នុងការអនុវត្តសេរីភាពបញ្ចេញមតិ......................................២៤
១. មធ្យោបាយតាមបែបប្រពៃណី.................................................................... ២៤
១.១. ប្រវត្តិ..........................................................................................................២៤
១.២. ស្ថានីយទូរទស្សន៍........................................................................................ ២៦
១.៣. ស្ថានីយវិទ្យុ.................................................................................................. ២៧
១.៤. កាសែត និងបញ្ជីកាសែត..................................................................................២៨
១.៥. ការជួបប្រជុំជាសាធារណៈ................................................................................ ៣០
២. មធ្យោបាយតាមបែបទំនើប.............................................................................. ៣០
២.១. ប្រើប្រាស់បណ្ដាញសារពត៌មានទំនើបជាឧបករណ៍ការពារ
និងលើក កម្ពស់សិទ្ធិមនុស្ស.............................................................................៣២
២.១.១. ទូរស័ព្ទដៃ....................................................................................... ៣២
២.១.២. អ៊ីនធឺណេត.......................................................................................៣២
២.១.៣. គេហទិនានុលេខន៍ ឬប្លុក(Block) ..................................... ៣២
២.១.៤. ហ្វេសបុក(facebook) ............................................................ ៣៤
២.១.៥. ធ្វីតទ័រ(Twitter) .............................................................................. ៣៤
២.២. លទ្ធភាពប្រើប្រាស់ទូរស័ព្ទដៃ និងប្រព័ន្ធអ៊ីនធឺណេតនៅកម្ពុជា............ ៣៥
ផ្នែកទី៣៖ មូលដ្ឋានគ្រឹះនៃការនិយាយជាសាធារណៈ........................................... ៣៧
១. និយមន័យក្នុងការនិយាយ..............................................................................៣៧
២. គោលបំណងក្នុងការនិយាយ..........................................................................៣៧
៣. ប្រភេទនៃការនិយាយ......................................................................................៣៨
៤. ធាតុសំខាន់ៗក្នុងការនិយាយ..........................................................................៣៨
៥. ចរិយាក្នុងការនិយាយ......................................................................................៣៩
៦. លក្ខណៈសម្បត្តិល្អរបស់អ្នកនិយាយ.............................................................៣៩
៧. សិល្បៈនៃការនិយាយ......................................................................................៤០
៨. វិធីនៃការនិយាយ............................................................................................ ៤១

៩. ដំណាក់កាលក្នុងការនិយាយ........................................................................៤២
ផ្នែកទី៤៖ បញ្ហាប្រឈមលើមធ្យោបាយនៃសេរីភាពបញ្ចេញមតិនៅកម្ពុជា.............. ៤៣
១. ការរឹតបន្តឹងលើសេរីភាពបញ្ចេញមតិតាមបែបទំនើប.....................................៤៤
១.១. ការកាត់ទោសចំពោះការប្រើប្រាស់វិទ្យុ និងកាសែត............................ ៤៥
១.២. ការដាក់កម្រិតដល់ការជួបប្រជុំជាសាធារណៈដោយសន្តិវិធី................៤៨
១.៣. អំពើហិង្សាប្រឆាំងមកលើអ្នកសារពត៌មាន......................................... ៤៩
១.៤. ប្រព័ន្ធផ្សព្វផ្សាយត្រូវបានគ្រប់គ្រងដោយរដ្ឋាភិបាល...........................៥០
២. ការរឹតបន្តឹងលើសេរីភាពបញ្ចេញមតិតាមបែបទំនើប.....................................៥១
២.១. សេចក្តីព្រាងច្បាប់ឧក្រិដ្ឋកម្មតាមប្រព័ន្ធអ៊ីនធឺណេត............................ ៥១
២.២. ការគ្រប់គ្រងប្រព័ន្ធអ៊ីនធឺណេតដោយរដ្ឋាភិបាល................................ ៥៣
៣. ការរឹតបន្តឹងក្នុងច្បាប់ជាតិ............................................................................៥៥
៤. ការរឹតបន្តឹងលើស្ថាប័នផ្សេងៗ.................................................................... ៥៨
៤.១. ការរឹតបន្តឹងលើសង្គមស៊ីវិល.................................................................. ៥៩
៤.១.១. ការរំខានដល់សកម្មភាពរបស់អង្គការសង្គមស៊ីវិល................................៥៩
៤.១.២. ការសម្លុតបំភ័យដល់តួអង្គសង្គមស៊ីវិល................................................ ៦០
៤.១.៣. ការប្រើអំពើហិង្សាមកលើតួអង្គសង្គមស៊ីវិល.........................................៦១
**សេចក្តីសន្និដ្ឋាន**
**អនុសាសន៍**
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

សេរីភាពក្នុងការបញ្ចេញមតិ គឺជាមូលដ្ឋានគ្រឹះនៃលទ្ធិប្រជាធិបតេយ្យ ដែលបានចូលរួមចំណែកយ៉ាងសកម្មក្នុងការធ្វើអោយមានដំណើរការល្អផ្នែកការពារ និងការគោរពសិទ្ធិមនុស្សតាមរយៈការប្រើប្រាស់នូវមធ្យោបាយបញ្ចេញសំខាន់ៗ។ មុខងារនៃសេរីភាពនេះរួមមានការបង្កើតនូវទំនាក់ទំនងការចូលរួមពីប្រជាពលរដ្ឋការទទួលខុសត្រូវខ្ពស់ និងការសំរេចចិត្តធ្វើអោយមានតម្លាភាព នៅក្នុងសង្គមនឹងនាំតម្រុងឆ្ពោះទៅរកសង្គមប្រជាធិបតេយ្យមួយ។ ដូចគ្នានឹងសិទ្ធិសេរីភាពដទៃទៀតដែរ សេរីភាពក្នុងការបញ្ចេញមតិមិនអាចប្រើប្រាស់ដោយប្រាសចាកពីព្រំដែនកំណត់របស់ច្បាប់បានឡើយ។ ការកំរិតផ្នែកទៅលើទស្សនៈពិសេសមួយចំនួន ដែលគេឃើញកំណត់ក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រ កម្ពុជាជាចំពោះសេរីភាពនេះ គឺដើម្បីការពារសិទ្ធិ និងសេចក្តីថ្លៃថ្នូរបស់អ្នកដទៃការពារប្រពៃណីល្អរបស់សង្គមច្បាប់ និងសណ្តាប់ធ្នាប់សាធារណៈ និងការពារសន្តិសុខជាតិ។ ទោះជាយ៉ាងណាការកំរិតផ្សេងៗទៅលើសសេរីភាពនេះ ត្រូវតែមានធម្មនុញ្ញភាពរបស់ខ្លួនព្រមទាំងមានភាពសមាមាត្រ ដែលគេត្រូវតែថ្លឹងថ្លែងមើលពីភាពសមស្រប និងភាពស្របច្បាប់នៃការដាក់កំរិតទាំងនេះ។

ការអនុវត្តសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិបច្ចុប្បន្នហាក់ដូចជា មានចំណុចវិជ្ជមានផង និងអវិជ្ជមានផង។ ថ្វីបើមានច្បាប់ជាតិ និងអន្តរជាតិជាច្រើនការពារសេរីភាពនេះយ៉ាងទូលំទូលាយក៏ដោយក៏ករណីរំលោភសិទ្ធិមនុស្ស នៅតែកើតមានជាហូរហែរក្នុងសង្គមស្របគ្នា និងយន្តការការពារសិទ្ធិមនុស្សរបស់រដ្ឋាភិបាលរដ្ឋសភាព្រឹទ្ធសភា មិនមានប្រសិទ្ធភាពគ្រប់គ្រាន់ និងខ្វះឆន្ទៈក្នុងការធ្វើសកម្មភាពក្នុងវិស័យនេះ។ ប្រព័ន្ធតុលាការ ដែលជាក្តីសង្ឃឹមរបស់ប្រជាពលរដ្ឋ ត្រូវគេមើលឃើញថាមានឱនភាព និងគ្មានអព្យាក្រឹត្យ។ ការខិតខំប្រឹងប្រែងរបស់រដ្ឋាភិបាល ដើម្បីធ្វើកំណែទំរង់ផ្សេងៗ រួមទាំងកំណែទំរង់ប្រព័ន្ធយុត្តិធម៌ផងនោះ បានកំពុងនាំកម្ពុជាឆ្ពោះទៅរកលទ្ធិប្រជាធិបតេយ្យ ប៉ុន្តែបែរជាមានដំណើរធាក់ថយក្រោយវិញ ក្នុងពេលដែលមានភាពចំរូងចំរាសថ្មីចុងក្រោយស្តីពីការដកអភ័យឯកសិទ្ធិភាពពីតំណាងរាស្ត្របីរូបរបស់គណបក្សប្រឆាំង។

ការអនុវត្តសេរីភាពក្នុងការបញ្ចេញមតិ ត្រូវបានប្រឈមមុខនឹងការទទួលខុសត្រូវផ្សេងៗ ដោយសារមធ្យោបាយនានានៃការប្រើប្រាស់សេរីភាពនេះដែរ គេមើលឃើញថា រំលោភទៅលើកេរ្តិ៍ឈ្មោះ និងសេចក្តីថ្លៃថ្នូរបស់អ្នកដទៃ ឬពាក់ព័ន្ធទៅនឹងការមិនគោរពសីលធម៌វិជ្ជាជីវៈរបស់អ្នកសារពត៌មានខ្លួនឯង។ ការទទួលខុសត្រូវសំខាន់ៗ មានការទទួលខុសត្រូវព្រហ្មទណ្ឌរដ្ឋប្បវេណីរដ្ឋបាល។ ស្របពេលគ្នា នឹងមានការទទួលខុសត្រូវនេះ គេពិនិត្យឃើញមានផលវិបាកមួយចំនួនដែលកើតចេញពីការអនុវត្តសេរីភាពក្នុងការបញ្ចេញមតិ។ ផលវិបាកទាំងនេះ អាចជាការភ័យខ្លាច

ចំពោះសន្តិសុខផ្ទាល់ខ្លួនការគំរាមកំហែងការសំលាប់ ការចាប់ឃុំខ្លួនការអនុវត្តច្បាប់ធូររលុង និងការខ្វះខាតច្បាប់ ដើម្បីអនុវត្តពិសេសច្បាប់ស្តីពីសេរីភាពទទួលពត៌មាន ដែលតំរូវការចាំបាច់របស់ប្រជាពលរដ្ឋ។ កត្តាអន់ថយមួយចំនួន ដែលជាឧបសគ្គសំរាប់សេរីភាពក្នុងការបញ្ចេញមតិនេះដែរ គឺភាពក្រីក្រកំរិតយល់ដឹងទាបរបស់ប្រជាពលរដ្ឋអំពើពុករលួយប្រព័ន្ធផ្សព្វផ្សាយ មានភាពលំអៀង។

ដោយមានទស្សនៈវិស័យដោយសុទិដ្ឋិនិយម យើងមានក្តីសង្ឃឹម និងជឿជាក់ថាកម្ពុជានឹងធ្វើដំណើរឆ្ពោះទៅរកលទ្ធិប្រជាធិបតេយ្យពិតប្រាកដ បើប្រជាពលរដ្ឋ អង្គការសង្គមស៊ីវិល និងរដ្ឋាភិបាលរួមគ្នាអនុវត្តច្បាប់អោយមានប្រសិទ្ធិភាព។ ពិសេសជាងនេះទៅទៀតតម្លាភាព និងនីតិរដ្ឋនឹងកើតមានយ៉ាងប្រត្យក្សក្នុងសង្គមកម្ពុជានាពេលអនាគតដ៏ខ្លីជាមិនខាន។

នៅក្នុងប្រធានបទ "សេរីភាពបញ្ចេញមតិ" នេះ ត្រូវបានបែងចែងជា២ជំពូក ដែលជំពូកនីមួយៗ មានការបែងចែកផ្នែកផ្សេងៗ និងចំណុចមួយចំនួនទៀត។

ជំពូកទី១ "សញ្ញាណទូទៅនៃសេរីភាពបញ្ចេញមតិ" បកស្រាយអំពី និយមន័យទូទៅនៃពាក្យថា សេរីភាព និងសេរីភាពបញ្ចេញមតិ។ បន្ទាប់មក បានលើកឡើងនូវទស្សនទានរបស់អ្នកប្រាជ្ញផ្សេងៗ និងប្រវត្តិនៃសិទ្ធិមនុស្សតាំងពីសតវត្សទី២០មក ដើម្បីធ្វើការសិក្សាឱ្យស៊ីជម្រៅបន្ថែមទៀត។ ទន្ទឹមនឹងនេះ ក៏បានលើកឡើងនូវបទបញ្ញត្តិទូទៅស្តីពីសេរីភាពបញ្ចេញមតិដូចជា បទដ្ឋានជាតិ និងអន្តរជាតិផងដែរ។

**ជំពូកទី២** " ការប្រព្រឹត្តទៅនៃការអនុវត្តសេរីភាពបញ្ចេញមតិនៅកម្ពុជា" រៀបរាប់អំពីមូលដ្ឋានគ្រឹះនៃសេរីភាពបញ្ចេញមតិ ដែលរួមមានសិទ្ធិទទួលបានពត៌មាន សិទ្ធិស្វែងរកពត៌មាន និងសិទ្ធិផ្សព្វផ្សាយពត៌មាន។ ម៉្យាងវិញទៀត ជំពុកនេះក៏បានរៀបរាប់ពីមធ្យោបាយក្នុងការអនុវត្តសេរីភាពបញ្ចេញមតិតាមបែបប្រពៃណី និងតាមបែបទំនើបផងដែរ។ លើសពីនេះទៅទៀត ជំពូកនេះ បានបង្ហាញពីមូលដ្ឋានគ្រឹះក្នុងការនិយាយជាសារធារណៈរបស់អ្នកបញ្ចេញមតិថែមទៀត។ រីឯចុងបញ្ចប់នៃជំពូកនេះ មានការបរិយាយអំពីបញ្ហាប្រឈមលើមធ្យោបាយនៃសេរីភាពបញ្ចេញមតិនៅកម្ពុជា ដែលជាចំណុចសំខាន់សម្រាប់ការគេចផុតពីបញ្ហាទាំងនោះ។

# ជំពូកទី១៖ សញ្ញាណទូទៅនៃសេរីភាពបញ្ចេញមតិ

## ផ្នែកទី១៖ និយមន័យទូទៅ និងទស្សនទានអ្នកប្រាជ្ញ

### ១. ពន្យល់ពាក្យគន្លឹះ

### ១.១. សេរីភាព

តើអ្វីទៅជាសេរីភាព? ហើយហេតុអ្វីបានជាវាសំខាន់? តើហេតុអ្វីបានជាយើង ត្រូវខ្វល់អំពីវា? ចំពោះការសន្និដ្ឋានដំបូង ដែលខ្ញុំបានផ្តល់ជូននៅទីនេះ គឺថាសិទ្ធិសេរីភាពបញ្ចេញមតិ គឺជាអ្វីដែលជារបស់ដ៏មានតម្លៃអំពីយើងជាមនុស្ស។ វាគឺជាគំនិតច្បាប់ធម្មជាតិថា ដើម្បីនិយាយឱ្យបានថាវាគឺជាការចាំបាច់ខាងសីលធម៌ ដែលមានមូលដ្ឋានលើអ្វី ដែលជាមូលដ្ឋានអំពីធម្មជាតិរបស់មនុស្សយើង។

**សេរីភាព** គឺជាការចង្អុលបង្ហាញអំពីចរិតលក្ខណៈនៃភាពសុខសាន្ត ដោយគ្មានអំពើហិង្សា ហើយមានសេរីភាពពេញលេញដោយខ្លាចនូវអំពើហិង្សា។ តាមធម្មតា តាមការយល់ឃើញនូវពេលនេះ ដូចជាមិនមានជម្លោះកើតមានឡើងសេរីភាពផងដែរ បានណែនាំយើងអំពីរបៀបរស់នៅអោយមានភាពស្និតស្នាលជាមួយគ្នានឹងគ្នា ឬរវាងបុគ្គល ដែលយើងមិងធ្លាប់ស្គាល់ពីមុនមក ឬមានទំនាក់ទំនងល្អជាមួយបុគ្គលផ្សេងទៀតភាពរុងរឿងនៃសង្គម ឬសេដ្ឋកិច្ចមានការរីកចម្រើននោះ គឺគ្មានអ្វីគួរអោយខ្វល់ខ្វាយនោះទេ ការបង្កើតអោយមានភាពស្មើគ្នានៅក្នុងប្រទេស ហើយការគ្រប់គ្រងនយោបាយ មានការរៀបចំបានល្អប្រសើរសំរាប់ប្រជាជនលើសកលលោកបានយ៉ាងពិតប្រាកដ។ ក្នុងការទំនាក់ទំនងជាមួយអន្តរជាតិពេលសន្តិភាព គឺមិនមែនមានត្រឹមតែភាពគ្មានសង្គ្រាម និងភាពគ្មានអំពើហិង្សាកើតមាននោះទេ។ ប៉ុន្តែថែមទាំងហ៊ានប្រឈមមុខរាល់ចំណុចវិជ្ជមានជាច្រើនទៀត ហើយត្រូវចេះគោរពចំពោះជាតិរបស់ខ្លួន ព្រមទាំងមានទំនាក់ទំនងសេដ្ឋកិច្ចល្អជាមួយប្រទេសជិតខាង[1]។

**សេរីភាព** ជាសញ្ញាណទស្សនវិជ្ជាមួយ ពោលគឺជាអំណាច ដែលតាមរយៈនោះនៅក្នុងវិស័យផ្សេងៗនៃជីវិតរបស់បុគ្គលគ្រប់រូប គេម្នាក់ៗមានសិទ្ធិជ្រើសរើសការប្រព្រឹត្តដោយ ខ្លួនឯងផ្ទាល់។ ការទទួលស្គាល់ ជាគតិយុត្តនៃសេរីភាពមួយបណ្តាលឱ្យមានផលវិបាក ច្រើនដូចជា: បង្ខំឱ្យបុគ្គលត្រូវតែគោរពដល់សិទ្ធិ និងសេរីភាពអ្នកដទៃ។ មាត្រា៤នៃសេចក្តីប្រកាសសិទ្ធិមនុស្ស និងសិទ្ធិពលរដ្ឋចែងថា "**សេរីភាព** គឺជាអំណាចដែលអាចធ្វើអ្វីៗ បានដោយមិនប៉ះពាល់អ្នកដទៃ" ។ រីឯមាត្រា៣១វាក្យខណ្ឌទី២នៃរដ្ឋធម្មនុញ្ញខ្មែរឆ្នាំ១៩៩៣ ចែងថា "ការប្រើប្រាស់សិទ្ធិសេរីភាពផ្ទាល់ខ្លួនរបស់បុគ្គលម្នាក់ៗ មិនត្រូវឱ្យប៉ះពាល់ដល់សិទ្ធិសេរីភាពអ្នកដទៃឡើយ" ។

---

[1] វេបសាយវីគីភីឌា https://km.wikipedia.org/wiki/សេរីភាព (ចតចម្លងថ្ងៃទី ០១ ខែឧសភា ឆ្នាំ២០១៦)

ដូចនេះ **សេរីភាព** គឺជាអំណាចក្នុងការសម្រេចចិត្តខ្លួនឯង ដែលមនុស្សគ្រប់រូបអាចប្រើប្រាស់ដោយខ្លួនឯងផ្ទាល់សមស្របតាមច្បាប់ និងស្ថិតក្រោមការគ្រប់គ្រងរបស់សង្គម។ សេរីភាព ត្រូវតែស្ថិតនៅជាប់ជាមួយនឹងជីវិតរបស់បុគ្គលម្នាក់ៗពីកំណើត។ ផ្ទុយទៅវិញ ការអនុវត្តសេរីភាព គឺជាសកម្មភាពសង្គមមួយមានន័យថាសង្គម ជាអ្នកកំណត់វិធាន ដែលទាក់ទងនឹងការអនុវត្តសេរីភាពរបស់សាមីជន។

### ១.២. សេរីភាពបញ្ចេញមតិ

សេរីភាពបញ្ចេញមតិ គឺជាសិទ្ធិនយោបាយ ដើម្បីធ្វើការទំនាក់ទំនងគំនិតរបស់មនុស្សម្នាក់ និងគំនិតរបស់អ្នកដទៃដោយប្រើរាងកាយមួយ និងទ្រព្យសម្បត្តិទៅនរណាម្នាក់ ដែលមានឆន្ទៈដើម្បីទទួលពួកគេ។ សេរីភាពបញ្ចេញមតិ រួមបញ្ចូលទាំងទង្វើនៃការស្វែងរកការទទួល និងការចែករំលែកពត៌មាន ឬគំនិតមិនគិតពីមធ្យមបានប្រើណាមួយទេ[2]។

មាត្រា១៩នៃសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស ក៏បានបញ្ញត្តិថា "មនុស្ស គ្រប់រូបមានសិទ្ធិសេរីភាព មានមតិ និងការបង្ហាញនូវមតិទាំងនោះ សិទ្ធិនេះរួមបញ្ចូលទាំង សេរីភាពក្នុងការកាន់មតិដោយគ្មានការជ្រៀតជ្រែក និងដើម្បីស្វែងរកការទទួល និងការទទួលបាននូវពត៌មាន និងគំនិតតាមរយៈប្រព័ន្ធផ្សព្វផ្សាយណាមួយ និងដោយមិនគិតពីព្រំដែន។

## ២. ការស្វែងយល់ទស្សនទានអ្នកប្រាជ្ញ

### ២.១. លោក ហ្សង់ហ្សាក់រ៉ូសូ (Jean-Jacques Rousseau)

ទស្សនវិជ្ជារបស់គាត់ មានឥទ្ធិពលទៅលើបដិវត្តន៍នៅប្រទេសបារាំង និងមានឥទ្ធិពលទៅលើកំណើត គំនិតនយោបាយសម័យទំនើប។ ស្នាដៃដ៏សំខាន់បំផុតរបស់គាត់គឺកិច្ចសន្យាសង្គម ដែលគូសបញ្ជាក់អំពីមូលដ្ឋានសំរាប់រៀបចំនយោបាយធម្មានរូប។ **Rousseau** បានអះអាងថា រដ្ឋតាមបែបធម្មជាតិ គឺជាលក្ខខណ្ឌដំបូងដែលគ្មានច្បាប់ ឬសីលធម៌ដែលមនុស្សបានចាកចេញ ដើម្បីគុណប្រយោជន៍ និងភាពចាំបាច់នៃការសហការគ្នា។ នៅពេលសង្គមរីកចម្រើន ការបែងចែកការងារ និងទ្រព្យសម្បត្តិឯកជន តម្រូវអោយមនុស្សរៀបចំស្ថាប័ននានាដែលមានច្បាប់។ នៅក្នុងដំណាក់កាលនៃសង្គមអន់ថយ មនុស្សតែងតែមានការប្រកួតប្រជែងគ្នា និងកាន់តែត្រូវការពឹងពាក់គ្នាឡើង។ សម្ពាធទាំងពីរនេះបានគម្រាមកំហែងដល់ជីវិតនិងសេរីភាពរបស់ពួកគេ។ ឆន្ទៈសេរីភាព និងសមភាព គឺជាសិទ្ធិធម្មជាតិរបស់មនុស្ស ដែលគេមិនអាចដកហូតយកបានឡើយ ហើយក៏មិនអាចអោយ ឬផ្ទេរពីមនុស្សម្នាក់ទៅមុស្សម្នាក់ទៀតបានឡើយ។ សេរីភាពជាសិទ្ធិរបស់មនុស្សគ្រប់រូបលុបបំបាត់សេរីភាពរបស់អ្នកណាម្នាក់ គឺលុបបំបាត់សិទ្ធិនិងភារកិច្ចរបស់មនុស្សជាតិ។ តាមលោក **Rousseau** ការចូលរួមទៅក្នុងសង្គមស៊ីវិលតាមរយៈកិច្ចសន្យាសង្គមនិងតាមរយៈការលះបង់ចោលនូវសិទ្ធិពីធម្មជាតិរបស់ខ្លួន ធ្វើអោយមនុស្សអាចរក្សា

[2] សៀវភៅលោកគ្រូ ឆឹង ស៊ីនៀង

ខ្លួនឯងផង និងនៅមានសេរីភាពផង។ **Rousseau** យល់ថាសភាពធម្មជាតិមិនមែនជាសភាព ដែលល្អតលាស់ មិនមានកម្មសិទ្ធិឯកជនទេ គេម្នាក់ៗអាចបេះផ្លែឈើ ដែលមិនមែនជារបស់អ្នក ណាម្នាក់ឡើយ បើគ្មានកម្មសិទ្ធិឯកជនទេ ក៏គ្មានចោរដែរ។ នៅក្នុងសភាពធម្មជាតិ គេម្នាក់ៗជា មួយ និងគ្រួសារអាចធ្វើដំណើរ ទៅទីកន្លែងណា ដែលគេចង់ទៅ មិនមានព្រំដែនអ្វីឡើយ។ ដូចនេះ បើគ្មានព្រំដែននោះក៏គ្មានរដ្ឋដែរ ហើយក៏គ្មានរដ្ឋក៏គ្មានសង្គ្រាមដែរ។

**Rousseau** ពន្យល់ថាការទទួលយកអំណាចឆន្ទៈរបស់មនុស្សជានាកុំអោយបុគ្គលនីមួយៗ ត្រូវលោយទៅនឹងឆន្ទៈរបស់បុគ្គលមួយក្រុមតូច ហើយក៏ធានាផងដែរថាពួកគេគោរពខ្លួនឯងផង ដែរ ពីព្រោះពួកគេតំណាងអោយសមូហភាពជាអ្នករៀបចំច្បាប់។ មនុស្សចាកចោលសភាពដាច់ ឆ្ងាយពីគ្នា ដើម្បីចុះកិច្ចសន្យាមួយ គឺកិច្ចសន្យាសង្គម។ កម្មវត្ថុនៃកិច្ចសន្យាសង្គមនេះ គឺការបង្កើត អោយមានសង្គម។ ពិតមែនហើយ ដែលថាមនុស្សអាចរស់នៅដោយគ្មានសង្គម មនុស្សអាចរស់ នៅដោយស្វែងរកដោយខ្លួនឯង ប៉ុន្តែមនុស្សយល់ឃើញថា វាមានប្រយោជន៍ច្រើន បើគេរស់នៅ ជាមួយគ្នាធ្វើការជាមួយគ្នា។ ទោះបីជា **Rousseau** អះអាងថាអធិបតេយ្យគួរតែស្ថិតនៅ ក្នុងដៃប្រជាជន ប៉ុន្តែគាត់ក៏បានបង្ហាញនូវភាពខុសគ្នារវាងអំណាចអធិបតេយ្យ និងរដ្ឋាភិបាល។ រដ្ឋាភិបាលរួមមាន តុលាការដែលមានភារកិច្ចអនុវត្ត និងពង្រឹងការអនុវត្តឆន្ទៈរួមរបស់មនុស្ស។ អំណាចអធិបតេយ្យ ជានីតិរដ្ឋដែលសំរេចដោយប្រជាធិបតេយ្យដោយផ្ទាល់នៅក្នុងសភា។ ប៉ុន្តែនៅ ក្រោមរបបរាជានិយមអំណាចអធិបតេយ្យពិត ប្រាកដក៏នៅតែជាច្បាប់ដដែល។ **Rousseau** បានប្រឆាំងទៅនឹងគំនិតដែរថា ប្រជាជនគួរប្រើប្រាស់អំណាចអធិបតេយ្យតាមរយៈសភាតំណាង រាស្ត្រ[3]។

### ២.២. លោក ចន ឡុក ( John Locke)

លោក **John Locke** ជាទស្សនវិទូ និងជាអ្នកទ្រឹស្តីនយោបាយជនជាតិអង់គ្លេស។ ទស្សនទាននយោបាយសង្គមរបស់លោក **Locke** ដែលធ្វើអោយមានកិត្យានុភាពល្បីល្បាញ ជាអ្នក នយោបាយវិទ្យា ដែលបកស្រាយស្ថានភាពធម្មជាតិរបស់មនុស្សជាស្ថានភាព ដែលមនុស្ស មានសេរីភាពគ្រប់គ្រាន់ក្នុងទំនាក់ទំនងរវាងបុគ្គល និងបុគ្គល។ ស្ថានភាពធម្មជាតិ ជាស្ថានភាព ដែលពោរពេញដោយសមភាពទាំងអំណាច ទាំងសិទ្ធិ សុទ្ធតែស្មើៗគ្នាសម្រាប់បុគ្គលទាំងអស់ ដោយមិនមានបុគ្គលណាម្នាក់មានសិទ្ធិអំណាចច្រើនជាងបុគ្គលដទៃ ហើយសិទ្ធិសេរីភាព មិនអាច កាត់ផ្តាច់ពីបុគ្គលឡើយ ក្នុងស្ថានភាពធម្មជាតិ។ សភាពធម្មជាតិ ជាកន្លែងដំបូងដែលបានផ្តល់ សិទ្ធិអោយមនុស្សជាសភាពសន្តិភាព និងជាសភាពដែលមនុស្សមានសុឆន្ទៈចង់ជួយគ្នាទៅវិញ ទៅមក ជាសភាពដែលមនុស្សមានវិចារណញ្ញាណ អាចយល់ដឹងពីច្បាប់ធម្មជាតិ និងចេះសំរប

[3] នួន សុធិមន្ត, វិទ្យាសាស្ត្រនយោបាយ: គំនិតនយោបាយរបស់អ្នកប្រាជ្ញល្បីៗ (២០១០), ៦០

សំរួលអាកប្បកិរិយារបស់ខ្លួនទៅនឹងច្បាប់ធម្មជាតិ។ តែសភាពធម្មជាតិ ក៏ជាសភាពខ្វះខាតមិនមានការកំណត់ច្បាប់ និងប្រកាសអោយប្រើប្រាស់ច្បាប់សំរាប់ទាំងអស់គ្នាឡើយ។ ក្នុងសភាពធម្មជាតិខ្វះខាតនូវអំណាចតុលាការ សំរាប់ទប់ស្កាត់មិនអោយមានការសងសឹកគ្នា ការជជែកគ្នាយកឈ្នះចាញ់តាមលក្ខណៈបុគ្គលដែលស្តែងឡើងក្នុងរូបភាពជាកូនក្តីផង ជាមេធាវីផង ជាចៅក្រមផងដែរ[4]។

ទ្រឹស្តីយោបាយរបស់ **Locke** ត្រូវបានបង្កើតឡើងលើទ្រឹស្តីកិច្ចសន្យាសង្គម។ គាត់ជឿជាក់ថាធម្មជាតិមនុស្ស គឺកំណត់សម្គាល់ដោយហេតុផល និងការអត់ឱន និងបានអនុញ្ញាតអោយមនុស្សមានភាពអត្មានិយម។ នៅក្នុងរដ្ឋតាមបែបធម្មជាតិ មនុស្សទាំងអស់មានសេរីភាពស្មើគ្នា និងឯករាជ្យហើយមនុស្សគ្រប់រូបមានសិទ្ធិតាមធម្មជាតិក្នុងការការពារ ជីវិត សុខភាព សេរីភាព ឬទ្រព្យសម្បត្តិរបស់ពួកគេ។ **Locke** បានសន្មត់ថាសិទ្ធិតែមួយគត់ក្នុងការការពារខ្លួននៅក្នុងរដ្ឋតាមបែបធម្មជាតិមិនគ្រប់គ្រាន់ឡើយ ហេតុនេះ ហើយមនុស្សបានបង្កើតសង្គមស៊ីវិលដើម្បីដោះស្រាយជម្លោះតាមបែបស៊ីវិលដោយមានជំនួយពីរដ្ឋាភិបាលនៅក្នុងរដ្ឋនៃសង្គមមួយ[5]។

### ២.៣. លោក តូម៉ាស ហាប់ (Thomas Hobbes)

លោក **Thomas Hobbes** ជាទស្សនវិទូនយោបាយជនជាតិអង់គ្លេស ហើយគាត់មានឈ្មោះល្បីដោយសារស្នាដៃរបស់ទស្សនវិជ្ជានយោបាយ និងស្នាដៃកិច្ចសន្យាសង្គម។ លោក **Thomas Hobbes** បានគិតដល់ជីវិតមនុស្សនឹងទៅជាយ៉ាងណា បើគ្មានរដ្ឋាភិបាល ដែលក្នុងស្ថានភាពនេះគាត់ហៅថារដ្ឋបែបធម្មជាតិ **(State of Nature)**។ នៅក្នុងរដ្ឋបែប ធម្មជាតិនេះ មនុស្សម្នាក់ៗមានសិទ្ធិទទួលបានអ្វីៗនៅក្នុងពិភពលោក។ បញ្ហានេះ ចៀសមិនរួចនាំទៅដល់ជម្លោះ និងសង្គ្រាម ដែលមនុស្សទាំងអស់ប្រយុទ្ធជាមួយគ្នា។ **Thomas Hobbes** បាននិយាយថា មនុស្ស គឺជាឆ្កែចចកសម្រាប់មនុស្សគ្នាឯងមានន័យថា នៅក្នុងសភាពធម្មជាតិ មនុស្សតែងតែច្បាំងគ្នា ប្រឆាំងគ្នាឯងផង និងប្រឆាំងអ្នកដទៃនៅក្នុងក្រុមផ្សេងៗទៀតផង។ នៅក្នុងសភាពធម្មជាតិមានតែសង្គ្រាមជាអចិន្ត្រៃយ៍ មានតែអសន្តិសុខ ដែលមនុស្សខ្សោយតែងតែជាអ្នករងគ្រោះរបស់អ្នកខ្លាំង ឬរបស់អ្នកមានល្បិចជាងខ្លួន។ មនុស្សមិនគ្រាន់តែអាក្រក់ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងមានសិទ្ធិធ្វើអ្វីៗ ដែលគេចង់ធ្វើ ឬទទួលយកនូវអ្វី ដែលគេចង់បានដរាបណាគេមានអំណាចជាចាំបាច់។ មានតែរដ្ឋប៉ុណ្ណោះ ដែលអាចការពារបុគ្គលបាន។ ដើម្បីចៀសផុតពីសង្គ្រាមនេះ មនុស្សនៅក្នុងរដ្ឋបែបធម្មជាតិ ស្រុះស្រួលគ្នាចំពោះកិច្ចសន្យាសង្គមមួយ និងបង្កើតសង្គមស៊ីវិលឡើង។ សង្គម គឺជាបណ្តុំប្រជាពលរដ្ឋ ដែលស្ថិតនៅក្រោមអំណាចអធិបតេយ្យ ដែលមនុស្ស

---

[4] នួន សុធិមន្ត, វិទ្យាសាស្ត្រនយោបាយ: គំនិតនយោបាយរបស់អ្នកប្រាជ្ញល្បីៗ (២០១០), ៥១-៥២

[5] ឈុន ណារ៉េត, ប្រវត្តិគំនិតនយោបាយ និងទ្រឹស្តីរដ្ឋ (ភ្នំពេញ៖ សុខលាភបោះពុម្ព, ២០០៨), ១១៧

ទាំងអស់នៅក្នុងសង្គមនេះ ត្រូវលះបង់សិទ្ធិធម្មជាតិរបស់គេដើម្បីបុព្វហេតុសុវត្ថិភាព។ ប៉ុន្តែ **Thomas Hobbes** បានថ្លែងថា ក្នុងករណីមានការរំលោភបំពានអំណាចធ្ងន់ធ្ងរ នឹងមានការងើបបះបោរប្រឆាំង។ ជាពិសេស ទ្រឹស្តីនៃការបែងចែកអំណាចមិនមានឡើយ គឺអ្នកដឹកនាំត្រូវត្រួតត្រាទាំងអំណាចស៊ីវិល យោធា តុលាការ និងអំណាចសាសនា[6]។

## ផ្នែកទី២៖ ប្រភពដើម និងការវិវត្តន៍នៃសិទ្ធិមនុស្ស

### ១. ការវិវត្តន៍នៃសិទ្ធិមនុស្ស

ផ្តើមចេញពីការតស៊ូ ដើម្បីសេរីភាព និងសមភាពនៅគ្រប់ទីកន្លែងទាំងអស់នៃប្រជាជននៅលើពិភពលោកនាំឱ្យប្រជាពលរដ្ឋ ទទួលបាននូវស្នាដៃនៃការតស៊ូ ដើម្បីសេរីភាព និងសមភាពដូចខាងក្រោម:

- ឆ្នាំ១៦៨៩ "Bill of Rights" សេចក្តីប្រកាសស្តីពីសិទ្ធិជាមូលដ្ឋាន (ប្រទេសអង់គ្លេស)៖ នេះជាលើកដំបូងនៅក្នុងប្រវត្តិមនុស្សជាតិ។ ការអះអាង ដែលថាច្បាប់មានប្រភពមកពីអាទិទេព ឬពីស្តេចត្រូវបានបោះចោល។ ច្បាប់នេះ បានប្រកាសថា ស្តេចក៏ជាប្រធានមួយនៃវិធានច្បាប់ដូចជាប្រជាពលរដ្ឋដទៃទៀតដែរ។ លើសពីនេះទៅទៀត វាបានចែងថាស្តេចត្រូវតែគោរពអំណាចសភា ដែលត្រូវបោះឆ្នោតជ្រើសរើសឡើងដោយសេរីដោយប្រជាជន។ សេចក្តីប្រកាសស្តីពីសិទ្ធិជាមូលដ្ឋាន "Bill of Rights" គឺជាសេចក្តីប្រកាសដំបូងបង្អស់ ដែលបានហាមឃាត់ការដាក់ទណ្ឌកម្មដ៏ព្រៃផ្សៃ និងការកាត់ទោសដោយអយុត្តិធម៌។ សេចក្តីប្រកាសនេះ "Bill of Rights" បានធានានូវគណៈវិនិច្ឆ័យតុលាការមិនលំអៀង និងចៅក្រមឯករាជ្យ។
- ឆ្នាំ១៧៧៦ សេចក្តីប្រកាសឯករាជ្យ (ប្រទេសអាមេរិក)៖ យោងតាមសេចក្តីប្រកាសនេះ តម្រូវឱ្យរដ្ឋាភិបាល ត្រូវបង្កើតឡើងដោយការព្រមព្រៀងរបស់ប្រជាជន ដើម្បីការពារសិទ្ធិ។ សេចក្តីប្រកាសនេះ បានបង្ហាញពីសិទ្ធិទាំងនោះក្នុងផ្នែកទី១ ពោលគឺតាមធម្មជាតិ មនុស្សគ្រប់រូប គឺមានសិទ្ធិសេរីភាព និងឯករាជ្យដោយស្មើភាពគ្នា ហើយមានសិទ្ធិផ្ទាល់ខ្លួនដូចជាសិទ្ធិមានសប្បាយរីករាយក្នុងជីវិត និងមានសេរីភាពដោយលទ្ធផលទទួល និងកាន់កាប់កម្មសិទ្ធិលើទ្រព្យសម្បត្តិ និងការស្វែងរក ហើយទទួលបាននូវសុភមង្គល និងសុវត្ថិភាព។ នៅដំណាក់កាលនោះ សេចក្តីប្រកាស មិនបានពង្រីកវិសាលភាពសិទ្ធិមនុស្សទៅដល់មនុស្សគ្រប់រូបនៅឡើយទេ គ្រាន់តែអនុវត្តចំពោះជនជាតិស្បែកសប៉ុណ្ណោះ។ មិនទាន់ដល់ជនជាតិស្បែកខ្មៅ ដែលត្រូវបានគេចាត់ទុកជាទាសកទេ។

[6] ឈុន ណារ៉េត, ប្រវត្តិគំនិតនយោបាយ និងទ្រឹស្តីរដ្ឋ (ភ្នំពេញ៖ សុខលាភបោះពុម្ព, ២០០៨), ១៣០-១៣២

- ឆ្នាំ១៧៨៩ សេចក្តីប្រកាសស្តីពីសិទ្ធិមនុស្ស និងសិទ្ធិពលរដ្ឋ (ប្រទេសបារាំង)៖ សេចក្តីប្រកាសនេះ មានលំនាំភាគច្រើនចេញពីសេចក្តីប្រកាសឯករាជ្យនៃសហរដ្ឋអាមេរិកឆ្នាំ១៧៧៦។ សេចក្តីប្រកាសនេះសង្កត់ធ្ងន់អំពីសិទ្ធិធម្មជាតិ និងសិទ្ធិ ដែលមិនអាចផ្ទេរបានដូចជាសេរីភាព សិទ្ធិកម្មសិទ្ធិ និងសិទ្ធិដើម្បីតស៊ូប្រឆាំងនឹងការគាបសង្កត់។ ខ្លឹមសារនៃមាត្រាទី១នៃប្រកាស បានទទួលស្គាល់ជាពិសេស សមភាពចំពោះមុខច្បាប់ និងយុត្តិធម៌។ ទន្ទឹមនឹងនេះ សេចក្តីប្រកាសក៏បានអះអាងផងដែរអំពីគោលការណ៍ការបែងចែកអំណាច។ ស្តេចល្វីសទី១៦ (Louis XVI) បានឱ្យសច្ចាប័នលើសេចក្តីប្រកាសនេះដោយស្ថិតក្រោមការគាបសង្កត់ពីសភា និងពីប្រជាជន ដែលបានដើរដង្ហែរក្បួនឆ្ពោះទៅទីក្រុង Versailles។
- ឆ្នាំ១៩៣៥-១៩៤៥៖ ក្នុងកំឡុងឆ្នាំនេះ ជាភ័ព្វសំណាងអាក្រក់ណាស់សម្រាប់មនុស្សជាតិដែលត្រូវទទួលរងនូវអំពើអមនុស្សធម៌ក្នុងកំឡុងរបបផ្តាច់ការណាស៊ី (Nazi Germany) និងជប៉ុន ដែលបានចាប់ផ្តើមសង្គ្រាមលើកទី២ ដែលបង្កឱ្យមនុស្សជាង៥០លាននាក់ត្រូវស្លាប់។ តាមរយៈបទពិសោធន៍ពិភពលោកបានឱ្យដឹងថា "ការទទួលស្គាល់នូវសេចក្តីថ្លៃថ្នូរផ្ទាល់ខ្លួន និងសិទ្ធិស្មើភាពគ្នា និងសិទ្ធិដែលមិនអាចផ្ទេរបានរបស់សមាជិកនៃគ្រួសារមនុស្សជាតិ គឺជាមូលដ្ឋាននៃសេរីភាព យុត្តិធម៌ និងសន្តិភាពនៅលើពិភពលោក (សេចក្តីថ្លែងការណ៍ជាសកលស្តីពីសិទ្ធិមនុស្ស)។
- ឆ្នាំ១៩៤៨ សេចក្តីថ្លែងការណ៍ជាសកលស្តីពីសិទ្ធិមនុស្ស (UDHR)៖ សេចក្តីថ្លែងការបានអនុម័តជាឯកច្ឆន្ទនៅថ្ងៃទី១០ ខែធ្នូឆ្នាំ១៩៤៨ ដោយអង្គការសហប្រជាជាតិ។ នៅក្រោយសង្គ្រាមលោកទី២ អ្នកប្រាជ្ញ ដែលជាអ្នកនិពន្ធនូវសេចក្តីថ្លែងការណ៍នេះ បានបញ្ចូលសារដ៏មានសារៈសំខាន់ ទៅដល់មនុស្សជាតិទាំងមូលនៅលើពិភពលោក ដែលខ្លឹមសារនោះមានន័យជាអាទិ៍ថា "សិទ្ធិមនុស្ស ត្រូវតែទទួលការគោរពជាសកល ដើម្បីជាប្រយោជន៍ដល់ការកសាងសន្តិភាពក្នុងលោក"។ បុព្វហេតុ ជាចំបង ដែលនាំឱ្យកកើតនូវសេចក្តីថ្លែងការណ៍នេះ គឺដោយសារភាពមហន្តរាយគួរឱ្យតក់ស្លុតដែលបង្កឡើងដោយសង្គ្រាមលោកលើកទី២មកលើមនុស្សជាតិ និងសង្គមមនុស្សមានទំហំធំក្រៃពេក។ ភាពខ្លោចផ្សាហួលប្រមាណ ដែលកើតចេញពីមហន្តរាយនេះ បានជំរុញទឹកចិត្តអ្នកប្រាជ្ញដែលមានទឹកចិត្តស្រលាញ់មនុស្សជាតិ និងស្រលាញ់សន្តិភាពនាពេលនោះមានការតស៊ូយ៉ាងមោះមុតស្វិតស្វាញ ក្នុងការតាក់តែងនូវឯកសារសិទ្ធិមនុស្សនេះឡើង សំដៅទុកជាវិធានទប់ស្កាត់សង្គ្រាមលោកនាពេលក្រោយទៀត។ ក្នុងន័យនេះ សេចក្តីថ្លែងការណ៍ជាសកលស្តីពីសិទ្ធិមនុស្សនេះ ត្រូវបានរៀបចំឡើងជាឧបករណ៍មួយ ដើម្បីប្រឆាំងនឹងអំពើសង្កត់សង្កិនគ្រប់រូបភាព លុបបំបាត់ចោលនូវរាល់មូលហេតុ ឬគោលចម្បងៗ ដែលបង្ក

ហេតុ ឬបញ្ហេះ ឱ្យមានជម្លោះ និងសង្គ្រាម ដើម្បីស្តារ និងរៀបចំឡើងវិញនូវពិភពលោកថ្មីមួយ ដែលមានសន្តិភាព សេរីភាព ឥស្សរជន និងគោរពនូវសេចក្តីថ្លៃថ្នូររបស់មនុស្សគ្រប់រូប។ សេចក្តីថ្លែងការណ៍នេះ ត្រូវបានទទួលយកយ៉ាងទូលំទូលាយបំផុតនៅលើពិភពលោក។ ខ្លឹមសារស្នូលរបស់សេចក្តីថ្លែងការណ៍ គឺជាតម្លៃផ្ទាល់ខ្លួននៃមនុស្សជាតិម្នាក់ៗ។

ដូចនេះ ការទទួលស្គាល់នូវសិទ្ធិមនុស្សបានចាត់ទុកថា ជាការទទួលស្គាល់មួយដែលធ្វើអោយមនុស្សគ្រប់គ្នារួមរស់នៅក្នុងសង្គម។ សិទ្ធិមនុស្ស បានចាត់ឫសគល់ក្នុងប្រពៃណីនិងឯកសារនៃវប្បធម៌បុរាណ ជាច្រើនហើយវាបានយកកាតាលីករនៃសង្គ្រាមលោកលើកទី២ ដើម្បីជំរុញសិទ្ធិមនុស្សទៅលើឆាកអន្តរជាតិ និងការចូលទៅក្នុងសតិសម្បជញ្ញៈរបស់ពិភពលោក។ ភាគច្រើននៃប្រវត្តិសាស្ត្រ ប្រជាជនទទួលបានសិទ្ធិនិង ការទទួលខុសត្រូវតាមរយៈសមាជិករបស់ខ្លួននៅក្នុងក្រុម ដូចជាគ្រួសារមួយប្រទេសជនជាតិដើមភាគតិច សាសនា វណ្ណៈសង្គមសហគមន៍ឬរដ្ឋ។ សាសនាហិណ្ឌូក្រមប៊ីឡូននៃ Hammarabi ព្រះគម្ពីគូរ៉ា (កូរ៉ា) និងលិទ្ធិរបស់ខុងជឺ គឺជាប្រភពទាំងប្រាំ ដែលបានសរសេរចាស់បំផុតដែលបង្ហាញពីរបស់កាតព្វកិច្ចរបស់មនុស្សសិទ្ធិ និងការទទួលខុសត្រូវ។ លើសពីនេះទៀត Inca និង Aztec យុត្តិធម៌និងរដ្ឋធម្មនុញ្ញ Iroquois គឺច្បាប់និងប្រភពរបស់ជនជាតិអាមេរិកាំងដើមដែលរស់នៅមុនពេលសតវត្សទី១៨នេះ។ ជាការពិតណាស់សង្គមទាំងអស់មិនថានៅក្នុងទំនៀមទំលាប់សរសេរ ឬនិយាយតគ្នាទេបានមានប្រពន្ធ័នៃបែបបទ និងយុត្តិធម៌ ក៏ដូចជាវិធីនៃការថែទាំដល់សុខភាព និងសុខមាលភាពរបស់សមាជិកខ្លួន។

## ២. ឯកសារសិទ្ធិមនុស្សមុនសតវត្សទី២០

ឯកសារដែលអះអាងសិទ្ធិរបស់បុគ្គលរួមមាន Magna Carta(១២១៥) ច្បាប់នៃសិទ្ធិរបស់អង់គ្លេស (១៦៨៩) សេចក្តីប្រកាសរបស់បារាំងស្តីពីសិទ្ធិមនុស្សនិងពលរដ្ឋ (១៧៨៩) និងរដ្ឋធម្មនុញ្ញាសហរដ្ឋអាមេរិក និងច្បាប់នៃសិទ្ធិ (១៧៩១) ត្រូវបានចាត់ទុកជាឯកសារគោលសំរាប់ឯកសារសិទ្ធិមនុស្សនាពេលបច្ចុប្បន្ន។ ប៉ុន្តែឯកសារទាំងនេះ នៅពេលដែលបានបកប្រែពីដំបូងចូលទៅក្នុងគោលនយោបាយមិនបានរាប់បញ្ចូលសិទ្ធិស្ត្រី ពណ៌សម្បុរ និងសមាជិកនៃក្រុមសង្គមសាសនាសេដ្ឋកិច្ច និងនយោបាយមួយចំនួននៅឡើយទេ។ទោះជាយ៉ាងណាក្តីការជិះជាន់ប្រជាជននៅទូទាំងពិភពលោកបានលាតត្រដាងក្នុងគោលការណ៍ឯកសារទាំងនេះ បានបង្ហាញពីការគាំទ្រដល់បដិវត្តន៍ ដែលអះអាងសិទ្ធិក្នុងការជ្រើសរើសដោយខ្លួនឯង[7]។

---

[7] Nancy Flower, A Story History of Human Rights (ប្រវត្តិសិទ្ធិមនុស្សសង្ខេប) http://www1.umn.edu/humanrts/edumat/hreduseries/hereandnow/Part-1/short-history.htm (ថតចម្លងថ្ងៃទី១១ ខែមេសា ២០១៦)

ច្បាប់សិទ្ធិមនុស្សអន្តរជាតិនាពេលបច្ចុប្បន្ន និងការបង្កើតនៃអង្គការសហប្រជាជាតិ (អ.ស.ប) បានផ្អែកលើប្រវត្តិសាស្ត្រដែលមានពីមុនមក។ កិច្ចខិតខំប្រឹងប្រែងនៅក្នុង សតវត្សទី ១៩ ក្នុងការហាមឃាត់ការជួញដូរទាសករ និងដើម្បីការពារកុំអោយមានការកើតឡើងនូវសង្គ្រាម គឺជាឧបករណ៍ដ៏ចម្បង។ នៅក្នុងឆ្នាំ ១៩១៩ ប្រទេសជាច្រើន បានបង្កើតឡើងអង្គការពលកម្មអន្តរជាតិ (ILO) ដើម្បីត្រួតពិនិត្យសន្ធិសញ្ញាការពារកម្មករទាក់ទងទៅនឹងសិទ្ធិរបស់ខ្លួនរួមទាំងសុខភាព និងសុវត្ថិភាពរបស់ពួកគេ។ ការព្រួយបារម្ភលើការការពារក្រុមជនជាតិភាគតិចមួយចំនួន ត្រូវបានលើកឡើងដោយសម្ព័ន្ធនៃប្រជាជាតិ (League of Nations) នៅក្រោយសង្គ្រាមលោកលើកទីមួយ។ ទោះជាយ៉ាងណាអង្គការនេះ បង្កើតឡើងសម្រាប់សន្តិភាព និងកិច្ចសហប្រតិបត្តិការអន្តរជាតិដោយសម្ព័ន្ធមិត្តអឺរ៉ុប មិនដែលសម្រេច បានគោលដៅរបស់ខ្លួនទេ។ សម្ព័ន្ធនេះ ទទួលបរាជ័យដោយសារតែសហរដ្ឋអាមេរិកបានបដិសេធមិនអោយចូលរួម និងដោយសារតែសម្ព័ន្ធបានបរាជ័យ ក្នុងការទប់ស្កាត់ការលុកលុយរបស់ជប៉ុនមកលើប្រទេសចិន និងម៉ាន់ជូរៀនាឆ្នាំ ១៩៣១ និងការវាយប្រហាររបស់ប្រទេសអ៊ីតាលីនៅលើប្រទេសអេត្យូពី (ឆ្នាំ១៩៣៥)។ ទីបំផុតសម្ព័ន្ធប្រជាជាតិ ត្រូវបានរំលាយជាមួយនឹងការចាប់ផ្តើមនៃសង្គ្រាមលោកលើកទីពីរក្នុងឆ្នាំ១៩៣៩[8]។

### ៣. កំណើតនៃអង្គការសហប្រជាជាតិ

គំនិតក្នុងការទាមទារសិទ្ធិមនុស្សនេះ បានកើតមានកាន់តែខ្លាំង បន្ទាប់ពីសង្គ្រាមលោកលើកទីពីរ។ ការសម្លាប់រង្គាលដោយណាស៊ីអាល្លឺម៉ង់ (Nazi Germany) បានសម្លាប់មនុស្សជាងប្រាំមួយលាននាក់ដែលរួមមានជនជាតិជីហ្វ Sintiនិងរ៉ូម៉ានី (ហ្គីបសីរសី) ភេទដូចគ្នា និងជនពិការដែលធ្វើអោយមានការភ័យរន្ធត់ខ្លាំងដល់ពិភពលោក។ ការសាកល្បង ត្រូវបានគេធ្វើឡើងនៅ Nuremberg និងទីក្រុងតូក្យូបន្ទាប់ពីសង្គ្រាមលោកលើកទីពីរ និងមន្ត្រីមកពីប្រទេសដែលចាញ់ត្រូវបានផ្តន្ទាទោសចំពោះការប្រព្រឹត្តឧក្រិដ្ឋកម្មសង្គ្រាម ប្រឆាំងនឹងសន្តិភាព និងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ។

បន្ទាប់មករដ្ឋាភិបាលជាច្រើន បានប្តេជ្ញាចិត្តបង្កើតអង្គការសហប្រជាជាតិដោយមានគោលដៅចម្បងនៃការជំរុញសន្តិភាពអន្តរជាតិ និងការការពារជម្លោះ។ មនុស្ស ចង់ធានាថាមិនជាថ្មីម្តងទៀតនឹងនរណាម្នាក់ត្រូវបានបដិសេធ ដោយអយុត្តិធម៌លើជីវិត សេរីភាព អាហារ ជម្រក និងសញ្ជាតិ។ សារៈសំខាន់នៃគោលការណ៍ សិទ្ធិមនុស្សដែលកំពុងរីកចម្រើនទាំងនេះ ត្រូវបានចាប់ខ្លួននៅក្នុងឆ្នាំ១៩៤១ របស់លោកប្រធានាធិបតី Franklin Delano Roosevelt's នៅពេលដែលគាត់បាននិយាយថាពិភពលោក ត្រូវការសេរីភាពសំខាន់ៗបួន គឺសេរីភាពនៃការបញ្ចេញមតិ សាសនាសេរីភាពពីការចង់បាន និងសេរីភាពពីការភ័យខ្លាច។ សិទ្ធិមនុស្ស ត្រូវបានការពារទូទាំង

[8] ដូចទី១ខាងលើ

ពិភពលោក ដើម្បីការការពារប្រជាពលរដ្ឋពីការរំលោភពំពានដោយរដ្ឋាភិបាលរបស់ពួកគេ។ សំលេងទាំងនេះ បានដើរតួនាទីយ៉ាងសំខាន់ក្នុងកិច្ចប្រជុំសានហ្វ្រាន់ស៊ីស្កូដែលបានព្រាង ធម្មនុញ្ញារបស់អង្គការសហប្រជាជាតិនៅឆ្នាំ១៩៤៥[9]។

## ៤. កតិកាសញ្ញាសិទ្ធិមនុស្ស

ជាមួយនឹងគោលដៅនៃការបង្កើតយន្តការសម្រាប់អនុវត្ត សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្សគណៈកម្មការអង្គការសហប្រជាជាតិស្តីពីសិទ្ធិមនុស្ស បានចាត់ចែងពង្រាងសន្ធិសញ្ញាពីរ គឺកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (ICCPR) និងពិធីសារជម្រើសរបស់ខ្លួន និងកតិកាសញ្ញាអន្តរជាតិស្តីពីសេដ្ឋកិច្ចសង្គម និងសិទ្ធិវប្បធម៌ (ICESCR) ។ រួមជាមួយនិងសេចក្តីប្រកាសជាសកល កតិកាសញ្ញាទាំងពីរ ត្រូវបានសំដៅជាទូទៅថាជាច្បាប់អន្តរជាតិនៃសិទ្ធិមនុស្ស។ ICCPR នេះផ្តោតលើបញ្ហាដូចជាសិទ្ធិរស់រានមានជីវិត សេរីភាពនៃការបញ្ចេញមតិ សាសនា និងការបោះឆ្នោត។ ICESCRនេះ ផ្តោតលើបញ្ហា ដូចជាអាហារ ការអប់រំ សុខភាព និងទីជំរក។ កតិកាសញ្ញាទាំងពីរ បានបន្ថែមនូវសិទ្ធិទាំងអស់របស់មនុស្ស និងហាមឃាត់ការរើសអើង។ នៅឆ្នាំ១៩៩៧ ប្រទេសចំនួនជាង១៣០ បានផ្តល់សច្ចាប័នកត្តិកាសញ្ញាទាំងនេះ។ សហរដ្ឋអាមេរិក ទោះជាយ៉ាងណា បានផ្តល់សច្ចាប័នតែទៅលើ ICCPR និងភ្ជាប់ជាមួយនិងខដាក់លក្ខ័ណ្ឌ ឬករណីលើកលែងជាច្រើន[10]។

## ៥. សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស

រដ្ឋជាសមាជិកនៃអង្គការសហប្រជាជាតិ បានសន្យាថានឹងលើកកម្ពស់ការគោរពសិទ្ធិទាំងអស់របស់មនុស្ស។ ដើម្បីជំរុញគោលដៅនេះអង្គការសហប្រជាជាតិ បានបង្កើតគណៈកម្មការមួយស្តីពីសិទ្ធិមនុស្ស និងការត្រួតពិនិត្យលើភារកិច្ចនៃគណៈកម្មការនេះដោយការធ្វើសេចក្តីព្រាងឯកសារមួយ ដែលមានអត្ថន័យនៃសិទ្ធិជាមូលដ្ឋាន និងសេរីភាព ដូចបានប្រកាសនៅក្នុងធម្មនុញ្ញនេះ។ នៅថ្ងៃទី ១០ ខែធ្នូ ឆ្នាំ១៩៤៨ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស ត្រូវបានអនុម័តដោយសមាជិកចំនួន៥៦ ក្នុងអង្គការសហប្រជាជាតិ។ សេចក្តីប្រកាសនេះ បានពង្រីកវិសាលភាពនៅក្នុងច្បាប់អន្តរជាតិដោយការបានបោះជំហ៊ានចូលធម្មនុញ្ញរបស់អង្គការសហប្រជាជាតិ ហេតុនេះការយកចិត្តទុកដាក់របស់រដ្ឋាភិបាលមួយទៅលើ ប្រជាពលរដ្ឋរបស់ខ្លួន គឺជាបញ្ហានៃក្តីបារម្ភរបស់អន្តរជាតិទាំងមូល និងមិនគ្រាន់តែជាបញ្ហាក្នុងស្រុកមួយនោះទេ។ ឥទ្ធិពលរបស់សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្សបានរីកសាយភាយគួរអោយកាត់សំគាល់។ គោលការណ៍របស់ខ្លួន ត្រូវបានគេដាក់បញ្ចូល ទៅក្នុងរដ្ឋធម្មនុញ្ញរបស់ប្រទេសចំនួនជាង១៨៥ប្រទេសក្នុងអង្គការ

[9] ដូចទី១ខាងលើ

[10] ដូចទី១ខាងលើ

សហប្រជាជាតិនេះ។ បើទោះបីជាការប្រកាសមួយ ដែលមិនមែនជាឯកសារស្របច្បាប់រួមគ្នា ប៉ុន្តែសេចក្តីប្រកាសជាសកល បានអនុលោមទៅតាមច្បាប់នៃប្រពៃណីអន្តរជាតិ ពីព្រោះមនុស្ស ចាត់ទុកវាជាការទទួលស្គាល់នូវសិទ្ធិរបស់មនុស្សទាំងអស់នៅក្នុងប្រទេស[11]។

### ៦. ឯកសារសិទ្ធិមនុស្សជាបន្តបន្ទាប់

បន្ថែមពីលើកតិកាសញ្ញាក្នុងច្បាប់អន្តរជាតិស្តីពីសិទ្ធិមនុស្ស អង្គការសហប្រជាជាតិបាន អនុម័តសន្ធិសញ្ញាជាង២០ផ្សេងទៀត ដើម្បីផ្តល់ពត៌មានលម្អិតបន្ថែមទៀតពីសិទ្ធិមនុស្ស។ ទាំង នេះរួមបញ្ចូលនូវ អនុសញ្ញាហាមឃាត់ ដើម្បីបង្ការ និងការរំលោភបំពានជាក់លាក់ដូចជា ការធ្វើទារុណកម្ម និងអំពើប្រល័យពូជសាសន៍ និងដើម្បីការពារប្រជាជនដែលងាយរងគ្រោះ ជាពិសេសដូចជា ជនភៀសខ្លួន (អនុសញ្ញាអន្តរជាតិស្តីពីស្ថានភាពរបស់ជនភៀសខ្លួនឆ្នាំ១៩៥១) ស្ត្រី (អនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំង និងនារីឆ្នាំ១៩៧៩) និងកុមារ (អនុសញ្ញាស្តីពីសិទ្ធិកុមារ១៩៨៩)។ នៅឆ្នាំ ១៩៩៧ សហរដ្ឋអាមេរិក បានផ្តល់សច្ចាប័នអនុសញ្ញា ទាំងនេះតែប៉ុណ្ណោះ៖

- អនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងពូជសាសន៍
- អនុសញ្ញាស្តីពីការបង្ការ និងផ្តន្ទាទោសចំពោះបទឧក្រិដ្ឋប្រល័យពូជសាសន៍
- អនុសញ្ញាស្តីពីសិទ្ធិនយាបាយស្ត្រី
- អនុសញ្ញាស្តីពីទាសភាពឆ្នាំ ១៩២៦
- អនុសញ្ញាស្តីពីការប្រឆាំង និងការធ្វើទារុណកម្ម និងអំពើឃោរឃៅផ្សេងតទៀត ដោយ អមនុស្សធម៌ ឬការព្យាបាទ ឬទណ្ឌកម្ម

នៅក្នុងទ្វីបអឺរ៉ុប ទ្វីបអាមេរិក និងទ្វីបអាហ្វ្រិក ឯកសារក្នុងតំបន់សម្រាប់ការការពារនិងការ លើកកម្ពស់សិទ្ធិមនុស្ស បានពង្រីកច្បាប់អន្តរជាតិស្តីពីសិទ្ធិមនុស្ស។ ឧទាហរណ៍រដ្ឋ នៅក្នុង ទ្វីបអាហ្វ្រិក បានបង្កើតធម្មនុញ្ញរបស់ពួកគេផ្ទាល់ ដែលទាក់ទងនឹងសិទ្ធិរបស់ប្រជាជន (ឆ្នាំ១៩៨១) និងរដ្ឋមូស្លីម បានបង្កើតសេចក្តីប្រកាសទីក្រុងគែរ ស្តីពីសិទ្ធិមនុស្សនៅសាសនាអ៊ីស្លាម (១៩៩០)។ ការផ្លាស់ប្តូរយ៉ាងខ្លាំងនៅអឺរ៉ុបភាគខាងកើតទ្វីប អាហ្វ្រិកនិងអាមេរិកឡាទីនចាប់តាំងពីឆ្នាំ ១៩៨៩ បានបង្ហាញអានុភាពកើនឡើងនៅក្នុងតម្រូវការនៃការគោរពសិទ្ធិមនុស្ស។ ម្យ៉ាងវិញទៀត ចលនាដ៏ មានប្រជាប្រិយភាពនៅក្នុងប្រទេសចិន កូរ៉េ និងប្រទេសនៅអាស៊ីដទៃទៀត បង្ហាញពីការប្តេជ្ញាចិត្ត ស្រដៀងគ្នាទៅនឹងគោលការណ៍ទាំងនេះ[12]។

[11] ដូចទី១ខាងលើ

[12] ដូចទី១ខាងលើ

### ៧. តួនាទីរបស់អង្គការមិនមែនរដ្ឋាភិបាល

នៅទូទាំងពិភពលោក អ្នកដែលជាតួអង្គសំខាន់ក្នុងការទាមទារសិទ្ធិមនុស្សនេះបាន ជាញឹកញាប់ពលរដ្ឋមិនមែនមន្ត្រីរដ្ឋាភិបាល។ ជាពិសេសអង្គការមិនមែនរដ្ឋាភិបាល (NGOs) បាន ដើរតួនាទីមួយក្នុងការផ្តោតសំខាន់ក្នុងសហគមន៍អន្តរជាតិលើបញ្ហាសិទ្ធិមនុស្ស។ ឧទាហរណ៍ សកម្មភាពអង្គការក្រៅរដ្ឋាភិបាលជុំវិញឆ្នាំ១៩៩៥ សន្និសីទពិភពលោកលើកទីបួនរបស់ អង្គការ សហប្រជាជាតិស្តីពីស្ត្រីនៅទីក្រុងប៉េកាំងប្រទេសចិន បានទាក់ទាញការយកចិត្តទុកដាក់ទៅនឹងការ រំលោភបំពានធ្ងន់ធ្ងរ មិនធ្លាប់មានពីមុនមកនៃសិទ្ធិមនុស្សរបស់ស្ត្រី។ អង្គការមិនមែនរដ្ឋាភិបាល ដូចជា អង្គការលើកលែងទោសអន្តរជាតិដែលជាអង្គការសង្គម គណៈកម្មការអន្តរជាតិ ក្រុមការ ងារអន្តរជាតិស្តីពីកិច្ចការជនជាតិដើមភាគតិចឃ្លាំមើលសិទ្ធិមនុស្ស ការតស៊ូមតិ សម្រាប់ការពារ សិទ្ធិមនុស្សអន្តរជាតិ និងជនរងគ្រោះ ត្រួតពិនិត្យសកម្មភាពរបស់រដ្ឋាភិបាល និងការដាក់សម្ពាធ អោយពួកគេ ដើម្បីធ្វើសម្រេចបាននូវការគោរពគោលការណ៍សិទ្ធិមនុស្ស។ មន្ត្រីរដ្ឋាភិបាល ដែលយល់ពីក្របខណ្ឌសិទ្ធិមនុស្ស ក៏អាចជាអ្នកទាមទារស្វែងរកការគោរពបាននូវសិទ្ធិមនុស្សដែរ រហូតឈានដល់ មានការផ្លាស់ប្តូរសេរីភាព។ ប្រធានាធិបតីសហរដ្ឋអាមេរិកជាច្រើនដូចជា Abraham Lincoln, Franklin Roosevelt, Lyndon B. Johnson, និង Jimmy Carter បានឈរយ៉ាងរឹងមាំ សម្រាប់ការគោរពសិទ្ធិមនុស្ស។ ក្នុងបណ្តាលប្រទេសផ្សេងទៀតដូចជា មេដឹកនាំ Nelson Mandela និង Vaclev Havel បាននាំមកនូវ ការផ្លាស់ប្តូរដ៏អស្ចារ្យអំពីការស្ថិតនៅក្រោមផ្ទាំងបដាសិទ្ធិមនុស្ស។

សិទ្ធិមនុស្សទទួលបានការគាំទ្រដោយសារការតស៊ូ និងព្យាយាមរបស់ពលរដ្ឋគ្រប់រូប ដោយប្រើប្រាស់រយៈពេលវែង ដើម្បីសម្រេចបាននូវការគោរពសិទ្ធិមនុស្សនេះ។ សេចក្តី ប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស គឺជាការនាំមកនូវសេរីភាព និងយុត្តិធម៌សម្រាប់ប្រជាជន នៅទូទាំងពិភពលោក។ សព្វថ្ងៃនេះ ការរំលោភបំពានសិទ្ធិមនុស្សដោយរដ្ឋាភិបាល ត្រូវបាន ទទួលការរិះគន់ និងការថ្កោលទោសចំពោះទង្វើទាំងនេះ ព្រោះមនុស្សទូទាំងពិភពលោក បាន ប្រមូលផ្តុំ និងធ្វើការប្រឈមមុខនិងភាពអយុត្តិធម៌ និងអមនុស្សធម៌[13]។

## ផ្នែកទី៣៖ បទបញ្ញាត្តិទូទៅស្តីពីសេរីភាពបញ្ចេញមតិ

### ១៖ បទដ្ឋានគតិយុត្តិអន្តរជាតិ

### ១.១ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស

សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស គឺជាសេចក្តីប្រកាសអនុម័តដោយមហាសន្និបាត អង្គការសហប្រជាជាតិនៅថ្ងៃទី១០ ខែធ្នូ ឆ្នាំ១៩៤៨ នៅទីក្រុងប៉ារីស[14]។ សេចក្តីប្រកាសនេះ បានក្រោកឡើងដោយផ្ទាល់ពីបទពិសោធន៍នៃសង្គ្រាមលោកលើកទីពីរ និងតំណាងអោយការ

[13] ដូចទី១ខាងលើ

[14] សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស (អនុម័តថ្ងៃទី១០ ខែធ្នូ ឆ្នាំ១៩៤៨)

បញ្ចេញមតិជាសកលដំបូងនៃសិទ្ធិ ដែលមនុស្សទាំងអស់មានសិទ្ធិទទួលបាន។ ច្បាប់អន្តរជាតិនៃសិទ្ធិមនុស្ស មានសេចក្ដីប្រកាសជាសកលស្ដីពីសិទ្ធិមនុស្ស កតិសញ្ញាអន្តរជាតិស្ដីពីសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ និងកតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ និងពិធីសារជម្រើសពីររបស់ខ្លួន។ ការអនុម័តនៃសេចក្ដីប្រកាសជាសកល គឺជាការរំលឹកនូវព្រឹត្តិការណ៍អន្តរជាតិ ដ៏សំខាន់សម្គាល់ជារៀងរាល់ឆ្នាំនៅថ្ងៃទី ១០ ខែធ្នូហើយ ត្រូវបានគេស្គាល់ថា ជាទិវាសិទ្ធមនុស្ស ឬទិវាសិទ្ធិមនុស្សអន្តរជាតិ។ មិនតែប៉ុណ្ណោះក្នុងមាត្រា១៩នៃសេចក្ដីប្រកាសនេះបានថ្លែងថា ជនគ្រប់រូបមានសិទ្ធិសេរីភាពក្នុងការមានមតិ និងសម្ដែងមតិ[15]។ សិទ្ធិនេះរាប់ បញ្ចូលសេរីភាពក្នុងការប្រកាន់យកមតិយោបល់ដោយគ្មានការជ្រៀតជ្រែក និងសេរីភាពក្នុងការស្វែងរកការទទួលបាន និងការផ្សព្វផ្សាយនូវពត៌មាន និងគំនិតនានាដោយគ្មានព្រំដែនទឹកដីនោះ តាមរយៈមធ្យោបាយសម្ដែងមតិណាមួយក៏ដោយ។

### ១.២ កតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ

កតិសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ត្រូវបានអនុម័តកាលពី ថ្ងៃទី១៦ ខែធ្នូ ឆ្នាំ១៩៦៦ ដោយមហាសន្និបានអង្គការសហប្រជាជាតិ ហើយចូលជាធរមានតាមច្បាប់អន្តរជាតិ កាលពីថ្ងៃទី២៣ ខែមិនា ឆ្នាំ១៩៧៦[16]។ កតិកាសញ្ញានេះ ជាសន្ធិសញ្ញាអន្តរជាតិមួយក្នុងចំណោមសន្ធិសញ្ញាអន្តរជាតិពីរ ដែលត្រូវបានបង្កើតឡើង ដើម្បីផ្ដល់អានុភាពតាមផ្លូវច្បាប់ដល់សេចក្ដីប្រកាសជាសកលស្ដីពីសិទ្ធិមនុស្សឆ្នាំ ១៩៤៨។ ការព្រាងសន្ធិសញ្ញា សិទ្ធិមនុស្សតែមួយ គឺមិនគ្រប់គ្រាន់នោះទេ ដោយសារនិន្នាការនយោបាយខុស គ្នាក្នុងសហគមន៍អន្តរជាតិនាពេលនោះ ទើបនាំអោយមានការព្រមព្រៀងគ្នាព្រាងសន្ធិសញ្ញាចំនួនពីរស្របគ្នា។ ហេតុដូចនេះ កតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធិយោបាយ បានដើរទន្ទឹមគ្នា ជាមួយនឹងកតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌។ កតិកាសញ្ញា ទាំងពីរនេះធ្វើតាមទម្រង់ដូចគ្នា និងមានបទបញ្ញាត្តិរួមដូចគ្នាជាច្រើន។ ការបែងចែងសិទ្ធិមនុស្សជាពីរកតិកាសញ្ញានេះ ព្រមទាំងការអនុម័តជាបន្តបន្ទាប់នូវសន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិ ដែលគ្រប់ដណ្ដប់លើវិស័យផ្សេងៗគ្នា អង្គការសហប្រជាជាតិតែងតែបានសង្កត់ធ្ងន់លើពាក្យ "សកលភាព ភាពទាក់ទងគ្នា និងភាពពុំនាក់អាស្រ័យគ្នា" នៃសិទ្ធិមនុស្សទាំងអស់។ និយាយរួមទៅ សិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ មិនសំខាន់ជាងសិទ្ធិ និងសិទ្ធិយោបាយដែរ ព្រោះមនុស្សទាំងអស់ មានសិទ្ធិទទួលបានសិទ្ធិមនុស្សទាំងអស់ស្មើគ្នា។ ទំនាក់ទំនងស្អិតរមួតរវាងសិទ្ធិទាំងពីរនេះ នៅពេល

[15] សេចក្ដីប្រកាសជាសកលស្ដីពីសិទ្ធិមនុស្ស (អនុម័តថ្ងៃទី១០ ខែធ្នូ ឆ្នាំ១៩៤៩), មាត្រា១៩

[16] កតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (អនុម័តថ្ងៃទី១៦ ខែធ្នូ ឆ្នាំ១៩៦៦ ចូលជាធរមានតាមច្បាប់អន្តរជាតិថ្ងៃទី២៣ ខែមិនា ឆ្នាំ១៩៧៦)

ខ្លះមានលក្ខណៈច្បាស់លាស់ណាស់ ដោយសារកតិកាសញ្ញាទាំងពីរមានបញ្ញត្តិពីសិទ្ធិស្វ័យសំរេចការមិនរើសអើង និងសមភាព ព្រមទាំងសិទ្ធិសហជីព និងការការពារគ្រួសារ។

កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ បង្កើតគោលការណ៍ទូទៅដែលណែនាំរដ្ឋ តាមរយៈបទបញ្ញត្តិក្នុងពីរផ្នែកដំបូងនៃកតិកាសញ្ញានេះសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ត្រូវបានការពារ ដែលគោលការណ៍ទាំងនោះរួមមានដូចជាៈ

- សិទ្ធិស្វ័យសម្រេចរបស់ប្រជាជនទាំងអស់ ដើម្បីធ្វើសេចក្តីសម្រេចលើឋានៈ នយោបាយរបស់ខ្លួនដោយសេរី និងដើម្បីចូលរួមក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (មាត្រា១)[17]
- គោលការណ៍នៃការមិនរើសអើង ក្នុងការអនុវត្តសិទ្ធិតាមកតិកាសញ្ញានេះ (មាត្រា២)[18]
- គោលការណ៍សមភាពរវាងបុរស និងស្ត្រីក្នុងការអាស្រ័យសិទ្ធិទាំងនេះ (មាត្រា៣)[19]

សិទ្ធិភាគច្រើននៅក្នុងអនុសញ្ញានេះ គឺជាសិទ្ធិដាច់ខាត ហើយត្រូវតែអនុវត្តភ្លាម និងទាំងស្រុងខណៈដែលសិទ្ធិទាំងនេះចូលជាធរមាន។ ជាក់ស្តែង ការទទួលយកបំរាមនៃអំពើទារុណកម្ម គឺរាល់ទារុណកម្មត្រូវតែបញ្ចប់ដោយគ្មានមូលហេតុអ្វីទាំងអស់។ ទោះជាយ៉ាងនេះក្តីកាលៈទេសៈកំណត់មួយចំនួនតូច រដ្ឋអាចព្យួរសិទ្ធិទាំងនេះអោយរួចផុតពីកាតព្វកិច្ចរបស់ខ្លួនដូចជា ក្នុងពេលមានអាសន្ន ជាទូទៅគំរាមកំហែងដល់អាយុជីវិតជាតិរដ្ឋ អាចចាត់វិធានការធានា ដែលតម្រូវចាំបាច់បំផុត ដើម្បីដើម្បីស្រាយការគំរាមកំហែងនេះ។ ប៉ុន្តែកាតព្វកិច្ចនៃការមិនរើសអើង និងសិទ្ធិសំខាន់ៗ មួយចំនួនទៀត រួមមានសិទ្ធិមានជីវិត សេរីភាពចាកផុតពីការធ្វើទារុណកម្ម និងទាសភាព សេរីភាពខាងមនសិការ និងសាសនាព្រមទាំងកិច្ចធានាការពារតាមផ្លូវច្បាប់មួយចំនួន ត្រូវបានចាត់ទុកថា មិនអាចព្យួរជាបណ្តោះអាសន្នបានទេមានន័យថា រដ្ឋមិនអាច ព្យួរសិទ្ធិទាំងនេះ ជា បណ្តោះអាសន្នបានទេទោះជាស្ថិតក្នុងកាលៈទេសៈរដ្ឋប្រកាសស្ថានភាពគ្រាអាសន្នក៏ដោយ។

ដោយឡែកព្រះរាជាណាចក្រកម្ពុជា បានក្លាយជារដ្ឋភាគីនៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយកាលពីថ្ងៃទី២៦ ខែសីហា ឆ្នាំ១៩៩២។ ជាក់ស្តែងក្នុងមាត្រា៣១នៃរដ្ឋធម្មនុញ្ញ[20] ដែលធានាការពារអនុសញ្ញានេះថា ជាផ្នែកមួយនៃច្បាប់កម្ពុជា ហើយមាត្រា

[17] កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (អនុម័តថ្ងៃទី១៦ ខែធ្នូ ឆ្នាំ១៩៦៦ ចូលជាធរមានតាមច្បាប់អន្តរជាតិថ្ងៃទី២៣ ខែមិនា ឆ្នាំ១៩៧៦) មាត្រា១

[18] កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (អនុម័តថ្ងៃទី១៦ ខែធ្នូ ឆ្នាំ១៩៦៦ ចូលជាធរមានតាមច្បាប់អន្តរជាតិថ្ងៃទី២៣ ខែមិនា ឆ្នាំ១៩៧៦) មាត្រា២

[19] កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (អនុម័តថ្ងៃទី១៦ ខែធ្នូ ឆ្នាំ១៩៦៦ ចូលជាធរមានតាមច្បាប់អន្តរជាតិថ្ងៃទី២៣ ខែមិនា ឆ្នាំ១៩៧៦) មាត្រា៣

[20] រដ្ឋធម្មនុញ្ញ លេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ១៩៩៣ មាត្រា៣១

ដទៃទៀត គូសបញ្ជាក់ឡើងវិញពីការប្តេជ្ញាចិត្តរបស់កម្ពុជា ក្នុងការធានាថា ប្រជាជនកម្ពុជាទាំងអស់ អាចអាស្រ័យនូវសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយរបស់ពួកគេ។ សេចក្តីប្រកាសនៃសិទ្ធិក្នុងជំពូកទី៣នៃរដ្ឋធម្មនុញ្ញរួមមាន ការការពារអាយុជីវិត សន្តិសុខ និងសេរីភាព (មាត្រា៣២)[21] សិទ្ធិប្រជាធិបតេយ្យ (មាត្រា៣៤ ៣៥ និង៤២)[22] សិទ្ធិបង្កើតសហជីព (មាត្រា៣៦)[23] សេរីភាពក្នុងការដើរហើរ (មាត្រា៤០)[24] សេរីភាពនៃការបញ្ចេញមតិ (មាត្រា៤១)[25] សេរីភាពខាងសាសនា (មាត្រា៤៣)។ រីឯឯករាជ្យភាពតុលាការវិញ ត្រូវបានធានាការពារនៅក្នុងជំពូកទី១១នៃរដ្ឋធម្មនុញ្ញ។

បន្ទាប់ពីកម្ពុជា បានក្លាយជារដ្ឋសមាជិកនៃកតិកាសញ្ញានេះ កម្ពុជាត្រូវជាប់កាតព្វកិច្ចតាមផ្លូវច្បាប់ពីការប្តេជ្ញាចិត្តចំពោះប្រជាពលរដ្ឋរបស់ខ្លួន និងចំពោះសហគមន៍អន្តរជាតិ ក្នុងការអនុវត្តបទបញ្ញត្តិនៃសន្ធិសញ្ញានេះ ដើម្បីលើកស្ទួយ និងការពារសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយរបស់ប្រជាពលរដ្ឋគ្រប់រូបនៅក្នុងប្រទេសកម្ពុជា។ កតិសញ្ញានេះ បានបង្កើតគណៈកម្មាធិការអន្តរជាតិមួយ ដើម្បីជួយរដ្ឋភាគីក្នុងការបំពេញបាននូវការប្តេជ្ញាចិត្ត ដែលសុទ្ធតែជាអ្នកជំនាញការឯករាជ្យ ហើយត្រូវបានទទួលស្គាល់ជាទូទៅថា គណៈកម្មាធិការសិទ្ធិមនុស្ស ដើម្បីឃ្លាំមើលការរីកចំរើន និងផ្តល់ប្រឹក្សាយោបល់ដល់រដ្ឋជាភាគី។ រដ្ឋភាគីទាំងអស់ តម្រូវអោយរាយការណ៍ជាទៀងទាត់ទៅគណៈកម្មាធិការនេះពីការចាត់វិធានការរបស់ខ្លួន ដើម្បីធានាបាននូវការអនុវត្តកតិកាសញ្ញានេះ។ បន្ទាប់មករបាយការណ៍នេះត្រូវបានយកមកពិភាក្សាជាមួយរដ្ឋាភិបាលសាមីរួចផ្តល់អនុសាសន៍ដល់រដ្ឋនោះ។ ដូចគ្នាដែរកម្ពុជា បានដាក់របាយការណ៍ដំបូងរបស់ខ្លួនជូនអង្គការសហប្រជាជាតិនៅឆ្នាំ ១៩៩៨ ហើយគណៈកម្មាធិការបានយករបាយការណ៍នោះមកពិនិត្យនៅខែកក្កដា ឆ្នាំ ១៩៩៩។

### ១.៣ កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ចសង្គមកិច្ច និងវប្បធម៌

កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ត្រូវបានអនុម័តនៅថ្ងៃទី១៦ ខែធ្នូ ឆ្នាំ១៩៦៦ ដោយមហាសន្និបានអង្គការសហប្រជាជាតិ ហើយបានចូលជាធរមាននៅថ្ងៃទី០៣ ខែមករា ឆ្នាំ១៩៧៦[26]។ កតិកាសញ្ញានេះ មិនខុសគ្នាពីកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយដែរ ដោយបានផ្តល់អានុភាពតាមផ្លូវច្បាប់ដល់សេចក្តីប្រកាស ជាសកល

[21] រដ្ឋធម្មនុញ្ញ លេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ១៩៩៣ មាត្រា៣២

[22] រដ្ឋធម្មនុញ្ញ លេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ១៩៩៣ មាត្រា៣២,៣៥,៤២

[23] រដ្ឋធម្មនុញ្ញ លេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ១៩៩៣ មាត្រា៣៦

[24] រដ្ឋធម្មនុញ្ញ លេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ១៩៩៣ មាត្រា៣៨

[25] រដ្ឋធម្មនុញ្ញ លេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ១៩៩៣ មាត្រា៤០

[26] កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (អនុម័តថ្ងៃទី១៦ ខែធ្នូ ឆ្នាំ១៩៦៦ ចូលជាធរមាននៅថ្ងៃទី០៣ ខែមករា ឆ្នាំ១៩៧៦)

ស្តីពីសិទ្ធិមនុស្សឆ្នាំ១៩៤៨។ ទោះជាយ៉ាងនេះក្តី កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ខុសពីកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយដោយសារវាមិនអាចអនុវត្តបានភ្លាមៗ និងដាច់ខាតនោះទេ ព្រោះសិទ្ធិទាំងនេះ ទាមទារនូវពេលវេលា និងធនធានសម្រាប់ការអភិវឌ្ឍគោលនយោបាយ និងហេដ្ឋារចនាសម្ព័ន្ធ។ ជាក់ស្តែង ការអនុវត្តយ៉ាងពេញលេញនូវ សិទ្ធិអប់រំទាមទារជាដំបូងអោយមានការសាងសង់អគារ និងការបណ្តុះបណ្តាលគ្រូបង្រៀន ដែលត្រូវចំណាយធនធាន ហើយដែលប្រទេសជាច្រើនខ្សត់ខ្សោយ។ ដើម្បីដោះស្រាយ បញ្ហានេះ កតិកាសញ្ញានេះតម្រូវអោយរដ្ឋភាគីធានាការរីក ចំរើនជាលំដាប់នៃសិទ្ធិទាំងនេះ។ ទោះជាធនធាន អាចមានកំរិតក៏ដោយ ប៉ុន្តែយ៉ាងហោចណាស់រដ្ឋភាគី ត្រូវតែធ្វើអោយមានការរីកចំរើនជាបន្តបន្ទាប់ និងជាក់ស្តែង ដើម្បីធ្វើអោយកាន់តែប្រសើរឡើងតាមតែអាចធ្វើបានដល់ការរីកចំរើននៃសិទ្ធិទាំងនេះ។ ហើយនៅពេលណាដែលសិទ្ធិទាំងនេះ អាច អនុវត្តបានយ៉ាងពេញលេញភ្លាមៗត្រូវតែអនុវត្ត។ កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌បានចែងនូវសិទ្ធិសំខាន់ៗ ដែលមនុស្សគ្រប់រូបមានសិទ្ធិទទួលបានរួមមាន៖

- ✓ សិទ្ធិធ្វើការងារ (មាត្រា៦)[27] សិទ្ធិទទួលបាននូវលក្ខខណ្ឌការងារត្រឹមត្រូវ និងអំណោយផល និងសិទ្ធិទទួលបានការសំរាកលំហែ (មាត្រា៧)
- ✓ សិទ្ធិសហជីព (មាត្រា៨)
- ✓ សិទ្ធិទទួលបានសន្តិសុខសង្គម (មាត្រា៩)
- ✓ សិទ្ធិគ្រួសាររួមទាំងអាពាហ៍ពិពាហ៍ និងការគាំពារស្ត្រីនិងកុមារ (មាត្រា១០)
- ✓ សិទ្ធិទទួលបានកម្រិតជីវភាពគ្រប់គ្រាន់ រួមមានចំណីអាហារ សំលៀកបំពាក់ និងលំនៅដ្ឋាន និងការកែលម្អកំរិតជីវភាពជាបន្តបន្ទាប់ (មាត្រា១១)
- ✓ សិទ្ធិទទួលបានសុខភាពផ្លូវកាយ និងផ្លូវចិត្ត (មាត្រា១២)
- ✓ សិទ្ធិទទួលបានការអប់រំ រួមទាំងការអប់រំមិនបង់ថ្លៃ និងជាកាតព្វកិច្ចនៅបឋមសិក្សា (មាត្រា១៣ និង១៤)
- ✓ សិទ្ធិវប្បធម៌ (មាត្រា១៥)

ព្រះរាជាណាចក្រកម្ពុជា បានចូលជាភាគីនៃកតិកាសញ្ញានេះ នៅថ្ងៃទី២៦ ខែសីហា ឆ្នាំ១៩៩២។ មាត្រា៣១នៃរដ្ឋធម្មនុញ្ញ ធានាការពារអនុសញ្ញាជាផ្នែកមួយនៃច្បាប់កម្ពុជាហើយ មាត្រាដទៃៗទៀត សបញ្ជាក់អោយឃើញថាប្រជាជនកម្ពុជាទាំងអស់ អាចទទួលបានសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ក្នុងវិសាលភាពមួយដ៏ពេញលេញបំផុតតាមដែលអាចធ្វើបាន។ ជាក់ស្តែង

[27] កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (អនុម័តថ្ងៃទី១៦ ខែធ្នូ ឆ្នាំ១៩៦៦ ចូលជាធរមាននៅថ្ងៃទី០៣ ខែមករា ឆ្នាំ១៩៧៦) មាត្រា៦-១៥

ក្នុងមាត្រា៣៦ ចែងពីសិទ្ធិធ្វើការងារ សិទ្ធិទទួលបានលក្ខខណ្ឌការងារត្រឹមត្រូវ និងសិទ្ធិចូលរួមបង្កើតសហជីព (មាត្រា៦៥) ការពារសិទ្ធិទទួលបានការអប់រំដែលមានគុណភាព (មាត្រា៧២) ធានាការពារសិទ្ធិសុខភាពរបស់ប្រជាជន និងមាត្រា ៧៥ តម្រូវអោយរដ្ឋភាគី បង្កើតប្រព័ន្ធសន្តិសុខ សង្គមសំរាប់កម្មករ។ លើសពីនេះទៅទៀត រដ្ឋជាភាគីនៃកតិកាសញ្ញានេះ ត្រូវប្តេជ្ញាចិ ត្តដោយចងកាតព្វកិច្ចតាមផ្លូវច្បាប់ចំពោះប្រជាពលរដ្ឋរបស់ខ្លួន និងចំពោះសហគមន៍អន្តរជាតិក្នុងការអនុវត្តបទបញ្ញត្តិទាំងឡាយនៃកតិកាសញ្ញា ដើម្បីលើកស្ទួយ និងការពារសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌។ ដើម្បីតាមដានការអនុវត្តកតិកាសញ្ញានេះ ក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គមកិច្ចនៃអង្គការសហប្រជាជាតិ បានបង្កើតគណៈកម្មាធិការអន្តរជាតិមួយនៃអ្នកជំនាញការឯករាជ្យ ដែលហៅថា គណៈកម្មាធិការសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដើម្បីតាមដានការរីកចំរើនរបស់រដ្ឋភាគី។ ក្នុងនោះរដ្ឋភាគីទាំងអស់ ត្រូវតែធ្វើរបាយការណ៍ជាទៀងទាត់ទៅគណៈកម្មាធិការស្តីពីដំណាក់កាលនានា ដែលខ្លួនបានប្រកាន់យកក្នុងការអនុវត្តអោយបាននូវកាតព្វកិច្ច ដែលមានចែងក្នុងកតិកាសញ្ញានេះ។ ចំពោះប្រទេសកម្ពុជាវិញរបាយការណ៍ដំបូងរបស់ខ្លួន បានដល់ពេលកំណត់ដាក់ជូនគណៈកម្មាធិការនាខែមិថុនា ឆ្នាំ ១៩៩៤ តែរហូតមកដល់ខែតុលា ឆ្នាំ២០០៨ ទើបរដ្ឋាភិបាល បានដាក់របាយការណ៍របស់ខ្លួនជូនគណៈកម្មាធិការ ហើយគណៈកម្មាធិការពិនិត្យរបាយការណ៍នេះនៅក្នុងសម័យប្រជុំរបស់ខ្លួនក្នុងថ្ងៃទី១ ខែឧសភា ឆ្នាំ២០០៩។

### ២. បទដ្ឋានគតិយុត្តជាតិ

### ២.១. រដ្ឋធម្មនុញ្ញ

សិទ្ធិសេរីភាពបញ្ចេញមតិ ក៏ត្រូវបានធានាក្នុងរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ផងដែរ ក្នុងមាត្រា៣១ ដែលចែងថា "ព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់ និងគោរពសិទ្ធិមនុស្សដូចមានចែង ក្នុងធម្មនុញ្ញអង្គការសហប្រជាជាតិ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងកតិកាសញ្ញាព្រមទាំងអនុសញ្ញាទាំងឡាយទាក់ទងនឹងសិទ្ធិមនុស្ស..."។[28] ម្យ៉ាងវិញទៀតក្នុងក្រុមប្រឹក្សា ធម្មនុញ្ញនៃប្រទេសកម្ពុជា ដែលមានអាណត្តិក្នុងការការពាររដ្ឋធម្មនុញ្ញ បានអះអាងក្នុងសេចក្តី សម្រេចកាលពីឆ្នាំ២០០៧ថា តួនាទីសន្ធិសញ្ញាសិទ្ធិមនុស្ស គឺត្រូវចាត់ទុកជាច្បាប់ជាតិ ហើយអាចអនុវត្តបានចំពោះមុខតុលាការ។ សេចក្តីសម្រេចនោះ បានចែងថា គ្មានច្បាប់ណាត្រូវបានយកមក ប្រើប្រាស់ប្រាកចាកលើរដ្ឋធម្មនុញ្ញ ឬសន្ធិសញ្ញាសិទ្ធិមនុស្សដែលកម្ពុជាជារដ្ឋភាគីនោះឡើយ។ កម្ពុជាគឺប្រកាន់នូវប្រព័ន្ធច្បាប់មួយអាស្រ័យហេតុនេះសន្ធិសញ្ញាអន្តរជាតិ ដែលកម្ពុជាបានផ្តល់សច្ចាប័ននោះ គួរតែត្រូវបានបញ្ចូលដោយស្វ័យប្រវត្តិទៅក្នុងច្បាប់ជាតិ។ បន្ថែមលើសនេះទៀត សិទ្ធិ

[28] រដ្ឋធម្មនុញ្ញ លេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ១៩៩៣ មាត្រា៣១

សេរីភាពបញ្ចេញមតិ គឺត្រូវបានធានាដោយឡែកក្រោមមាត្រា៤១នៃរដ្ឋធម្មនុញ្ញ ដែលចែងថា ពលរដ្ឋខ្មែរមានសេរីភាពខាងបញ្ចេញមតិរបស់ខ្លួន សេរីភាពខាងសារពត៌មាន សេរីភាពខាងការបោះពុម្ពផ្សាយ សេរីភាពខាងការប្រជុំ។ រដ្ឋធម្មនុញ្ញលើកកម្ពស់ដល់មជ្ឈដ្ឋានមួយដែលពលរដ្ឋត្រូវបានគេពង្រឹងអំណាច ដើម្បីប្រើប្រាស់សិទ្ធិរបស់ខ្លួន ក្នុងការបញ្ចេញមតិ និងចូលរួមក្នុងកិច្ចការសាធារណ:[29]។ មាត្រា៣៥នៃរដ្ឋធម្មនុញ្ញ បានបញ្ញាត្តិថា ពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិចូលរួមយ៉ាងសកម្មក្នុងជីវភាពនយោបាយ សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌របស់ប្រទេសជាតិ។ សេចក្តីស្នើទាំងឡាយរបស់ពលរដ្ឋ ត្រូវទទួលបានការពិនិត្យ និងដោះស្រាយយ៉ាងហ្មត់ ចត់ពីអង្គការរដ្ឋ[30]។ ហើយសិទ្ធិក្នុងការបញ្ចេញមតិតាមរយៈការធ្វើបាតុកម្មដោយសន្តិវិធី ក៏ត្រូវបានចែងដោយរដ្ឋធម្មនុញ្ញក្នុងមាត្រា៣៧ ដែលថាសិទ្ធិធ្វើកូដកម្ម និងធ្វើបាតុកម្មដោយសន្តិវិធី...។[31]

## ២.២ ច្បាប់ស្តីពីរបបសារពត៌មាន

ច្បាប់ស្តីពីរបបសារពតិមាន ត្រូវបានចូលជាធរមាននៅថ្ងៃទី ០១ ខែកញ្ញា ឆ្នាំ១៩៩៥ ក្រោយពីបានទទួលការអនុម័តពីរដ្ឋសភា និងព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជារួចមក។ លិខិតបទដ្ឋានគតិយុត្តិមួយនេះ មានសារៈសំខាន់ខ្លាំងណាស់ចំពោះសិទ្ធិនយោបាយ ដោយសារវាបាន កំណត់ពីសិទ្ធិ និងសេរីភាពខាងសារពតិមានរបស់ប្រជាពលរដ្ឋកម្ពុជាទាំងអស់។ ក្នុងនាមជាប្រទេសដែលប្រកាន់នូវលទ្ធិប្រជាធិបតេយ្យ ប្រទេសកម្ពុជា បានបើកចំហយ៉ាងទូលាយចំពោះសេរីភាពខាងសារពតិមាន ក្នុងគោលបំណងអោយប្រជាពលរដ្ឋរបស់ខ្លួនទាំង អស់ទទួលបាននូវគ្រប់ពតិមានទាំងអស់នូវរាល់ព្រឹត្តិការណ៍ ដែលបានកើតឡើងនៅក្នុងសង្គមមិនថាជាបញ្ហាសេដ្ឋកិច្ច សង្គមកិច្ច ឬនយោបាយនោះទេ។ ប៉ុន្តែសេរីភាពទាំងនោះក៏ត្រូវស្ថិតក្រោមការគ្រប់គ្រងរបស់ច្បាប់ក្នុងប្រទេសកម្ពុជាផងដែរ គឺច្បាប់ស្តីពីរបបសារពតិមាននេះឯង។ ច្បាប់នេះបានចែងយ៉ាងច្បាស់ហើយថា រាល់ការបោះពុម្ពផ្សាយពតិមានមួយចំនួន ត្រូវបានអនុញ្ញាត និងពតិមានខ្លះទៀតត្រូវបានហាមឃាត់។ ជាក់ស្តែងរាល់ការបោះពុម្ពផ្សាយនូវពតិមានផ្លូវការដូចជា សេចក្តីថ្លែងការណ៍ ការប្រជុំ កំណត់ហេតុប្រជុំ ឬ របាយការណ៍ណាមួយ មិនត្រូវបានផ្តន្ទាទោសឡើយ លើកលែងតែមាន ការហាមឃាត់ដោយតុលាការដោយហាមមិនអោយបើកចំហដល់សាធារណជន អាថិកំបាំងរបស់បុគ្គលម្នាក់ៗ ក្នុងការជំរះក្តី និងសំណុំរឿង ដែលនៅក្នុងការអង្កេតស៊ើបសួរ របស់តុលាការនៅឡើយ (មាត្រា៤)[32]។ ទោះជាយ៉ាងនេះក្តីជាគោលការណ៍ សារពតិមានសិទ្ធិទទួលពតិមានដែលស្ថិតក្នុងការគ្រប់គ្រងរបស់រាជរដ្ឋាភិបាល លើកលែងតែពតិមានណា ដែល

[29] រដ្ឋធម្មនុញ្ញ លេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ១៩៩៣ មាត្រា៤១

[30] រដ្ឋធម្មនុញ្ញ លេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ១៩៩៣ មាត្រា៣៥

[31] រដ្ឋធម្មនុញ្ញ លេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ១៩៩៣ មាត្រា៣៧

[32] ច្បាប់ស្តីពីរបបសារពតិមាន ចុះលេខ នស/រកម/០៨៩៥/០០៧ នៅថ្ងៃទី០១ ខែកញ្ញា ឆ្នាំ១៩៩៥ មាត្រា៤

អន្តរាយដល់សន្តិសុខ អន្តរាយដល់ទំនាក់ទំនងជាមួយប្រទេសដទៃ ការបំពានលើសិទ្ធិ របស់បុគ្គលម្នាក់ៗ ការលាតត្រដាងឯកសារសម្ងាត់ផ្នែកពាណិជ្ជកម្មផ្នែកហិរញ្ញវត្ថុប៉ះពាល់ដល់សិទ្ធិជនណាម្នាក់ ក្នុងការនាំអោយមានជំនុំជំរះក្តីដោយអយុត្តិធម៌ និងមានគ្រោះថ្នាក់ដល់មន្ត្រីដែលត្រូវអនុវត្តច្បាប់ជាដើម (មាត្រា៥)[33]។ ម៉្យាងច្បាប់ស្តីពីរបបសារពត៌មាន ក៏បានបញ្ញត្តិផងដែរពីការទទួលខុសត្រូវនៃអ្នកសារពត៌មាន ដោយក្នុងនោះពួកគេ មានសិទ្ធិបង្កើតសមាគមអ្នកសារពត៌មានដោយមានលក្ខណៈឯករាជ្យ ហើយត្រូវគ្រប់គ្រងដោយលក្ខន្តិកៈរបស់ខ្លួនដែលមិនផ្ទុយនឹងច្បាប់ជាធរមាន (មាត្រា៦)[34]។

### ២.៣. ច្បាប់ស្តីពីការធ្វើបាតុកម្មដោយសន្តិវិធី

ច្បាប់ស្តីពីការធ្វើបាតុកម្មដោយសន្តិវិធី ត្រូវបានចូលជាធរមាននៅថ្ងៃទី០៥ ខែធ្នូ ឆ្នាំ ២០០៩ ក្រោយពីមានការអនុម័តយល់ព្រមពីរដ្ឋសភា និងព្រឹទ្ធសភារួចមក។ ច្បាប់នេះត្រូវបានបង្កើតឡើងដោយឈរលើគោលការណ៍សិទ្ធិនយោបាយរបស់ប្រជាពលរដ្ឋកម្ពុជា គឺមានបំណង ធានាការពារសេរីភាពខាងការបញ្ចេញមតិរបស់ប្រជាពលរដ្ឋខ្មែរ តាមរយៈការធ្វើបាតុកម្មដោយសន្តិវិធី។ ជាការឆ្លើយតប ទៅនឹងការប្រើប្រាស់សិទ្ធិសេរីភាពនៅក្នុងសង្គមប្រជាធិបតេយ្យ រាជរដ្ឋាភិបាលមានកាតព្វកិច្ច ត្រូវតែការពារនូវសិទ្ធិទាំងនោះរបស់ពួកគេលើកលែងតែការប្រើប្រាស់ សិទ្ធិនេះដោយរំលោភទៅដល់សិទ្ធិសេរីភាព និងកិត្តិយសរបស់អ្នកដទៃដល់ទំនៀមទំលាប់ល្អរបស់សង្គមជាតិ ដល់សណ្តាប់ធ្នាប់សាធារណៈ និងដល់សន្តិសុខជាតិឡើយ (មាត្រា២)[35]។ ច្បាប់នេះបានសម្តែងការគាំទ្រដល់ការធ្វើបាតុកម្មអហិង្សារបស់ប្រជាពលរដ្ឋខ្មែរគ្រប់រូប ដោយបានញ្ញាត្តិយ៉ាងច្បាស់ពីនីតិវិធីនៃការធ្វើបាតុកម្មដោយសន្តិវិធីនៅទីសារធារណៈ ដោយមានការជូនដំណឹងជាលាយលក្ខណ៍អក្សរទៅអាជ្ញាធរ ដែនដីរាជធានី ឬខេត្ត ដែលមានសមត្ថកិច្ចគ្រប់គ្រង ទីកន្លែងនោះ (មាត្រា៥)[36]។ ជាពិសេសដើម្បីអោយការធ្វើបាតុកម្មដោយសន្តិវិធីនេះប្រព្រឹត្តទៅបានដោយរលូន ច្បាប់ស្តីពីការធ្វើបាតុកម្មដោយសន្តិវិធី ក៏បានបញ្ជាក់ផងដែរនូវការទទួលខុសត្រូវរបស់អ្នកដឹកនាំធ្វើបាតុកម្ម និងអាជ្ញាធរមានសមត្ថកិច្ច ដោយពួកគេ ត្រូវតែសហការជាមួយនគរបាលមូលដ្ឋាន និងកងរាជអាវុធហត្ថ ដើម្បីទប់ស្កាត់ផលអាក្រក់ ដែលនឹងអាចកើតមានដោយការធ្វើកំណាត់ផ្លូវខាងលើអោយមានភាពងាយស្រួល និងសម្រួលចរាចរណ៍សម្រាប់យានយន្ត ដោយការ

---

[33] ច្បាប់ស្តីពីរបបសារពត៌មាន ចុះលេខ នស/រកម/០៨៩៥/០០៧ នៅថ្ងៃទី០១ ខែកញ្ញា ឆ្នាំ១៩៩៥ មាត្រា៥

[34] ច្បាប់ស្តីពីរបបសារពត៌មាន ចុះលេខ នស/រកម/០៨៩៥/០០៧ នៅថ្ងៃទី០១ ខែកញ្ញា ឆ្នាំ១៩៩៥ មាត្រា៦

[35] ច្បាប់ស្តីពីការធ្វើបាតុកម្មដោយសន្តិវិធី ចុះលេខ នស/រកម/១២០៩/០១២ នៅថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០០៩ មាត្រា២

[36] ច្បាប់ស្តីពីការធ្វើបាតុកម្មដោយសន្តិវិធី ចុះលេខ នស/រកម/១២០៩/០១២ នៅថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០០៩ មាត្រា៥

ធ្វើកំណាត់ផ្លូវ ខាងលើអោយមានភាពងាយស្រួល និងសម្រួលចរាចរណ៍សម្រាប់យានយន្ត ដើម្បីកុំអោយមានការរំខានធ្ងន់ធ្ងរដល់ដំណើរការអាជីវកម្មសេវាកម្ម ពាណិជ្ជកម្ម ឬជំនួញផ្សេងៗ (មាត្រា១៥)[37]។ បទបញ្ញាត្តិនៃច្បាប់នេះ ក៏បានហាមឃាត់នៅក្នុងករណី ដែលបាតុករណា មានកាន់ឧបករណ៍ ដែលអាចបណ្តាលអោយមានគ្រោះថ្នាក់ ឬអាចបង្កទុក្ខទោសដល់អ្នកដទៃ ឬប្រព្រឹត្តអំពើណាមួយ ដែលជាការជ្រៀតជ្រែកសិទ្ធិសេរីភាពអ្នកដទៃ អាជ្ញាធរមានសមត្ថកិច្ច ត្រូវដកហូតឧបករណ៍ទាំងនោះចេញ ឬហាមប្រាមកុំអោយបាតុករនោះប្រព្រឹត្តអំពើនេះទៀត តែប្រសិនបើបាតុករនោះ មានការរឹងរូសមិនព្រមបញ្ឈប់អំពើនេះ សមត្ថកិច្ចត្រូវធ្វើការឃាត់ខ្លួនបណ្តោះអាសន្នរហូតដល់បាតុកម្ម ដោយសន្តិវិធីបានបញ្ចប់សព្វគ្រប់ទើបធ្វើការដោះលែងវិញ (មាត្រា២៣)[38]។

[37] ច្បាប់ស្តីពីការធ្វើបាតុកម្មដោយសន្តិវិធី ចុះលេខ នស/រកម/១២០៩/០១២ នៅថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០០៩ មាត្រា១៥

[38] ច្បាប់ស្តីពីការធ្វើបាតុកម្មដោយសន្តិវិធី ចុះលេខ នស/រកម/១២០៩/០១២ នៅថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០០៩ មាត្រា២៣

# ជំពូកទី២៖ ដំណើរការនៃការអនុវត្តសេរីភាពបញ្ចេញមតិនៅកម្ពុជា

## ផ្នែកទី១ ៖ គោលការណ៍ជាមូលដ្ឋាននៃសេរីភាពបញ្ចេញមតិ

### ១. សិទ្ធិទទួលបានពត៌មាន

សិទ្ធិទទួលបានពត៌មាន ត្រូវបានចាត់ទុកថា ជាសិទ្ធិគ្រឹះក៏សំខាន់មួយដែលប្រជាពលរដ្ឋគ្រប់រូប មិនអាចខ្វះបានដោយសារសិទ្ធិនេះចូលរួមចំណែក ក្នុងការទទួលបានសិទ្ធិមនុស្សយ៉ាងពេញលេញរបស់ពលរដ្ឋ ក្នុងប្រទេសនីមួយៗទាក់ទិននឹងសេរីភាពបញ្ចេញមតិនេះផងដែរ ពលរដ្ឋមានលទ្ធភាពក្នុងការបញ្ចេញមតិរបស់ខ្លួនបានដោយការស្វែងយល់ពីមជ្ឈដ្ឋាន និងបរិបទរបស់សង្គមដែលគេរស់នៅ ហើយការទទួលបានពត៌មាននេះ ជាទូទៅត្រូវបានផ្ដល់អោយដោយរដ្ឋពោលគឺរដ្ឋាភិបាលរបស់ប្រទេសនីមួយៗ។ ទន្ទឹមនឹងធាតុផ្សំរបស់រដ្ឋាភិបាល ដែលជាតួអង្គយ៉ាងសំខាន់ ក្នុងការផ្ដល់នូវពត៌មានដល់ប្រជាពលរដ្ឋ រដ្ឋាភិបាលមានកាតព្វកិច្ច និងប្រើប្រាស់អោយអស់លទ្ធភាពនូវគ្រប់មធ្យោបាយក្នុងការបញ្ជូនពត៌មាន និងផ្ដល់ពត៌មានទាំងអស់នោះទៅដល់ពលរដ្ឋរបស់ខ្លួន។ ជាក់ស្ដែងនៅក្នុងប្រទេស ដែលប្រកាន់លិទ្ធិប្រជាធិបតេយ្យ មុនពេលប្រព្រឹត្តនូវការបោះឆ្នោតជាសកលម្ដងៗ រដ្ឋាភិបាល មានកាតព្វកិច្ចផ្សព្វផ្សាយក៏ដូចជា ផ្ដល់នូវគ្រប់ពត៌មានដល់ពលរដ្ឋរបស់ខ្លួនទាក់ទងនឹង គណបក្សនយោបាយដែលបានឈរឈ្មោះ គោលការណ៍របស់គណបក្សនយោបាយ និងការផ្សព្វផ្សាយពីកាលបរិច្ឆេទការបោះឆ្នោតជាដើម។ ការផ្ដល់អោយរបស់ រដ្ឋាភិបាលដល់ពលរដ្ឋ ត្រូវធ្វើមុនពេលបោះឆ្នោតព្រោះថា ការទទួលបាននូវពត៌មានទាំងនោះពេញលេញពីរដ្ឋាភិបាល ធ្វើអោយពលរដ្ឋមានការយល់ដឹងមានការស្វែងយល់ និងមានសមត្ថភាពគ្រប់គ្រាន់ ក្នុងការបញ្ចេញមតិរបស់ពួកគេនាពេលបោះឆ្នោត។ លើសពីនេះទៅទៀត ការលើកកម្ពស់សេរីភាពបញ្ចេញមតិតាមរយៈការផ្ដល់ពត៌មាននេះ ក៏ត្រូវបានកម្រិតនូវព្រំដែនផងដែរដោយសារតែ ការផ្ដល់ពត៌មានជាសាធារណៈនោះ បានធ្វើអោយប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់សណ្ដាប់ធ្នាប់ និងទំនៀមទំលាប់ប្រពៃណីរបស់ប្រទេស។ នៅក្នុងទិដ្ឋភាពបច្ចុប្បន្នប្រទេសខ្លះបានបង្កើតច្បាប់ ដែលបានបញ្ញាត្តិនូវព្រំដែនកំណត់ ក្នុងការទទួលបានពត៌មានពីរដ្ឋាភិបាលរបស់ខ្លួនដោយសារតែពត៌មានមួយចំនួន ជាពត៌មានសំងាត់ និងមិនអាចធ្វើការផ្សព្វផ្សាយជាសារធារណៈ បាន។ ហេតុនេះ យើងសង្កេតឃើញថា សិទ្ធិទទួលបានពត៌មានជាសិទ្ធិ ដែលពលរដ្ឋគ្រប់ៗរូប មានសិទ្ធិទទួលបាននូវពត៌មានតាមគ្រប់មធ្យោបាយពីរដ្ឋាភិបាលរបស់ខ្លួន ហើយរដ្ឋាភិបាលខ្លួនឯង ក៏ត្រូវមានកាតព្វកិច្ចផ្ដល់នូវគ្រប់ពត៌មានទាំងអស់ដល់ពលរដ្ឋរបស់ខ្លួន លើកលែង តែពត៌មានមួយចំនួន ដែលស្ថិតក្នុងការគ្រប់គ្រងរបស់រាជរដ្ឋាភិបាល ហើយពត៌មានទាំងនោះ

ធ្វើអន្តរាយដល់សន្តិសុខ អន្តរាយដល់ទំនាក់ទំនងជាមួយប្រទេសដទៃ និងការបំពានលើសិទ្ធិរបស់បុគ្គលម្នាក់ៗជាដើម។

### ២. សិទ្ធិស្វែងរកពត៌មាន

ការទទួលបានពត៌មាន ដោយគ្រាន់តែពឹងផ្អែកលើពត៌មាន ដែលបានផ្តល់អោយរដ្ឋាភិបាលតែមួយផ្នែក មិនអាចជំរុញអោយមានការបញ្ចេញមតិពេញលេញ និងត្រឹមត្រូវនោះទេ។ ប្រជាពលរដ្ឋខ្លួនឯងក៏មានសិទ្ធិ ក្នុងការស្វែងរកពត៌មានតាមគ្រប់មធ្យោបាយតាម ដែលអាចធ្វើទៅបាន ដើម្បីធ្វើសេរីភាពនៃការបញ្ចេញមតិមាន លក្ខណៈទូលំទូលាយ និងប្រត្យក្ស។ ជាឧទាហរណ៍ នៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍មួយចំនួន ការទទួលបាននូវពត៌មាននៅ មានភាពខ្វះចន្លោះនៅឡើយ ដោយសាររដ្ឋាភិបាលរបស់ប្រទេសទាំងនោះពុំមានលទ្ធភាពគ្រប់គ្រាន់ក្នុងការផ្សព្វផ្សាយពត៌មានដល់ពលរដ្ឋរបស់ខ្លួនអោយមានលក្ខណៈទូលំទូលាយ និងពេញលេញបានទេ។ ដូចនេះ ពលរដ្ឋ អាចធ្វើការស្វែងរកពត៌មានដោយខ្លួនឯងបានតាមរយៈមធ្យោបាយ ជាច្រើនផ្សេងៗគ្នា ជាពិសេសតាមរយៈប្រព័ន្ធអ៊ីនធឺណែត ដែលមានការពេញនិយម និងមានអ្នកប្រើប្រាស់រាប់លាននាក់នៅលើពិភពលោក។ ពលរដ្ឋ អាចស្វែងរកពត៌មានបានយ៉ាង ងាយ ស្រួលរហ័ស និងចំណាយតិចជាងមធ្យោបាយនានា ដែលជាហេតុធ្វើអោយការស្វែងរកពត៌មានរបស់ពលរដ្ឋ មានការពឹងផ្អែកលើការស្វែងរកដោយខ្លួនឯងជាជាងការផ្តល់អោយដោយ រដ្ឋាភិបាលរបស់ខ្លួន។ ប៉ុន្តែ ផ្ទុយទៅវិញ ការស្វែងរកពត៌មានរបស់ពលរដ្ឋមិនសុទ្ធតែមានភាពទូលំទូលាយទេ ដោយសារតែរបបគ្រប់គ្រងប្រទេសនីមួយៗមានភាពខុសគ្នា។ នៅក្នុងប្រទេស ដែលប្រកាន់របបកុម្មុនីស្ត ការស្វែងរកពត៌មានត្រូវបានរឹតត្បិត ដើម្បីរក្សានូវស្ថានភាព និងស្ថេរភាពនយោបាយ និងសេដ្ឋកិច្ចនៅក្នុងប្រទេស។ ប្រទេសចិនជាឧបករណ៍មួយ ដែលរដ្ឋាភិបាលប្រទេសនេះ បានរឹតត្បិតការស្វែងរកនូវពត៌មាន ក្នុងប្រទេសរបស់ខ្លួនដោយបានធ្វើការបិទមិនអោយប្រើប្រាស់ប្រព័ន្ធបណ្តាញសង្គម និងពត៌មានមួយចំនួនមិនអាច ចូលមើលបានជាសាធារណៈឡើង ពោលគឺជាពត៌មានសំងាត់របស់រដ្ឋាភិបាល។ ដូច្នេះ យើងសង្កេតឃើញថា ការទទួលបាននូវពត៌មានដែលផ្តល់អោយដោយរដ្ឋាភិបាល មិនមានលក្ខណៈគ្រប់គ្រាន់នៅឡើយទេ ហេតុនេះប្រជាពលរដ្ឋខ្លួនឯង ត្រូវចេះស្វែងរកនូវពត៌មានទាំងនោះដោយសារតែពួកគេមានសិទ្ធិពេញលេញ ក្នុងការស្វែងរកសិទ្ធិមនុស្សស្របតាមសេចក្តីថ្លែងការ ជាសកលស្តីពីសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិផងដែរ។ ទោះជាយ៉ាងនេះក្តី ប្រជាពលរដ្ឋទាំងអស់ ត្រូវបានកម្រិតនូវសិទ្ធិស្វែងរកពត៌មាន មួយចំនួនដោយសារបរិបទ និងរបបដឹកនាំរបស់ប្រទេសនីមួយៗមានលក្ខណៈខុសគ្នា ដែលតម្រូវអោយរដ្ឋាភិបាល រឹតត្បិតនូវសិទ្ធិក្នុងការស្វែងរកពត៌មានទាំងនោះ។

### ៣. សិទ្ធិផ្សព្វផ្សាយពត៌មាន

ក្រោយពីទទួលបាននូវពត៌មាន និងស្វែងរកបន្ថែមនូវពត៌មានទាំងនោះហើយ ប្រជាពលរដ្ឋគ្រប់រូបនៅ មានសិទ្ធិជាមូលដ្ឋានមួយទៀត គឺសិទ្ធិក្នុងការផ្សព្វផ្សាយនូវពត៌មានទាំងនោះ ដើម្បីបញ្ជាក់ពីលទ្ធភាពនិង សមត្ថភាពគ្រប់គ្រាន់របស់ពលរដ្ឋក្នុងការបញ្ចេញមតិរបស់ពួកគេ។ សិទ្ធិក្នុងការផ្សព្វផ្សាយពត៌មាន បានអនុញ្ញាតអោយពលរដ្ឋធ្វើការផ្សព្វផ្សាយនូវគំនិត យោបល់ ឬការយល់ឃើញរបស់ពួកគេដោយធ្វើការចែករំលែកនូវពត៌មានទាំងនោះទៅអ្នកដទៃយ៉ាងសេរី និងទូលំទូលាយ។ នៅក្នុងទិដ្ឋភាពសង្គមទូទៅការផ្សព្វផ្សាយពត៌មាន ត្រូវបានធ្វើឡើងតាមគ្រប់មធ្យោបាយ ទាំងអស់ដូចជា ការផ្សព្វផ្សាយតាមរយះទូរទស្សន៍ វិទ្យុ ប្រព័ន្ធអ៊ីនធឺណេតជាដើម។ ជាក់ស្តែង ការចែករំលែកនូវរបស់ពលរដ្ឋទាក់ទងនឹងនិន្នាការនយោបាយ ឬទស្សនះរបស់បុគ្គលម្នាក់ៗទាក់ទងនឹងបញ្ហានយោបាយ ត្រូវបានអនុញ្ញាតអោយមានការផ្សព្វផ្សាយយ៉ាងពេញលេញដោយហេតុថាការផ្សព្វផ្សាយជាសារធារណៈ អំពីទស្សនះរបស់បុគ្គលម្នាក់ៗស្តែងអោយឃើញពីការចូលរួមក្នុងការបញ្ចេញមតិ និងធ្វើការសេរីភាពក្នុងការបញ្ចេញមតិមានភាពពេញលេញផងដែរ។ ទោះបីជាយ៉ាងនេះក្តី សិទ្ធិក្នុងការផ្សព្វផ្សាយពត៌មានក៏មិន ខុសពីសិទ្ធិទទួលបានពត៌មាន និងសិទ្ធិស្វែងរកពត៌មានដែរ ដោយសារតែសិទ្ធិនេះត្រូវបានកម្រិតនូវព្រំដែនផងដែរ ក្នុងករណីដែលសិទ្ធិផ្សព្វផ្សាយពត៌មានធ្វើអោយមានការប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណះ និងទំនៀមទំលាប់ប្រពៃណីរបស់ប្រទេស និងធ្វើអោយប៉ះពាល់ដល់កេរ្តិ៍ឈ្មោះ ឬកិត្តិយសរបស់បុគ្គលណាមួយ ពោលគឺការផ្សព្វផ្សាយនូវពត៌មានមិនពិតជាសាធារណៈ។ ជារួមយើងឃើញថាបុគ្គលគ្រប់រូបត្រូវបានទទួលការលើកទឹកចិត្ត និងជំរុញអោយមានការបញ្ចេញមតិរបស់ខ្លួនតាមរយះការប្រើប្រាស់នូវសិទ្ធិក្នុងការផ្សព្វផ្សាយពត៌មាន ប៉ុន្តែការផ្សព្វផ្សាយនូវពត៌មានទាំងនោះមិនសុទ្ធតែអាចធ្វើឡើងទៅបានឡើយ ប្រសិនបើមានការបំពារបំពានដល់អ្នកដទៃ ឬខុសពីការបញ្ញាត្តិរបស់ច្បាប់ក្នុងប្រទេស។

## ផ្នែកទី២៖ មធ្យោបាយនៃការបញ្ចេញមតិនៅកម្ពុជា

### ១. ប្រព័ន្ធផ្សព្វផ្សាយបែបប្រពៃណី

### ១.១ ប្រពត្តិ

នៅក្នុងឆ្នាំ១៩៨៧ រដ្ឋបានគ្រប់គ្រងការបោះពុម្ព និងប្រព័ន្ធផ្សព្វផ្សាយអេឡិចត្រូនិក និងកំពុងគ្រប់គ្រងមាតិការបស់ពួកគេរដ្ឋ។ មធ្យមបោះពុម្ព ដែលច្រើនបំផុតក្នុងឆ្នាំ១៩៨៧ គឺទិនានុប្បវត្តិរបស់គណបក្សប្រជាជន ដែលត្រូវបានសម្ពោធដាក់អោយប្រើប្រាស់នៅខែតុលាឆ្នាំ១៩៨៥ ដើម្បីបង្ហាញពីជំហររបស់គណបក្សស្តីពីកិច្ចការក្នុងស្រុក និងអន្តរជាតិ។ ស្ទើរតែ ដូចជាមានសារៈសំខាន់ទោះជាយ៉ាងណា គឺប្រចាំសប្តាហ៍របស់រណសិរ្សសាមគ្គីកសាងការពារ មាតុភូមិកម្ពុជា (KUFNCD) មហាវិថីកម្ពុជាក្រោមនេះ។ ការបោះពុម្ពផ្សាយដ៏សំខាន់នៃកង កម្លាំងប្រដាប់

អាវុធ គឺជាប្រចាំសប្តាហ៍គឺកងទ័ពបដិវត្តន៍។ ក្នុងអំឡុងពេលការកាន់កាប់របស់វៀតណាមនៅឆ្នាំ ១៩៨៧ ប្រទេសកម្ពុជាមិនមានកាសែតប្រចាំថ្ងៃទេ[39]។ បើទោះបីជាស្ថានភាពនេះ បានផ្លាស់ប្តូរយ៉ាងលឿនក្រោយពីការដកកងទ័ពវៀតណាម និងអ៊ុនតាក់ដែលបានត្រួតពិនិត្យការបោះឆ្នោតទូទៅនៅឆ្នាំ១៩៩៣។

វិទ្យុ និងទូរទស្សន៍ បានស្ថិតក្រោមការដឹកនាំរបស់គណៈកម្មការវិទ្យុនិងទូរទស្សន៍កម្ពុជា ដែលបានបង្កើតឡើងនៅក្នុងឆ្នាំ១៩៨៣នេះ។ នៅឆ្នាំ១៩៨៦ មានអ្នកស្តាប់វិទ្យុប្រមាណ២០០.០០០ នាក់នៅក្នុងប្រទេសនោះ។ សម្លេងរបស់ប្រជាជនកម្ពុជាំ (VOKP) កម្មវិធីវិទ្យុផ្សាយជាភាសាខ្មែរ ត្រូវបានវៀតណាម បារាំង អង់គ្លេស ឡាវនិងថៃ។ ដោយមានជំនួយរបស់វៀតណាម ផ្សាយតាមកញ្ចក់ទូរទស្សន៍ ត្រូវបានបង្កើតនៅលើមូលដ្ឋានការ កាត់ទោសនៅក្នុងខែធ្នូ ឆ្នាំ១៩៨៣ ហើយបន្ទាប់មកបានទៀងទាត់នៅចុងបញ្ចប់នៃឆ្នាំ១៩៨៤ នេះ។ នៅខែមិនា ឆ្នាំ១៩៨៦ ទូរទស្សន៍កម្ពុជា (ទទក) បានដំណើរការពីរម៉ោងពេលល្ងាចមួយបួនថ្ងៃក្នុងមួយសប្តាហ៍នៅក្នុងរាជធានី ភ្នំពេញតែប៉ុណ្ណោះ។ នៅក្នុងខែធ្នូ ឆ្នាំ១៩៨៦ វៀតណាម បានយល់ព្រមបណ្តុះបណ្តាល អ្នកបច្ចេកទេសទូរទស្សន៍កម្ពុជា។ សហភាពសូវៀត បានយល់ព្រមសហការជាមួយសាលារាជធានីភ្នំពេញក្នុងការអភិវឌ្ឍនៃប្រព័ន្ធផ្សព្វផ្សាយអេឡិច្រូនិកនេះ។ ទស្សនិកជនកម្ពុជា បានចាប់ផ្តើម ដើម្បីទទួលបានកម្មវិធី ទូរទស្សន៍សូវៀតបន្ទាប់ពីខែមីនា ឆ្នាំ១៩៨៧ តាមរយៈស្ថានីយ៍ផ្កាយរណបមួយ ដែលសហភាពសូវៀតបានសាងសង់ឡើងនៅក្នុងរាជធានីភ្នំពេញ[40]។

ចាប់ផ្តើមនៅឆ្នាំ១៩៧៩ ក្រោមរបបដែលដឹកនាំដោយសម្តេចហេង សំរិន បានលើកទឹកចិត្តមនុស្សអោយអានទិនានុប្បវត្តិផ្លូវការ និងស្តាប់វិទ្យុជារៀងរាល់ថ្ងៃ។ ការរីកពលដាលអនក្ខរកម្ម និងការខ្វះខាតទាំងប្រព័ន្ធផ្សព្វផ្សាយ បោះពុម្ព និងអ្នកទទួលវិទ្យុ ទោះជាយ៉ាងណាមានន័យថា ប្រជាជនកម្ពុជាមួយចំនួន អាចធ្វើតាមការផ្តល់យោបល់របស់រដ្ឋាភិបាល។ ប៉ុន្តែសូម្បីតែនៅពេលប្រព័ន្ធផ្សព្វផ្សាយទាំងនេះ អាចរកបាន "ពួកកម្មាភិបាលនិងយុទ្ធជន" នៅក្នុងកងកម្លាំងប្រដាប់អាវុធ ឧទាហរណ៍មានការចាប់អារម្មណ៍កាន់តែច្រើននៅក្នុងការស្តាប់កម្មវិធីតន្ត្រីជាង ក្នុងការអានអំពី "ស្ថានភាពនិងការអភិវឌ្ឍនៅក្នុងប្រទេសនេះនិង ពិភពលោក ឬអត្ថបទនៅលើគំរូដ៏ល្អនៃមនុស្សល្អ"[41]។

[39] Shinn, Rinn-Sup, The Media (ប្រព័ន្ធផ្សព្វផ្សាយ) នៅឆ្នាំ១៩៨៧

[40] Shinn, Rinn-Sup, The Media (ប្រព័ន្ធផ្សព្វផ្សាយ) នៅឆ្នាំ១៩៨៧

[41] Shinn, Rinn-Sup, The Media (ប្រព័ន្ធផ្សព្វផ្សាយ) នៅឆ្នាំ១៩៨៧

### ១.២. ស្ថានីយ៍ទូរទស្សន៍

ប្រទេសកម្ពុជា បានចាប់ផ្តើមតម្លើងស្ថានីយ៍មួយការធ្វើការសាកល្បងការហៅសញ្ញារបស់វា គឺ XUTV ដែលបានចាប់ផ្តើមផ្សាយនៅក្នុងឆ្នាំ ១៩៦៦។ ស្ថានីយ៍នេះ គឺជាផ្នែកមួយនៃវិទ្យុខ្មែរ ដែលបានគ្រប់គ្រងដោយរដ្ឋនៅឆ្នាំ១៩៧០ ដែលធ្វើប្រតិបត្តិការ ១២ ម៉ោងទៅ ១៤ ម៉ោងជារៀងរាល់ ថ្ងៃដោយមានការផ្សាយពាណិជ្ជកម្មជាចំណូលចម្បងរបស់ខ្លួន។ ក្នុងឆ្នាំ១៩៨៦៣ រដ្ឋាភិបាល បានបើកស្ថានីយ៍ផ្សេងទៀត (ទទក) ក្រោមការជួយទំនុកបម្រុងពីប្រជាជនវៀតណាម ដែលគាំទ្រ ដោយសាធារណរដ្ឋប្រជាមានិតនៃរបបកម្ពុជា។ វាបានចាប់ផ្តើមផ្សាយពីឆ្នាំ១៩៨៦ ហើយវាជា ស្ថានីយ៍តែមួយប៉ុណ្ណោះរហូតដល់ចុងទសវត្ស១៩៩០ ពេលដែលក្រុមហ៊ុនឯកជន បានចាប់ផ្តើម បើកដំណើរការស្ថានីយ៍របស់ខ្លួន[42]។

មានស្ថានីយ៍ទូរទស្សន៍ចំនួន១១នៅទូទាំងប្រទេស រួមទាំងស្ថានីយ៍បញ្ជូនពីរជាមួយនឹង ភាសាបារាំង ថៃនិងវៀតណាមផ្សាយក៏ដូចជា ស្ថានីយ៍ថាមពលទាបដល់១២ក្នុងតំបន់រួមមាន៖

- ប៉ុស្តិ៍លេខ ៣
- ទូរទស្សន៍ MNBT
- ទូរទស្សន៍អប្សរា (TV១១) ការចាក់ផ្សាយជារៀងរាល់ថ្ងៃចាប់ពីម៉ោង៥:៣០ ព្រឹកដល់ម៉ោង១០:០០រសៀល
- ទូរទស្សន៍បាយ័នឆានែល UFO តែមួយគត់របស់ប្រទេសកម្ពុជា ដែលមានមូលដ្ឋាននៅក្នុងខេត្តកណ្តាលខេត្តកណ្តាល
- បណ្តាញទូរទស្សន៍កម្ពុជា (ស៊ីធីអិន) អតីតស្ថានីយ៍ទូរទស្សន៍នៅកម្ពុជាបណ្តាញ (CTN)
- MY TV ប៉ុស្តិ៍ ទូរទស្សន៍មួយ ដែលផ្តោតសំខាន់លើមនុស្សវ័យជំទង់ និងយុវជនកម្ពុជា ដែលជាកម្មសិទ្ធិរបស់ទូរទស្សន៍ស៊ីធីអិនផងដែរ
- ទូរទស្សន៍ខ្មែរ (CTV៩)
- ទូរទស្សន៍ជាតិកម្ពុជា (ទទក)
- ទូរទស្សន៍កងយោធាពលភូមិន្ទកម្ពុជា (TV៥) ផ្សាយ ១៧.៥ ម៉ោងពី ៦.០០ព្រឹកដល់ ១១:៣០ ល្ងាច
- SEATV (ស្ថានីយ៍ទូរទស្សន៍អាស៊ីខាងត្បូងភាគខាងកើត)
- ទូរស្សន៍ HDTV ហាង្សមាស ទូរទស្សន៍ HDTV ជាលើកដំបូងនៅក្នុងប្រទេសកម្ពុជា មានការផ្សាយ២៤ម៉ោងក្នុងមួយថ្ងៃ។
- CNC

[42] Alan G. Davies, *Television Stations in Cambodia*, http://www.asiawaves.net/cambodia-tv.htm (ថតចម្លងថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៦

- បាយ័នព័ត៌មាន (Bayon News TV)
- CTV8

អ្នកផ្តល់សេវាទូរទស្សន៍ខ្សែកាប មាន៖

- DTV STAR Co., Ltd
- ទូរទស្សន៍ខ្សែកាបកម្ពុជា (ស៊ីស៊ីធីវី)[43]

ចាប់តាំងពីឆ្នាំ ២០០៩ វិស័យឧស្សាហកម្មខ្សែភាពយន្តនេះ បានកើនឡើងដោយអត្រា ២៦% ទាក់ទាញ ក្រុមហ៊ុនខ្សែភាពយន្តនិងនាយក ដើម្បីថតខ្សែភាពយន្តនៅលើសមុទ្រ ក្នុងប្រទេសកម្ពុជា។

**ទូរទស្សន៍កម្ពុជានាពេលអនាគត**

នៅឆ្នាំ ២០១៥ ទូរទស្សន៍កម្ពុជាគ្រោង នឹងប្តូរទៅឌីជីថលផ្សព្វផ្សាយវីដេអូ DVB-T មាននៅក្នុងអនុសាសន៍របស់អាស៊ាន។ បច្ចុប្បន្នទូរទស្សន៍ One TV ប៉ុណ្ណោះ ដែលបានចាប់ផ្តើមផ្តល់ជូននូវសេវាកម្មនៅក្នុងខែកញ្ញា ឆ្នាំ ២០១២ ត្រូវបានផ្តល់ជូននូវផ្សាយ DVB-T មាននៅក្នុងប្រទេសកម្ពុជា។

**១.៣ ស្ថានីយ៍វិទ្យុ**

ប្រទេសកម្ពុជាមានស្ថានីយ៍ AM ពីរ និងស្ថានីយ៍វិទ្យុ FM យ៉ាងយោចណាស់៦៥។

បញ្ជីនៃស្ថានីយ៍វិទ្យុ៖

- វិទ្យុ TOWN FM ១០២.២៥ $HM_Z$
- វិទ្យុ TOWN FM ៩៥.៧ $MH_Z$បាត់ដំបង
- វិទ្យុ TOWN FM ៩០.៧ MHZ សៀមរាប
- វិទ្យុ TOP FM ៩២.៣ MHZ
- Dance FM Phnom Penh
- NRG ៨៩ FM
- Radio Love FM ៩៧.៥ MHz ស្ថានីយ៍វិទ្យុតន្ត្រីប៉ុបលោកខាងលិចក្នុងស្រុករបស់ប្រទេសកម្ពុជា
- វិទ្យុអូស្ត្រាលី វិទ្យុ FM ១០១.៥ រាជធានីភ្នំពេញ និងខេត្តសៀមរាប ដែលអាចប្រើបាន ២៤ម៉ោងក្នុងមួយថ្ងៃច័ន្ទ
- BBC World Service Radio FM ១០០
- វិទ្យុអប្សរាFM៩៧ MHz
- វិទ្យុគ្រួសារFM៩៩.៥ MHz

[43] Alan G. Davies, *Television Stations in Cambodia*, http://www.asiawaves.net/cambodia-tv.htm (ថតចម្លងថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៦

- វិទ្យុជាតិកម្ពុជាAM៩១៨ និងFM៩៦
- វិទ្យុសំបុកឃ្មុំFM ១០៥ MHz
- វិទ្យុFM៩០ MHz
- វិទ្យុFM៩៩ MHz
- វិអូអេសំលេងសហរដ្ឋអាមេរិក(VOA)
- វិទ្យុអាស៊ីសេរី
- វិទ្យុខ្មែរFM១០៧ MHz
- វិទ្យុ Sweet FM ៨៨ MHz
- វិទ្យុកងទ័ពកម្ពុជា
- វិទ្យុFM១០២Mhz របស់ស្រ្តីនៃមណ្ឌលពត៌មានស្រ្តីកម្ពុជា ការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយ ដើម្បីជំរុញការផ្លាស់ប្តូរសង្គមនៅក្នុងសង្គមកម្ពុជា។
- វិទ្យុសារិកា FM ១០៦.៥ MHz
- វិទ្យុ FM ៩៥.៧MHz[44]

**១.៤ ការសែត និងបញ្ជីការសែត**

សារពត៌មានមាននៅក្នុងប្រទេសកម្ពុជា មានជាងប្រមាណ ១០០ ប៉ុន្មាននេះជាយ៉ាង ណាមានសារពត៌មានតិចតួចប៉ុណ្ណោះ ដែលរក្សាកាលវិភាគបោះពុម្ពផ្សាយទៀងទាត់ និងបាន បង់ថ្លៃបុគ្គលិក។ កាសែតជាច្រើន ត្រូវបានគ្រប់គ្រងដោយគណបក្សនយោបាយ ឬបុគ្គលអ្នក នយោបាយ ដូច្នេះ ការផ្សព្វផ្សាយពត៌មានមានលក្ខណៈលម្អៀង។ ពេលខ្លះអ្នក យកព័ត៌មាន នឹងទាមទារការទូទាត់ពីប្រភពរបស់ពួកគេ ដើម្បីរក្សារឿងអាស្រូវដោយមិនគិតថាតើពិត ឬមិន ពិតនោះទេ។

បញ្ជីនៃការសែត មានដូចខាងក្រោម៖

- ចក្រវាឡដេលី
- កម្ពុជាថ្មីដេលី
- កម្ពុជាថ្ងៃនេះ
- កោះសន្តិភាព
- មនសិកាខ្មែរ ចេញផ្សាយដោយគណបក្សសម រង្ស៊ី
- រស្មីកម្ពុជា

[44] Alan G. Davies, Radio Station in Cambodia (២០១៤), http://www.asiawaves.net/cambodia-radio.htm (ថតចម្លងថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៦

- សម្លេងយុវជន
- ឧត្តមគតិខ្មែរ
- វត្តភ្នំដេលី
- The Messenger ចេញផ្សាយដោយការិយាល័យជាតិទំនាក់ទំនងសង្គមកាតូលិក
- Kanychok Sangkhum[45]

កាសែតជាភាសាអង់គ្លេស មាន៖

- Business News
- CTown Daily
- The Cambodia Times
- The Mirror
- Phnom Penh Post[46]

ទស្សនាវដ្តីភាសាអង់គ្លេស មាន៖

- Cambodia Tourism Magazine
- Cambodia CityLife Magazine
- Lady Penh
- BayonPearnik
- Visitors Guide
- Cambodia Pocket Guide
- Southeast Asia Globe
- Discover Cambodia
- Asialife Guide Phnom Penh
- Economics Today
- Coastal
- Sports Express[47]

កាសែតភាសាបារាំង មាន៖

- Cambodge Nouveau
- Cambodge Soir[48]

កាសែតភាសាចិន មាន៖

- Cambodia Sin Chew Daily
- Jian Hua Daily[49]

---

45 List of Newspapers in Cambodia (២០១២), http://en.wikipedia.org/wiki/List_of_newspapers_in_cambodia (ថតចម្លងថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៦)

46 ដូចទី៤៣ខាងលើ

47 ដូចទី៤៣ខាងលើ

48 ដូចទី៤៣ខាងលើ

49 ដូចទី៤៣ខាងលើ

### ១.៥ ការជួបប្រជុំគ្នាជាសាធារណៈ

ប្រជាពលរដ្ឋកម្ពុជាក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងមកនេះ បានប្រើប្រាស់សិទ្ធិក្នុងការបញ្ចេញមតិ និងការចែករំលែកនូវមតិរបស់ពួកគេតាមរយៈការប្រមូលផ្តុំគ្នា និងជួបជុំគ្នានៅទីសាធារណៈ ដើម្បីសម្តែងនូវមតិទាំងនោះ។ ការជួបជុំជាសាធារណៈ ត្រូវបានធ្វើឡើងតាមគ្រប់រូបភាពក្នុងនោះក៏មានការធ្វើបាតុកម្មដោយសន្តិវិធី កុប្បកម្ម និងការធ្វើបាតុកម្មដោយហិង្សា។ ទន្ទឹមនឹងនេះដែរ រដ្ឋធម្មនុញ្ញរបស់ព្រះរាជាណាចក្រកម្ពុជា ក៏បានបញ្ញាត្តិនូវសិទ្ធិក្នុង ការបញ្ចេញមតិតាមរយៈការធ្វើបាតុកម្មដោយសន្តិវិធី ក៏ត្រូវបានចែងដោយរដ្ឋធម្មនុញ្ញក្នុងមាត្រា៣៧ ដែលជាហេតុធ្វើអោយប្រជាពលរដ្ឋគ្រប់រូបមានសិទ្ធិសម្តែងនូវសិទ្ធិ របស់ពួកគេស្របតាមបញ្ញាត្តិច្បាប់ដែលបានចែង[50]។ ការជួបប្រជុំគ្នា ជាមធ្យោបាយក្នុងការបញ្ចេញមតិមួយ ដែលធ្វើការចំណាយតិច ប៉ុន្តែការជួបប្រជុំនេះ មានឥទ្ធិពលយ៉ាងខ្លាំងដែលអាចធ្វើការកែប្រែ ផ្លាស់ប្តូរ និងធ្វើការរិះគន់នូវគោលនយោបាយរបស់រាជរដ្ឋាភិបាល បញ្ហាអសកម្មមួយចំនួន ដែលកើតមានក្នុងសង្គមបច្ចុប្បន្ន។ ប្រជាពលរដ្ឋកម្ពុជាភាគច្រើនតែងតែធ្វើការជួបប្រជុំគ្នា ជាលក្ខណៈខ្នាតធំ នៅទីលានប្រជាធិបតេយ្យនៅរាជធានីភ្នំពេញ ឬនៅតាមសណ្ឋាគារ ឬភោជនីយដ្ឋាននានា។ រីឯរាជរដ្ឋាភិបាលបានចូលរួមចំណែក ក្នុងការរក្សាសន្តិសុខ សណ្តាប់ធ្នាប់ និងការសំរួលចរាចរណ៍ នៅពេលដែលមានការជួបប្រជុំគ្នាជាសាធារណៈ។ ទោះជារដ្ឋធម្មនុញ្ញ បានបញ្ញាត្តិនូវមាត្រាមួយចំនួនដើម្បីការពារសិទ្ធិរបស់ពលរដ្ឋក្នុងការសម្តែងមតិក៏ពិតមែន តែការប្រើប្រាស់នូវសិទ្ធិទាំងនោះ មិនត្រូវធ្វើអោយមានការប៉ះពាល់ ឬរំខានដល់អ្នកដទៃឡើយ។ ប្រសិនបើមានការរំខាន ឬធ្វើអោយខូចខាត ដល់អ្នកដទៃ អាជ្ញាធរមានសមត្ថកិច្ច អាចមានសិទ្ធិរាំរាំង ឬបញ្ឈប់ការជួបប្រជុំនោះបាន។ ដូច្នេះសេរីភាពក្នុងការបញ្ចេញមតិនៅក្នុងប្រទេសកម្ពុជាពិតជាត្រូវពឹងផ្អែកលើមធ្យោបាយជាច្រើន ដើម្បីជំរុញអោយមានការប្រកាន់នូវលិទ្ធិប្រជាធិបតេយ្យពេញលេញ ក្នុងនោះការជួបប្រជុំគ្នានៅទីសាធារណៈ ក៏ជាមធ្យោបាយមួយក្នុងចំណោមមធ្យោបាយផ្សេងទៀត ដែលធ្វើអោយការបញ្ចេញមតិទទួលបានជោគជ័យ។ ប៉ុន្តែការប្រើប្រាស់នូវសិទ្ធិទាំងនោះមិនត្រូវប៉ះពាល់ ឬធ្វើអោយខូចខាតដល់បុគ្គលដទៃទៀតឡើយ ដែលជាហេតុធ្វើអោយមានការហាមឃាត់ ឬបញ្ឈប់នូវសកម្មភាពជួបប្រជុំនោះបាន។

## ២. ប្រព័ន្ធផ្សព្វផ្សាយបែបទំនើប

ទោះជាមានការរឹតបន្តឹងយ៉ាងធ្ងន់ធ្ងរលើប្រព័ន្ធផ្សព្វផ្សាយបោះពុម្ពផ្សាយវិទ្យុ និងទូរទស្សន៍ក៏ដោយ ប៉ុន្តែបណ្តាញសារពត៌មានប្រចាំទស្សវត្សទី២១ នេះមានសក្តានុពលក្នុងការបំបាក់រនាំងប្រពៃណី និងបើកព្រំដែនថ្មីសម្រាប់សេរីភាពបញ្ចេញមតិ។ បណ្តាសារពត៌មានទំនើប ត្រូវបានផ្តល់

[50] រដ្ឋធម្មនុញ្ញ ចុះលេខ នស/រកម/០៧០៥/០០១ នៅថ្ងៃទី២១ ខែកញ្ញា ឆ្នាំ១៩៩៣ មាត្រា៣៧

និយមន័យថា ជាទំនើបកម្មពត៌មាន ដែលទម្រង់បណ្តាញសារពត៌មាននេះហាក់ដូចជា នៅមានភាពឯករាជ្យ និងមិនស្ថិតក្រោយការគ្រប់គ្រងរបស់រដ្ឋាភិបាលប៉ុន្មាន[51] ហើយពត៌មានវិទ្យា និងទំនាក់ទំនង ត្រូវបានពីពណ៌នាថា ជាលិទ្ធិប្រជាធិបតេយ្យឌីជីថលសម័យថ្មី[52]។ ជាមួយនឹងការប្រើប្រាស់ទូរស័ព្ទដៃ ឬអ៊ីនធឺណេត អ្នកប្រើប្រាស់ អាចចែករំលែកពត៌មាន និងគំនិតយ៉ាងឆាប់រហ័ស។ បណ្តាញសារពត៌មានទំនើបផ្តល់អំណាចដល់ប្រជាពលរដ្ឋកម្ពុជា ដើម្បីអាចទទួលបានពត៌មានមានបង្ហាញពីខ្លួនគេ និងចូលរួមក្នុងការជជែកពីភាក្សាជាសាធារណៈបានយ៉ាងសកម្ម ដែលនេះមិនធ្លាប់មានពីមុនមក។ សិទ្ធិទាំងឡាយ ដែលមានសំរាប់សារពត៌មានបែបប្រពៃណីក្នុងច្បាប់កម្ពុជា ក៏គួរតែអាចអនុវត្តបានចំពោះទម្រង់បណ្តាញសារពត៌មានថ្មីមួយនេះផងដែរ។ មាត្រា១៩នៃសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងកតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ បានចែងពីសិទ្ធិសេរីភាពបញ្ចេញមតិ មិនថាតាមរយៈមធ្យោបាយណាមួយនោះទេ[53]។ មនុស្សគ្រប់រូបមានសេរីភាពក្នុងការស្រាវជ្រាវពត៌មានទទួល និងផ្សព្វផ្សាយពត៌មាន និងគំនិតសព្វបែបយ៉ាង ដោយមិនគិតពីព្រំដែនដោយផ្ទាល់មាត់ សរសេរ ឬបោះពុម្ពតាមទម្រង់សិល្បៈក្តី ឬមធ្យោបាយផ្សព្វផ្សាយដទៃទៀតក្តីតាមការជ្រើសរើសរបស់ខ្លួន។ សិទ្ធិសេរីភាពបញ្ចេញមតិតាមរយៈបណ្តាញសារពត៌មានទំនើប ត្រូវបានបញ្ជាក់បន្ថែមពេលដែល ក្រុមប្រឹក្សាសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិអនុម័តសេចក្តីប្រកាសស្តីពីការលើកកម្ពស់ ការការពារ និងលទ្ធភាពក្នុងការប្រើប្រាស់សិទ្ធិ មនុស្សនៅលើប្រព័ន្ធអ៊ីនធឺណែត។ ក្នុងអំឡុងកិច្ចប្រជុំលើកទី២០ កាលពីថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០១២ ក្រុមប្រឹក្សាសិទ្ធិមនុស្ស បានអះអាងថាប្រជាពលរដ្ឋគ្រប់រូបមានសិទ្ធិដូចគ្នា មិនថាជានៅលើប្រពន្ធអ៊ីនធឺណេត ឬក្រៅប្រព័ន្ធអ៊ីនធឺណេតនោះទេ។ សេចក្តីប្រកាសនេះ ចែងថា ការប្រើប្រាស់សិទ្ធិមនុស្ស ជាពិសេសសិទ្ធិសេរីភាពបញ្ចេញមតិនៅលើប្រព័ន្ធអ៊ីនធឺណេត ជាការ

---

[51] មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជាស្តីពីទិវាសេរីភាពសារពត៌មានទស្សវត្សរ៍ទី២១៖ ព្រំដែនថ្មី និងរបាំងចាស់មកលើសេរីភាពបញ្ចេញមតិនៅកម្ពុជា (២០១១) http://www.cchrcambodia.org/admin/media/analysis/english/CCHR_Briefing_Note.pdf (ថតចម្លងថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៦)

[52] ចក់ សុភាព, *លទ្ធិប្រជាធិបតេយ្យឌីជីថលកើនឡើងនៅក្នុងប្រទេសកម្ពុជា (ភ្នំពេញ, ២០១១)* http://sopheapfocus.com/index.php/2009/11/digital-democracy-emerging-in-cambodia/ (ថតចម្លងថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៦)

[53] កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ អនុម័តថ្ងៃទី១៦ ខែធ្នូ ឆ្នាំ១៩៦៦ ចូលជាធរមានថ្ងៃទី២៣ ខែមិនា ឆ្នាំ១៩៧៦ http://treaties.un.org/Pages/ViewsDetails.aspx?src=TREATY&mtdg_no=IV-4&chapter=4&lang=en (ថតចម្លងថ្ងៃទី០១ ខែឧសភា ឆ្នាំ២០១៦)

បង្កើនផលប្រយោជន៍ និងសារៈសំខាន់ដោយសារតែល្បឿននៃការអភិវឌ្ឍបច្ចេកវិទ្យាអាចអោយបុគ្គលទាំងអស់លើពិភពលោកប្រើប្រាស់នូវបច្ចេកវិទ្យាពត៌មាន និងទំនាក់ទំនងថ្មីៗ[54]។

## ២.១ ប្រើប្រាស់បណ្តាញសង្គមសារពត៌មានទំនើប ជាឧបករណ៍ការពារ និងលើកម្ពស់សិទ្ធិ

ការប្រើប្រាស់បណ្តាញសារពិមានទំនើប បានក្លាយជាវិធីដ៏មានតម្លៃជាខ្លាំងក្នុងការការពារ និងលើកកម្ពស់សិទ្ធិមនុស្សនៅកម្ពុជា។ ទូរស័ទ្ទដៃ និងបច្ចេកវិទ្យាអ៊ីនធឺណេតបានបង្កើតលំហាថ្មីមួយសំរាប់ការពិភាក្សា និងរិះគន់លើរដ្ឋាភិបាល និងស្ថានភាពជដែល។ ដែលការធ្វើបែបនេះនឹងមិនអាចធ្វើទៅបានទេក្នុងទម្រង់សារពត៌មានបោះពុម្ពផ្សាយ វិទ្យុ និងទូរទស្សន៍។

### ២.១.១. ទូរស័ព្ទដៃ

សេវាផ្ញើសារជាអក្សរ បានក្លាយជាវិធីដ៏មានប្រជាប្រិយក្នុងវិស័យទំនាក់ទំនងនៅកម្ពុជា។ ដោយសារតែលទ្ធភាពប្រើប្រាស់ទូរស័ព្ទដៃមានច្រើន បច្ចេកវិទ្យាសារជាអក្សរ ក៏ថែមទាំងត្រូវបានប្រជាពលរដ្ឋ ដែលរស់នៅក្នុងតំបន់ជនបទ និងដាច់ស្រយាលបំផុតនៅកម្ពុជាប្រើប្រាស់ផងដែរ។ ដូចនេះ ការប្រើសារជាអក្សរ ជាឧបករណ៍តស៊ូមតិផ្នែក សិទ្ធិមនុស្ស ដែលមិនអាចខ្វះបានហើយ វាក៏អាចលើកកម្ពស់ និងការពារសិទ្ធិមនុស្សតាមរយៈការថតរូប និងវីដេអូ។

### ២.១.២. អ៊ីនធឺណេត (Internet)

ប្រព័ន្ធអ៊ីនធឺណេត ក៏ផ្តល់អោយអ្នកប្រើប្រាស់នូវចំណេះដឹង និងធនធានដោយឥតគិតថ្លៃជាច្រើនសន្ធឹកសន្ធាប់។ ភ្នាក់ងារសារពត៌មានបោះពុម្ពផ្សាយជាច្រើន ក៏បានបង្កើតវែបសាយរបស់ខ្លួនផងដែរ។ ឧទាហរណ៍ មនសិកាខ្មែរ និងភ្នំពេញប៉ុស្ត៍ ភ្នាក់ងារសារពត៌មានទាំងអស់មានវែបសាយ ដែលអនុញ្ញាតអោយអ្នកអាចចូលអានអត្ថបទ និងមើលវីដេអូដោយឥតគិតថ្លៃ។ ប្រជាពលរដ្ឋ កម្ពុជាភាគច្រើនរស់នៅតំបន់ជនបទ ហើយការចែកចាយកាសែត គឺប្រមូលផ្តុំតែនៅទីប្រជុំជន។ តាមរយៈការកើនឡើងនៃលទ្ធភាពប្រើប្រាស់អ៊ីនធឺណេត អ្នកអានសារពត៌មានបែបប្រពៃណី ដែលពិបាកក្នុងការរកពត៌មាននោះនឹងអាចទទួលបានពត៌មាន។ បន្ថែមលើនោះបាតុភូតមួយនេះ ក៏មានកើតឡើងចំពោះវិទ្យុផងដែរ ដូចជាស្ថានីយ៍វិទ្យុសំបុកឃ្មុំ សម្លេងប្រជាធិបតេយ្យ សម្លេងសង្គមស៊ីវិល ក៏អាចស្តាប់តាមប្រព័ន្ធអ៊ីនធឺណេតបានដែរ។

### ២.១.៣. គេហទិនានុលេខន៍ (ប្លុក ឬ Block)

ប្លុកប្រៀបដូចជាកំណត់ហេតុលើប្រព័ន្ធអ៊ីនធឺណេត ដែលបុគ្គលម្នាក់ៗអាចសរសេរពីអ្វីក៏ដោយដែលខ្លួនសរសេរដូចជា បទពិសោធន៍ផ្ទាល់ខ្លួន ឬរឿងនយោបាយ ឬមតិយោបល់បែបអ្នក

---

[54] ក្រុមប្រឹក្សាសិទ្ធិមនុស្សអង្គការសហប្រជាជាត, ការលើកម្ពស់ ការការពារ និងការរីករាយក្នុងការទទួលសិទ្ធិមនុស្សលើប្រព័ន្ធអ៊ីនធឺណេត (កិច្ចប្រជុំទី២០ មិថុនា ២០១២) http://www.regeringen.se/content/1/c6/19/64/51/6999c512.pdf (ថតចម្លងថ្ងៃទី០៣ ខែឧសភា ឆ្នាំ២១០៦)

ប្រាជ្ញលើប្រធានបទ និងបញ្ហាផ្សេងៗជាច្រើន[55]។ ប្លុក អាចមានជាច្រើនរូបរាង និងទម្រង់ ប៉ុន្តែជាធម្មតាគឺគ្រាន់តែជាវែបសាយ ដែលអ្នកសរសេរប្លុកនីមួយបន្ទាន់សម័យជាទៀងទាត់។ ប្លុកក្លាយអាចទៅជាវិធី ដែលងាយស្រួល និងអាចលៃលកប្រើប្រាស់ បានដើម្បីអោយពលរដ្ឋកម្ពុជាបញ្ចេញមតិ ដែលជាទូទៅ អាននឹងត្រូវគាបសង្កត់ក្នុងពិភពសារពត៌មានប្រពៃណី។ វែបសាយដូចជា http://www.blogger.com និង http://www.wordpress.com អនុញ្ញាតអោយមនុស្សទូទៅបង្កើតប្លុកដោយខ្លួនគេផ្ទាល់ដោយមិនចាំបាច់ត្រូវចំណាយប្រាក់។ ក្នុងឆ្នាំ២០០៧ សារពត៌មាន ខឺ ខែមបូឌា ដេលី ប៉ាន់ស្មានថា ប្រទេសកម្ពុជា មានប្លុកប្រហែលជាចំនួន ២០៥០។ ប៉ុន្តែដោយសារតែចំនួនការប្រើប្រាស់អ៊ីនធឺណេត មានការកើនឡើងជាច្រើន ដូច្នេះអាចនឹងប៉ាន់ស្មាថាចំនួន ប្លុកមានច្រើនជាងនេះ[56]។ ដោយកត់សំគាល់ពីការកើនឡើងនៃអ្នកសរសេរប្លុកកម្ពុជា កម្ពុជាបានក្លាយជាប្រទេសម្ចាស់ផ្ទះ ដែលបានរៀបចំកម្មវិធី ប្លុកហ្វេសអាស៊ីក្នុងខេត្តសៀមរាប។ ទិវាគេហទិនានុលេខន៍ (ប្លុក) អាស៊ី គឺជាកម្មវិធីប្រមូលផ្តុំអ្នករសេរប្លុកទូទាំងតំបន់ ដើម្បីពិភាក្សាពីបទពិសោធន៍នៃការសរសេរប្លុក គំនិត បច្ចេកវិទ្យាផ្សេងៗជាដើម[57]។ អ្នកសរសេរប្លុកកម្ពុជាច្រើន ប្រើប្រាស់ប្លុកដើម្បីអនុវត្តសិទ្ធិសេរីភាពបញ្ចេញមតិ ដែលក្នុងសារពត៌មានបែបប្រពៃណី ត្រូវបានរឹតត្បិតដោយរដ្ឋាភិបាល។

ទោះបីជាប្លុក មានច្រើនប្រភេទ ដែលអាចប្រើប្រាស់សំរាប់ការតស៊ូមតិផ្នែកនយោបាយ ប្លុករៀបរាប់ពីវិវត្តិ និងការដាក់ញត្តិតាមប្រព័ន្ធអ៊ីនធឺណេត ជាវិធីធម្មតាបំផុតដែលត្រូវបានប្រើប្រាស់ដើម្បីសរសេរពីបញ្ហាជាក់លាក់។ នៅកម្ពុជាប្លុក រៀបរាប់ពីវិបត្តិ ដ៏ល្បីឈ្មោះ គឺប្លុក "រក្សាបឹងកក់" ដែលបុគ្គលឯកជនជាអ្នកមើលថែប្លុកមួយនោះ។ ប្លុកនោះផ្ទាល់បានធ្វើការបច្ចុប្បន្នភាពស្តីពីការអភិវឌ្ឍន៍នៅតំបន់បឹងកក់ ក្នុងទីក្រុងភ្នំពេញ ដែលរយៈពេលថ្មីៗនេះក្លាយទៅជាវែបសាយ ដែលនិយាយពីការបណ្តេញចេញដោយបង្ខំជាច្រើន ដែលបានកើតឡើង ប្លុកនេះថែមទាំងបានស្នើសុំអោយអ្នកអានចុះអត្តលេខលើញត្តិ ដើម្បីទាមទារប្រាក់សំណងសំរាប់ជនរងគ្រោះនៃការបណ្តេញចេញដោយបង្ខំ និងដើម្បីបញ្ឈប់រំលោភបំពានលើសិទ្ធិដីធ្លី ដែលកើតមានជាបន្តបន្ទាប់។ បន្ថែមពីលើប្លុកមានវិបត្តិញត្តិអ៊ីនធឺណេតក៏ត្រូវបានប្រើប្រាស់ជាមធ្យោបាយ ដើម្បីដោះស្រាយ

---

[55] http:/www.blogger.com/tour_start.g (ចូលទស្សនាថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០១៦)

[56] មជ្ឈមណ្ឌលសិទ្ធិមនុស្ស, បណ្តាញសារពត៌មានទំនើប និងការលើកកម្ពស់សិទ្ធិមនុស្សនៅកម្ពុជា (របាយការណ៍,២០១២), ថតចម្លងថ្ងៃទី០២ ខែឧសភា ឆ្នាំ២០១៤

[57] លីហ្សា គីម, អ្នកសរសេរប្លុកពិភាក្សាពីសេរីភាពអ៊ីនធឺណេតនៅប្លុកហ្វេសអាស៊ីឆ្នាំ២០១២ នៅកម្ពុជា (កម្មវិធីប្លុកហ្វេសអាស៊ី, ២០១២)
http://2012.blogfest.asia/ (ថតចម្លងថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០១៦)

ជាមួយ និងការរំលោភបំពានសិទ្ធិមនុស្ស និងបានទទួលជោគជ័យ ពិសេសក្នុងការទាក់ទាញចំណាប់អារម្មណ៍ពីសហាគមន៍នៅលើប្រព័ន្ធអ៊ីនធឺណេត។

**២.១.៤. ហ្វេសប៊ុក (facebook)**

មកដល់ខែមេសា ឆ្នាំ២០១៣ កម្ពុជាមានចំនួនអ្នកប្រើប្រាស់ហ្វេសប៊ុក ដែលសកម្មប្រចាំខែចំនួន៧៥២,៨២០នាក់[58]។ យោងតាមការប៉ាន់ស្មានរបស់ភ្នាក់ងារផ្សាយពាណិជ្ជកម្ម និងទីផ្សារផ្នែកបណ្តាញសង្គម មីដៀ ប្លាស់ កម្ពុជាបានចំនួនអ្នកប្រើប្រាស់ហ្វេសប៊ុកថ្មីចំនួនប្រហែល ជា ១១០០ ក្នុងមួយថ្ងៃ[59]។ ប៉ុន្តែតួលេខទាំងនេះរួមបញ្ចូលទាំងជនជាតិ បរទេសរស់នៅកម្ពុជា ប្រជាពលរដ្ឋធម្មតាផងដែរ និងក្រុមអង្គការ ដែលបានបង្កើតគណនីហ្វេសប៊ុកផងដែរ[60]។ ស្របពេល ដែលជាទូទៅហ្វេសប៊ុកត្រូវបានប្រើ ដើម្បីធ្វើទំនាក់ទំនង ប៉ុន្តែហ្វេសប៊ុកក៏បានក្លាយជាមធ្យោបាយក៏មានប្រជាប្រិយ ដើម្បីធ្វើការតស៊ូមតិក្នុងសង្គមផងដែរ។ អង្គការសិទ្ធិមនុស្ស និងភ្នាក់ងារពត៌មានប្រើប្រាស់ហ្វេសប៊ុក ដើម្បីជាវិធីចែកចាយពត៌មានដោយសេរី ហើយមនុស្សជាច្រើន បានបង្កើតគេហទំព័រហ្វេសប៊ុកសំរាប់ខ្លួនគេផ្ទាល់។

**២.១.៥. ធ្វីតទ័រ (Twitter)**

ធ្វីតទ័រ ក៏ដូចជាហ្វេសប៊ុកផងដែរ ជាបណ្តាញសារពត៌មានសង្គម ដែលប្រើប្រាស់ដោយបុគ្គល ដើម្បីចែករំលែកពត៌មាន និងពិភាក្សាគំនិត។ ការទំនាក់ទំនងកើតមានឡើងតាមរយៈការដោះដូរសារខ្លីៗ និងរហ័ស ត្រូវបានគេស្គាល់ថាជាធ្វីតមាន១៤៩ តួអក្សរ ឬតិចជាងនេះ។ ក្នុងប្រទេស ដែលមានសម្បូរទូរស័ព្ទដៃដូចជា កម្ពុជាធ្វីតទ័រ គឺជាវិធីសំរាប់ធ្វើទំនាក់ទំនង ហើយការកើនឡើងនៃការប្រើប្រាស់របស់វា គឺអាចនឹងកើតឡើង ក្នុងរយៈពេលប៉ុន្មានឆ្នាំខាងមុខទៀត។ ទោះបីជាមិនមានស្ថិត ដែលបង្ហាញពីចំនួនអ្នកប្រើប្រាស់ធ្វីតទ័រពិតប្រាកដនៅកម្ពុជាក៏ដោយ[61]

---

[58] សូស៊ិល បេិកគ័រ, http://www.socialbakers.com/facebook-statistics/cambodia, ថតចម្លងថ្ងៃទី០២ ខែឧសភា ឆ្នាំ២០១៦

[59] ដានីញ៉េល ដឺ ខាធឺរេត, អាជីវកម្មនៅកម្ពុជាចាប់ផ្តើមប្រើប្រាស់ការផ្សព្វផ្សាយនៅលើហ្វេសប៊ុក (សារពត៌មាន ឌឹ ភ្នំពេញប៉ុស្ត៍,២០១៣) http://www.phnompenhpost.com/2013021261301/Business/cambodia-business-embrace-facebook-advertising.html (ថតចម្លងថ្ងៃទី០២ ខែឧសភា ឆ្នាំ២០១៦)

[60] ពេជ្រ សំណាង, បណ្តាញសង្គមនៅទីនោះមានលក្ខណៈបែបសង្គមច្រើនជាងនយោបាយ (វិទ្យុសំឡេងសហរដ្ឋអាមេរិក, ២០១១) http://www.voacambodia.com/content/social-media-here-more-social-than-political-researcher-116817728/1356907.html (ថតចម្លងថ្ងៃទី០២ ខែឧសភា ឆ្នាំ២០១៦)

[61] សារពត៌មានឌីជីថលនៅកម្ពុជា (សាកលវិទ្យាល័យសិង្ហបុរី)

ភស្តុតាងបានបង្ហាញថា ទំព័រធ្វីតទ័ររបស់ភ្នាក់ងារពត៌មានទទួលបានចំនួនអ្នកតាមច្រើនជាងរបស់អង្គការ ឧទាហរណ៍ វិទ្យុ វីអូអេ មានអ្នកតាមចំនួន ២៦,៥១៨លាននាក់ ដែលអង្គការភាគច្រើនមានរវាងពី ៥០ ទៅ ៥០០ នាក់។ ទោះបីជាបើប្រៀបធៀបទៅនឹងហ្វេសប៊ុក ធ្វីតទ័រ មានចំនួនអ្នកប្រើតិចជាងក៏ដោយ ប៉ុន្តែក៏មានការប្រើប្រាស់ធ្វីតទ័ររបស់ក្រុមប្រជាពលរដ្ឋកម្ពុជា ដើម្បីធ្វីតពីព្រឹត្តិការណ៍សំខាន់ៗ រួមបញ្ចូលទាំងព្រឹត្តិការណ៍ការផ្អើលរត់ជាន់គ្នា នៅលើស្ពានកោះពេជ្រក្នុងអំឡុងពិធីបុណ្យអុំទូក ឆ្នាំ២០១០[62] និងលទ្ធផលនៃការបោះឆ្នោតឆ្នាំ២០១៣។ អង្គការសិទ្ធិមនុស្សជាច្រើននៅកម្ពុជាក៏បានប្រើប្រាស់ធ្វីតទ័រ ដើម្បីចែកចាយពត៌មានសំខាន់ៗទៅកាន់សាធារណជនផងដែរ។ បន្ថែមពីលើនេះធ្វីតទ័រ ក៏ត្រូវបានប្រើប្រាស់ជាមធ្យោបាយការទូត ដើម្បីបន្ថយភាពតានតឹងពាក់ព័ន្ធនឹងរឿងជម្លោះព្រំដែនរវាងប្រទេសកម្ពុជា និងប្រទេសថៃផងដែរ[63]។ ធ្វីត ត្រូវបានផ្ញើរចេញដោយបុគ្គល ជាសញ្ញាបង្ហាញពីការចង់បានសន្តិភាព ជាឧទារហណ៍ ក្នុងឆ្នាំ២០១១ រដ្ឋមន្ត្រីក្រសួងការបរទេសប្រទេសថៃបានអំពាវនាវអោយមានសន្តិភាពរវាងប្រទេសទាំងពីរ[64]។

### ២.២. លទ្ធភាពប្រើប្រាស់ទូរស័ព្ទដៃ និងប្រព័ន្ធអ៊ីនធឺណេតនៅកម្ពុជា

ប្រទេសកម្ពុជា គឺជាប្រទេសដំបូងក្នុងពិភពលោក ដែលមានទូរស័ព្ទដៃច្រើនជាងទូរស័ព្ទខ្សែ[65]។ ទូរស័ព្ទដៃ បានក្លាយជាវិធីក៏ងាយស្រួល និងមានតម្លៃសមរម្យសំរាប់ ប្រជាពលរដ្ឋនៅកម្ពុជា ដើម្បីធ្វើការទំនាក់ទំនង។ ដល់ចុងឆ្នាំ២០១២ ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

---

http://wiki.smu.edu.sg/digitalmediaasia/Digital_Media_in_Cambodia#Twitter (ថតចម្លងថ្ងៃទី០២ ខែឧសភា ឆ្នាំ២០១៦

[62] មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា, *បណ្តាញសារពត៌មានទំនើប និងការលើកកម្ពស់សិទ្ធិមនុស្សនៅកម្ពុជា* (របាយការណ៍,២០១២ http:/cchrcambodia.org/index_old.php?url=media/media.php&p=reprot_detail.php&reid=79&id=5 (ថតចម្លងថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០១៦)

[63] គ្រីមីណា គ្រូម្ភ៉ា, *ជម្លោះកម្ពុជា ថៃ មិនបញ្ចប់នៅត្រង់ព្រំដែន* (អេដ្ធូច ថាមស៍, ២០១១) http://www.cchrcambodia.org/media/flies/news/227_tccdneatbwet_en.pdf (ថតចម្លងថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០១៦)

[64] មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា, *បណ្តាញសារពត៌មានទំនើប និងការលើកកម្ពស់សិទ្ធិមនុស្សនៅកម្ពុជា* (របាយការណ៍,២០១២ http:/cchrcambodia.org/index_old.php?url=media/media.php&p=reprot_detail.php&reid=79&id=5 (ថតចម្លងថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០១៦)

[65] មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជាស្តីពីសារពត៌មានទំនើប និងការលើកកម្ពស់សិទ្ធិមនុស្សនៅកម្ពុជា (ភ្នំពេញ, ២០១២) http://www.cchrcambodia.org/admin/media/report/english/2012_17_24_New_Media_and_the_Promotion_of_Human_Right_in_Cambodia_ENG.pdf (ថតចម្លងថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០១៦)

រាយការណ៍ថា ចំនួនចុះឈ្មោះប្រើទូរស័ទ្វដៃ បានកើនឡើងច្រើនជាង ២០លាន។ ដោយសារតែចំនួនប្រជាពលរដ្ឋមានត្រឹមតែ១៥លាននាក់ ចំនួនការប្រើប្រាស់ទូរស័ទ្វដៃជាមធ្យម គឺមនុស្សម្នាក់ប្រើ១.៣ទូរស័ព្ទ[66]។ ដូចនេះ ស្ទើរតែ១០០ភាគរយ នៃអ្នកប្រើប្រាស់មានទូរស័ព្ទទំនើបប្រើ[67]។ ផ្ទុយនឹងលទ្ធភាពប្រើប្រាស់ទូរស័ព្ទដៃរបស់ប្រទេសកម្ពុជា ដែលកំពុងតែកើនឡើង ប្រទេសកម្ពុជាបែរជាមានអ្នកប្រើប្រាស់អ៊ីនធឺណេតទាបបំផុតក្នុងអាស៊ីអាគ្នេយ៍។ ប៉ុន្តែ ចំនួនអ្នកប្រើប្រាស់អ៊ីនធឺណេតរបស់ប្រទេសកម្ពុជាកើនឡើងយ៉ាងឆាប់រហ័ស។ ក្នុងខែធ្នូ ឆ្នាំ២០១២ ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ប៉ាន់ស្មានថាចំនួនអ្នកប្រើប្រាស់នៅកម្ពុជា មាន២.៧លាននាក់ស្មើនឹង១៧ ភាគរយនៃចំនួនប្រជាពលរដ្ឋសរុប[68]។ ខណៈពេលភាពត្រឹមត្រូវនៃការប៉ាន់ស្មាននៅតែជាប្រធានបទនៃការជជែកពិភាក្សា ប៉ុន្តែមិនមានការសង្ស័យអំពីការកើនឡើងនៃភាពឈានមុខផ្នែកបច្ចេកវិទ្យាក្នុងពេលបច្ចុប្បន្ននោះទេ ដោយសារក្រុមហ៊ុនផ្គត់ផ្គង់សេវាអ៊ីនធឺណេត ធ្វើអោយអ៊ីធឺណេតមានតម្លៃសមរម្យ ដើម្បីអាចអោយអតិថិជនប្រើប្រាស់បាន។ យោងតាមសម្តីរបស់អ្នកគ្រប់គ្រងផ្នែកលក់នៃក្រុមហ៊ុនផ្តល់សេវាអ៊ីនធឺណេតអូផិនណេត (OpenNet) អ្នកប្រើតាមផ្ទះអាចទទួលបានសេវាកម្មអ៊ីនធឺណេតលឿន ដោយចាប់ផ្តើមពីតមលៃ១២ដុល្លាសហរដ្ឋអាមេរិកក្នុងមួយខែ។ តម្លៃនេះ មិនអាចទៅរួចទេ បើគិតត្រលប់ទៅឆ្នាំ ២០១១ ដែលពេលនោះ ទិន្ន័យរបស់ធនាគារពិភពលោក បង្ហាញត្រឹមតែ៣.១ភាគរយនៃចំនួនប្រជាពលរដ្ឋកម្ពុជាសរុបមានលទ្ធភាពប្រើប្រាស់អ៊ីនធឺណេត។ បន្ថែមពីលើនេះ ក៏មានជម្រើសជាច្រើនសំរាប់អ្នក ដែលមិនមានកុំព្យូទ័រផ្ទាល់ខ្លួន។ ទីក្រុងភ្នំពេញ មានហាងអ៊ីនធឺណេតកាហ្វេច្រើនជាង៣០០កន្លែង និងការ

---

[66] អែន រ៉ែសប៊ែនប្រ៊ីង, ជម្រើសការវិនិយោគសម្រាប់ទូរគមនាគមន៍កម្ពុជា (សារពត៌មាន ឌឹ ភ្នំពេញ, ២០១២) http://www.phnompenhpst.com/2013022061463/Business/investment-options-for-cambodian-telcos,html (ថតចម្លងថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០១៦)

[67] អ៊ឹម សុធារិទ្ធិ, បណ្តាញសារពត៌មានសង្គមផ្លាស់ប្តូរទិដ្ឋភាពឌីជីថលនីកម្ពុជា (វិទ្យុសំលេងសហរដ្ឋអាមេរិក, ២០១២) http://voacambodia.com/content/cambodia-social-media-changing-cambodian-information-landscape/1571656.html%6c (ថតចម្លងថ្ងៃទី០៦ ខែឧសភា ឆ្នាំ២០១៦)

[68] អង្គការលើកកម្ពស់ពាណិជ្ជកម្ម និងការិនិយោគ,ការបង្កើតទូរស័ព្ទខ្សែ ទូរស័ព្ទដៃ និងអ៊ីនធឺណេត (ស្ថានទូតព្រះរាជាណាចក្រកម្ពុជាទីក្រុងឡុងដ៍, ២០១៣) http://cambodianembassy.org.uk/indes_main.php?lang=&kc=0&mct=0&menu=0&k=0&menu1=0&menu2=&menu3=&link=olink1=0&locate=&page=&topic=Telecoms&topic_cat=Business&readmore=3 (ថតចម្លងថ្ងៃទី០៦ ខែឧសភា ឆ្នាំ២០១៦)

ប្រើប្រាស់ ឧបករណ៍បច្ចេកវិទ្យា ដែលមានការកើនឡើងដូចជា ទូរស័ព្ទទំនើបនិង Tablets ក្លាយទៅជាវិធីថ្មីមួយសំរាប់ប្រើប្រាស់អ៊ីនធឺណេត[69]។

**ផ្នែកទី៣៖ មូលដ្ឋានគ្រឹះនៃការនិយាយជាសាធារណៈ**[70]

**១. និយមន័យនៃការនិយាយ**

**តើការនិយាយជាអ្វី**?

- គឺជាការស្តែងចេញនៃការប្រើភាសា។
- គឺជាការបង្ហាញនូវអារម្មណ៍ ជាដំណើរការនៃទំនាក់ទំនងរវាងមនុស្សទៅមនុស្ស ម្នាក់ ឬមនុស្សមួយក្រុមដែលមានភាសា សំឡេង និងអាកប្បកិរិយាជាប្រព័ន្ធទំនាក់ទំនង។
- គឺជាឧបករណ៍ទំនាក់ទំនងដែលមានអានុភាពខ្លាំងបំផុតក្នុងលោក។
- គឺជានិមិត្តសញ្ញានៃការយល់រវាងមនុស្ស និងមនុស្ស។
- គឺជាដំណើរការផ្ទេរនូវការយល់ឃើញ និងទិន្នន័យផ្សេងៗឱ្យដល់អ្នកស្តាប់។
- គឺជាសកម្មភាពរួមគ្នានឹងការស្តាប់ ដែលជាប្រតិកម្មតប ហើយដើម្បីឱ្យបានលទ្ធផលល្អជាទីពេញចិត្តនោះ គួរមានគោលការណ៍ និងសិល្បៈប្រកបផង។
- គឺជាក្លោងទ្វារឆ្ពោះទៅរកភាពជោគជ័យ ឬបរាជ័យ។
- គឺជាវត្ថុមានសារៈសំខាន់ក្នុងជីវិត។ ការនិយាយដែលល្អ នឹងធ្វើឱ្យការទាក់ទង ការពិភាក្សា ឬការបញ្ចេញយោបល់បានជោគជ័យ។
- គឺជាធាតុសំខាន់ក្នុងការទាក់ទងគ្នាផ្សេងៗ តាមការពិតអ្នកណាក៏អាចនិយាយបានដែរ។ ប៉ុន្តែពេលដែលនិយាយហើយ តើនឹងបានលទ្ធផលយ៉ាងណា? តើជាទីគាប់ចិត្តដែរឬទេ? ទើបជាកត្តាសំខាន់ការនិយាយបានល្អ និងនិយាយឱ្យអ្នកដទៃដឹងពីគោលបំណងអ្នកនិយាយនោះ មិនមែនជារឿងដែលបានដោយងាយៗនោះទេ។

**២. គោលបំណងនៃការនិយាយ**[71]

យើងអាចចែកគោលបំណងនៃការនិយាយជា៧ចំណុចគឺ:

- ដើម្បីបង្កើតចំណេះដឹង
- ដើម្បីធ្វើឱ្យមានការយោគយល់រវាងគ្នា និងគ្នា
- ដើម្បីបញ្ចេញទុក្ខកង្វល់ក្នុងចិត្ត ធ្វើឱ្យមានអារម្មណ៍ធូរស្រាល

---

[69] ស៊ុយ ហ៊ាមខេមរា, ទិន្នន័យតម្លៃថោក បច្ចេកវិទ្យាល្អជាងមុន ធ្វើឱ្យប្រជាពលរដ្ឋកម្ពុជាជាច្រើនអាចប្រើប្រាស់អ៊ីនធឺណេត (វិទ្យុសំឡេងសហរដ្ឋអាមេរិក, ២០១៣) http://www.voacambodia.com/content/cheap-data-better-tech-putting-more-cambodians-online/1624617.html (ថតចម្លងថ្ងៃទី០៦ ខែឧសភា ឆ្នាំ២០១៦)

[70] សាស្ត្រាចារ្យ សំ សារិន, នីតិសេរីភាពសាធារណៈ: (២០១៤-២០១៥)

[71] សាស្ត្រាចារ្យ សំ សារិន, នីតិសេរីភាពសាធារណៈ: (២០១៤-២០១៥

- ដើម្បីធ្វើឱ្យមានការសប្បាយរីករាយ
- ដើម្បីបើកឪកាសឱ្យអ្នកស្តាប់
- ដើម្បីលួងលោង និងទាក់ទាញទឹកចិត្ត
- ដើម្បីធ្វើឱ្យអ្នកស្តាប់មានទំនុកចិត្តជឿជាក់ ហើយផ្លាស់ប្តូរទស្សនៈរបស់ខ្លួន។

**៣. ប្រភេទនៃការនិយាយ**[72]

ការនិយាយ អាចបែងចែកជាពីរប្រភេទ គឺជាការនិយាយម្នាក់ឯង និងការនិយាយជាក្រុមៈ

- ការនិយាយម្នាក់ឯងៈ អ្នកនិយាយត្រូវនិយាយម្នាក់ឯង អាចនៅក្នុងថ្នាក់រៀន ឬនៅក្នុងអង្គប្រជុំ។ អ្នកនិយាយ អាចនិយាយពីការនិទានរឿង ការរាយការណ៍ការអធិប្បាយបច្ចេកវិទ្យា ការឃោសនា ឬការបញ្ចេញមតិយោបល់ផ្សេងៗ។
- ការនិយាយជាក្រុមៈ អ្នកនិយាយ ត្រូវនិយាយម្តងម្នាក់ៗ គឺការសន្ទនាសំដែងនូវការយល់ឃើញ រួមគ្នា ឬជជែកវែកញែក។ រឿង ដែលគួរយកមកហ្វឹកហាត់និយាយមកពីបទពិសោធន៍ ឬហេតុការណ៍ ដែលធ្លាប់បានឃើញ បានស្តាប់ បានអាន បានសាកសួរអ្នកចេះ ឬបានស្រាវជ្រាវពីមុនមក។

**៤. ធាតុសំខាន់ៗក្នុងការនិយាយ**[73]

យើងអាចចែកធាតុសំខាន់ក្នុងការនិយាយជាបីផ្នែក គឺអ្នកនិយាយ អ្នកស្តាប់ និងរឿងដែលត្រូវនិយាយៈ

អ្នកនិយាយៈ ជាសារធាតុមួយដ៏សំខាន់ជាទីបំផុតក្នុងការនិយាយ។ មុននឹងចាប់ផ្តើមនិយាយ អ្នកនិយាយ ត្រូវតែត្រៀមលក្ខណៈសម្បត្តិឱ្យបានរួចជាស្រេចជាមុនសិន។ លក្ខណៈសម្បត្តិ ដែលត្រូវត្រៀមពេលនិយាយគឺៈ

- ✓ អត្តចរិតៈ ត្រូវស្លៀកពាក់ឱ្យបានសមរម្យទៅនឹងទីកន្លែង។ កាយវិការ ទឹកមុខ ឬការធ្វើចលនា គួរឱ្យទៅតាមធម្មជាតិ ហើយត្រូវសម្លឹងមុខអ្នកស្តាប់ជានិច្ច តែមិនត្រូវញាក់មុខញាក់មាត់ឡើយ។
- ✓ ការប្រើសំឡេងៈ សំឡេងមានសារៈសំខាន់ណាស់ក្នុងការនិយាយ។ គួរនិយាយឱ្យបានច្បាស់ៗមិនរអាក់រអួរ ហើយត្រូវតែនិយាយឱ្យអ្នកស្តាប់បានឮច្បាស់គ្រប់គ្នា ដើម្បីឱ្យងាយស្រួលក្នុងការតាមដានស្តាប់។ ប៉ុន្តែមិនគួរឱ្យខ្លាំង ឬតិចពេកទេ ហើយក៏មិន គួរឱ្យយឺតពេកដែរ ឬលឿនពេកដែរ។ គួរព្យាយាមធ្វើដូចសំឡេងនិយាយ កុំឱ្យដូចសំឡេងអានសូត្រ ឬទេសនាឱ្យសោះ។ ត្រូវចេះលើកដាក់សំឡេងឈប់សម្រាក ដកដង្ហើម និងនិយាយសង្ខួនប្រយោគណា ដែលសំខាន់ ប៉ុន្តែមិនត្រូវនិយាយច្រំដែលច្រើនពេកទេ។

[72] សាស្ត្រាចារ្យ សំ សារិន, នីតិសេរីភាពសាធារណៈ (២០១៤-២០១៥

[73] សាស្ត្រាចារ្យ សំ សារិន, នីតិសេរីភាពសាធារណៈ (២០១៤-២០១៥

- ✓ ភាសាដែលប្រើ: គួរប្រើពាក្យពេជន៍ ដែលសាមញ្ញងាយយល់។ គួរប្រើវិធីសន្ទនា តែបើសិនអ្នកស្តាប់មានច្រើនគួរប្រើវិធីថ្លែងការ។ អ្នកស្តាប់ប្រៀប បានដូចជាឧបករណ៍ដ៏មានប្រសិទ្ធភាពល្អវិសេសណាស់ សម្រាប់វាស់សមត្ថភាពរបស់អ្នកនិយាយ។ នៅចំពោះមុខអ្នកស្តាប់ ដែលមានច្រើននាក់ អ្នកនិយាយគួរដឹងពីពត៌មានលំអិតស្តីពីចំនួន អាជីព អាយុ ភេទ កម្រិតវប្បធម៌ រហូតដល់ការយកចិត្តទុកដាក់ស្តាប់របស់អ្នកស្តាប់ជាមុនសិន។ អ្នកនិយាយគួរសិក្សាអំពីធម្មជាតិរបស់អ្នកស្តាប់ ហើយព្យាយាមដោះស្រាយបញ្ហា ឬហេតុការណ៍ចំពោះមុខឱ្យទាន់ពេលវេលា។
- ✓ រឿងដែលត្រូវនិយាយ: ការត្រៀមរឿងនិយាយ ក៏ដូចជាការតែងសេចក្តីដែរ គឺត្រូវមានសេចក្តីផ្តើម តួសេចក្តី និងសេចក្តីបញ្ចប់។

### ៥. ចរិយាក្នុងការនិយាយ[74]

ការនិយាយ ត្រូវមានចិត្តសាស្ត្រ ត្រូវរំពឹងគិតដល់ទំនោរចិត្ត និងត្រូវការរបស់អ្នកស្តាប់ ហើយត្រូវប្តូររឿងនិយាយ កាលណាបើឃើញថាអ្នកស្តាប់ ឬគូសន្ទនាមិនយកចិត្តទុកដាក់ស្តាប់។ តាមគោលការណ៍ចិត្តសាស្ត្រណែនាំអំពីរឿងនេះដូចតទៅ:

- ➢ ព្យាយាមជៀសវាងការនិយាយរឿងផ្ទាល់ខ្លួនដូចជា រឿងកូន ប្តី ប្រពន្ធជាដើម។ល។ គួរតែនិយាយរឿងណាដែលមានប្រយោជន៍ដល់អ្នកស្តាប់ដូចជា សិល្ប: កីឡា វិទ្យាសាស្ត្រ ប្រវត្តិសាស្ត្រ ពត៌មានប្រចាំថ្ងៃជាដើម។
- ➢ កុំប្រមូលយកការសន្ទនាមកធ្វើជាកម្មសិទ្ធិផ្ទាល់ខ្លួនម្នាក់ឯងផ្តាច់មុខ ដោយមិនទុកឱ្យអ្នកដទៃនិយាយខ្លះផងឱ្យសោះ។
- ➢ កុំជំទោះនឹងគូសន្ទនា ប៉ុន្តែរកចំណុចដែលមានការយល់ឃើញរួមគ្នាមកនិយាយជំនួសវិញ។
- ➢ កុំទាន់និយាយកាត់ ឬបន្ថែមបើមិនទាន់មានឱកាស ប៉ុន្តែបើគ្រាន់តែដាក់នូវសំនួរតូចៗក៏អាចនឹងធ្វើទៅបាន។
- ➢ កុំប្រញាប់ប្តូររឿងថ្មីភ្លាមៗពេក។
- ➢ ត្រូវសម្តែងថា អ្នកចាប់អារម្មណ៍រឿងដែលគូសន្ទនាកំពុងនិយាយ។
- ➢ ត្រូវចេះបង្វែររឿងចូលមករកខ្លឹមសារសំខាន់។
- ➢ កុំបញ្ចេញយោបល់ អំណះអំណាង ច្រងេងច្រងាងខ្លាំងពេក ឬបង្ខំឱ្យគេយល់ស្របជាមួយនឹងខ្លួនរហូតដល់ថ្នាក់ហាមជំទាស់ឱ្យសោះ។
- ➢ មិននិយាយពេលមានអ្វីនៅក្នុងមាត់ ត្រូវនិយាយឱ្យច្បាស់ៗ បើមានសំឡេងរំខានផ្អាកនិយាយមួយរយ:រហូតដល់សំឡេងនោះបាត់ទៅ។

[74] សាស្ត្រាចារ្យ សំ សារិន, នីតិសេរីភាពសាធារណ: (២០១៤-២០១៥

- កុំនិយាយទិតៀន និន្ទាឈ្នានីស ចំអក ឬប្រមាថមើលងាយអ្នកដទៃ។

### ៦. លក្ខណៈសម្បត្តិល្អរបស់អ្នកនិយាយ[75]

អ្នកនិយាយ ដែលល្អគួរឱ្យមានលក្ខណៈសម្បត្តិដូចតទៅ:

- មុននឹងនិយាយ ត្រូវគិតឱ្យបានហ្មត់ចត់ជាមុនសិន ថាតើពាក្យសំដីនេះ ផ្តល់លទ្ធផលយ៉ាងណា?
- មិនគួរនិយាយអាក្រក់ពីអ្នកណាដោយសារតែការច្រណែននិន្ទា មិននិយាយផ្លែផ្កា មិនត្រូវទម្លាក់កំហុសទៅអ្នកដទៃ ដែលជាអ្នកបង្ហាញការខ្វះសីលធម៌ និងបង្ហាញទឹកចិត្តមិនល្អរបស់អ្នកនិយាយ។
- នៅពេលដែលកំពុងខឹង ឬមិនពេញទឹកចិត្តនឹងអ្នកណាម្នាក់ អ្នកត្រូវអត់ធ្មត់ សង្កត់ចិត្តទុកសិន ព្រោះពេលខឹង អាចឃើញថា សទៅជាខ្មៅ អាក្រក់ទៅជាល្អបាន។ ទោះបីជាក្នុងការសន្ទនាក្តី ក្នុងការជជែកវែកញែកក្នុងអង្គប្រជុំ ករណីនេះត្រូវតែពិចារណាឱ្យបានល្អិតល្អន់ជាទីបំផុត។
- មិនត្រូវនិយាយចំអកទេ ទោះបីជានិយាយលេងក៏ដោយ ព្រោះនឹងធ្វើឱ្យអ្នកស្តាប់អាក់អន់ចិត្ត
- ទោះបីមានការយល់ឃើញខុសគ្នាក៏ដោយ ក៏មិនគួរប្រឆាំងជំទាស់ដែរ។ តែគួររកវិធីនិយាយឱ្យបានសុភាពដោយបញ្ចេញការយល់ឃើញខុសពីគេបានដែរ។
- ប្រើពាក្យពេជន៍សុភាពសមរម្យទៅនឹងអ្នកស្តាប់ដូចជានិយាយជាមួយចាស់ទុំ ឬអ្នកដឹកនាំជាដើម។
- មិននិយាយអួតខ្លួន អួតចំណេះដឹង ឬគំរាមអ្នកដទៃ។
- បើនៅក្នុងការសន្ទនា ត្រូវចេះធ្វើអ្នកស្តាប់ខ្លះផង។
- ត្រូវចេះស្តាប់យោបល់អ្នកដទៃផង
- បើចង់និយាយនៅពេលដែលអ្នកដទៃនិយាយមិនទាន់ចប់ ត្រូវសុំអភ័យទោសជាមុនសិន។ ប៉ុន្តែតាមគោលការណ៍គួរតែរង់ចាំឱ្យនិយាយចប់សិនទើបល្អ
- មានទឹកមុខញញឹមញញែម កាយវិការសុភាពរាបសារ និងតែងខ្លួនសមរម្យ។

### ៧. សិល្បៈនៃការនិយាយ[76]

សិល្បៈនៃការនិយាយ ស្តែងចេញដោយការពោលពាក្យពេជន៍ ដែលនឹងធ្វើឱ្យអ្នកស្តាប់យល់ចិត្ត និងមានការសប្បាយរីករាយផងដែរ។ ព្រមទាំងបានទាក់ទាញចិត្តអ្នកស្តាប់ឱ្យមានជំនឿចិត្តលើអ្នកនិយាយផងដែរ។ ការនិយាយដែលធ្វើឱ្យពេញចិត្តអ្នកស្តាប់បាននោះ

[75] សាស្ត្រាចារ្យ សំ សារិន, នីតិសេរីភាពសាធារណៈ (២០១៤-២០១៥

[76] សាស្ត្រាចារ្យ សំ សារិន, នីតិសេរីភាពសាធារណៈ (២០១៤-២០១៥

គឺអាស្រ័យទៅនឹងសំឡេង ឬសំនួនវោហារ ដែលជ្រួតជ្រាបទៅក្នុងដួងចិត្តអ្នកស្តាប់ ហើយបានធ្វើឱ្យគេរំភើបរីករាយ និងមានសារៈប្រយោជន៍។

សិល្បៈនៃការនិយាយ គ្មានក្បួនខ្នាតងាប់ក្រឡុងដូចគណិតវិទ្យាទេ គឺវាអាស្រ័យទៅនឹងអ្នកស្តាប់ ទីកន្លែង វប្បធម៌ ប្រពៃណី ដែលខុសប្លែងពីគ្នា។ ចំពោះការហ្វឹកហ្វាត់និយាយ គឺត្រូវហ្វឹកហ្វាត់ទាំងអស់ដូចជា ជំនាញក្នុងការនិយាយ និងជំនាញក្នុងការស្តាប់ព្រមគ្នា ព្រោះអ្នកស្តាប់រមែងជាបេះដូងនៃអ្នកនិយាយ ហើយការនិយាយ នឹងបានផលសម្រេច លុះត្រាតែអ្នកស្តាប់យកចិត្តទុកដាក់ស្តាប់ផងដែរ។

អ្នកស្តាប់ដែលល្អ ត្រូវមានលក្ខណៈដូចតទៅនេះ៖

- យកចិត្តទុកដាក់ស្តាប់ មានសមាធិក្នុងការស្តាប់ ហើយគួរកត់ត្រាខ្លឹមសារសំខាន់ៗទុកផង
- តាមដានរឿងពីដើមដល់ចប់ និងអាចប្រមូលសារៈសំខាន់បានតាមគោលបំណងរបស់អ្នកនិយាយ
- ស្តាប់ ហើយគិត រួចហើយប្រើវិចារណញ្ញាណក្នុងការពិចារណាថា តើរឿងដែលបានស្តាប់នោះគួរជឿឬទេ? មានសារៈប្រយោជន៍ដូចម្តេច? អ្នកនិយាយបានផ្តល់គំនិតច្បាស់លាស់ប៉ុនណា? តើមានចេតនារម្មណ៍យ៉ាងដូចម្តេច?
- ស្តាប់ដោយមានហេតុផល គ្មានទោសៈ មោហៈ ឬលំអៀងទៅខាងណាមួយ និងមិនធ្វើជាអាជ្ញាកណ្តាល ដែលហាក់ដូចជាបិទបាំងនូវអ្វីដែលល្អក៏ជាប្រយោជន៍ចំពោះអ្នកស្តាប់ទាំងអស់
- ស្តាប់នូវអ្វីដែលគួរស្តាប់ គឺត្រូវជ្រើសរើសស្តាប់រឿងរ៉ាវណា ដែលគួរស្តាប់ និងមានសារៈប្រយោជន៍តែប៉ុណ្ណោះ។ ជាធម្មតា មនុស្សយើង ចង់ស្តាប់អ្វីក៏បានដែរ ប៉ុន្តែត្រូវគិតថា តើរឿងដែលបានស្តាប់នោះមានសារៈប្រយោជន៍ឬទេ? តើមានផលវិបាកដល់ខ្លួនដែរទេ?
- ពេលកំពុងស្តាប់ មិនគួរគិតជាមុនថា អ្នកនិយាយ នឹងនិយាយអ្វីឡើយ គឺត្រូវស្តាប់រឿងដែលគេនិយាយដោយយកចិត្តទុកដាក់ ហើយត្រូវពិចារណារឿង ដែលគេនិយាយនោះវាទាក់ទងនឹងរឿង ដែលគេបាននិយាយរួចមកហើយយ៉ាងដូចម្តេចខ្លះ?
- មិនគួរនិយាយកាត់ ពេលដែលអ្នកនិយាយឈប់សម្រាកដកដង្ហើម ឬកំពុងនិយាយមិនទាន់ចប់។ ការទុកឱកាសឱ្យគេនិយាយឱ្យចប់ អាចមានផលល្អខាងផ្លូវចិត្ត។ បើមានបញ្ហាត្រូវចោទសួរច្បូររង់ចាំឱកាសសមរម្យសិន។
- មិនគួរស្ងាបហាមាត់ធំៗ ជជែករំខាន ឱនមុខមើលសៀវភៅ ឬការសែតនៅពេលកំពុងស្តាប់ឡើយ។

**៨. វិធីនិយាយ**[77]

វិធីនិយាយ ចែកចេញជា៥យ៉ាងគឺ:

- បែបបទន្ទេញចាំមាត់: អ្នកនិយាយត្រៀមរឿង ដែលនិយាយរួចស្រេច ហើយទន្ទេញចាំមាត់យកទៅនិយាយ។ វិធីនេះ មិនសូវជាបានជោគជ័យប៉ុន្មានទេ ហើយទាំងធ្វើឱ្យអ្នកនិយាយហត់នឿយទៀតផង ព្រោះអ្នកស្តាប់ មិនអាចដឹងបានថា អ្នកនិយាយទន្ទេញចាំមាត់ធ្វើឱ្យគ្មានការរំភើប និងគ្មានរសជាតិ ហើយថែមទាំងធ្វើឱ្យធុញទ្រាន់ទៀតផង។ ម៉្យាងទៀត ប្រសិនបើអ្នកនិយាយមានការភ្លេច ភ្លាំង ចំណុចខ្លះៗក្នុងពេលនិយាយ និងអាចធ្វើឱ្យការនិយាយដែលល្អមិនគួរប្រើវិធីនេះ។ ទោះជាយ៉ាងណាក្តីការរង់ចាំ ឬទន្ទេញវគ្គខ្លះៗក៏ជាការចាំបាច់ដែរ គឺចាត់ទុកជា ការ លើកយកចំណុចសំខាន់ៗមកនិយាយប៉ុណ្ណោះ មិនចាត់ទុកជាការទន្ទេញចាំ មាត់ទេ។
- បែបអានអត្ថបទ: វិធីនេះច្រើនតែប្រើជាផ្លូវការ ដើម្បីការងារការខុសឆ្គងដូចជា ការរាយការណ៍។ល។
- បែបយល់ច្បាស់ ហើយមើលគោលសំខាន់ៗ ជាវិធី ដែលមានអ្នកនិយមប្រើច្រើន គ្នា។ ការនិយាយបែបនេះ ជាការនិយាយ ដែលផុសចេញពីដួងចិត្តពិតៗពីកម្រិត វប្បធម៌ និងពីអារម្មណ៍ទៅតាមធម្មជាតិ ប៉ុន្តែគ្រាន់តែកត់ត្រាចំណុចសំខាន់ៗខ្លះដាក់ ក្រដាស់គ្រាន់ទុកក្រឡេកមើលម្តងៗ ដើម្បីកុំឱ្យភ្លេចតែប៉ុណ្ណោះ។
- បែបរៀបចំរួចស្រេច ហើយចងចាំ ព្រមទាំងយល់: វិធីនេះប្រហាក់ប្រហែលគ្នានឹងវិធីទី៣ដែរ គ្រាន់តែអ្នកនិយាយត្រូវការចងចាំ និងមានសមាធិល្អថែមទៀតប៉ុណ្ណោះ។ អ្នកស្តាប់អាចមានអារម្មណ៍ថា អ្នកនិយាយមិនបានត្រៀមទុកជាមុនទេ ព្រោះមិនមានអ្វីកាន់ក្នុងដៃឡើយ។ ការពិតអ្នកនិយាយ បានត្រៀម និងចងចាំខ្លឹមសារទុក ក្នុងខួរក្បាលរួចទៅហើយមុននឹងឡើងមកនិយាយ។ វិធីនេះ អាចធ្វើឱ្យអ្នកស្តាប់ជក់ចិត្ត និងមានការជឿជាក់លើការនិយាយ តែមានអ្នកនិយាយវិធីនេះតិចតួចណាស់។
- បែបឥតព្រៀងទុក: វិធីនេះបើថានឹងល្អល្អក៏បាន តែបើអ្នកធ្វើបានចាត់ទុកថា ពូកែ ណាស់។ អ្នកដែលនឹងប្រើវិធីនេះបាន លុះត្រាតែបានឆ្លងកាត់វិធីផ្សេងៗ ឬក៏បានហ្វឹក ហ្វាត់ជាយូរមកហើយ។ វិធីនេះល្អបំផុតនោះ គឺគួរមានគម្រោងទុកជាមុនថាតើនឹង ចាប់ផ្តើមពីអ្វី? តើមានខ្លឹមសារយ៉ាងដូចម្តេច? តើត្រូវបញ្ចប់យ៉ាងដូចម្តេច? លុះដល់ពេលនិយាយក៏នឹងគ្មានការផ្តាំឆ្គង ហើយថែមទាំងមានការទាក់ទាញចិត្តអ្នកស្តាប់ បានទៀតផង។

[77] សាស្ត្រាចារ្យ សំ សារិន, នីតិសេរីភាពសាធារណៈ (២០១៤-២០១៥

វិធីទាំងនេះខាងលើ យើងមិនទាន់អាចបញ្ជាក់បានថា វិធីណាមួយល្អជាងវិធីណា ឬវិធីណាមួយ ដែលជាវិធីល្អបំផុតបានឡើយ គឺអាស្រ័យទៅលើអ្នកនិយាយស្ទាត់ តាម វិធីណាមួយ។

## ៩. ដំណាក់កាលអនុវត្តនៃការនិយាយ[78]

ការអនុវត្តនៃការនិយាយចែកចេញជា៣ដំណាក់កាល គឺដំណាក់កាលត្រៀមខ្លួន និយាយ ដំណាក់កាល ដំណាក់កាលកំពុងនិយាយ និងដំណាក់កាលក្រោយពេល និយាយចប់។

ដំណាក់កាលត្រៀមខ្លួននិយាយ: នៅពេលបានទទួលឱ្យនិយាយ អ្នកនិយាយត្រូវត្រៀម អំពីគោលដៅនឹងត្រូវនិយាយ គឺត្រូវជ្រើសរើសឱ្យសមរម្យទៅនឹងគោលបំណង រួចធ្វើការវិភាគ ទៅលើអ្នកស្តាប់ ប្រមូលទិន្នន័យ និងឯកសារផ្សេងៗ ដែលនឹងប្រើឱ្យសព្វគ្រប់។

ដំណាក់កាលកំពុងនិយាយ: មានប្រការ ដែលត្រូវអនុវត្ត១២យ៉ាង៖

- គោរពពេលវេលា
- ការឈានឡើងទៅលើវេទិការ
- ប្រុងប្រយ័ត្នក្នុងការតុបតែងខ្លួន
- ផ្តល់កិត្តិយសដល់អ្នកស្តាប់
- គួរសម្លឹងមើលទៅអ្នកស្តាប់ទូទៅ
- ការប្រើភាសានិយាយ
- ឧទាហរណ៍ ឬអំណះអំណាងច្បាស់លាស់
- ការធ្វើកាយវិការគួរឱ្យសមស្របនឹងរឿង
- រង់ចាំសង្កេតប្រតិកម្មពីអ្នកស្តាប់
- មិនគួរនិយាយប្រជែងនឹងសំឡេងសើច ឬសំឡេងទះដៃឡើយ
- ការនិយាយចុងក្រោយឱ្យអ្នកស្តាប់ទៅគិត
- និយាយតាមការតាំងចិត្ត តែក៏ត្រូវគោរពវេលាដែរ
- ពេលចាំបាច់ក៏ត្រូវប្តូររឿងនិយាយខ្លះដែរ។

ដំណាក់កាលក្រោយពេលនិយាយចប់ចែកចេញជា២ប្រភេទ៖

- ពេលនិយាយចប់ហើយក៏ត្រឡប់មកផ្ទះ
- ពេលនិយាយចប់ទុកពេលឱ្យអ្នកស្តាប់សួរបំបាត់ការសង្ស័យ។ ករណីនេះបើសិនណា ដំណើរការទៅតាមធម្មតានោះក៏គ្មាន បញ្ហាអ្វី ឡើយ ព្រោះអ្នកនិយាយនឹងមានឱកាសអាចឆ្លើយបំភ្លឺបំបាត់ការសង្ស័យបាន។ ប៉ុន្តែបើសិនអ្នកសួរបាន បង្ក

[78] សាស្ត្រាចារ្យ សំ សារិន, នីតិសេរីភាពសាធារណៈ (២០១៤-២០១៥

បញ្ហាឡើងនោះ អ្នកនិយាយ ត្រូវអត់ធ្មត់ និងឈ្លាសវៃ ទើបអាចដោះស្រាយបញ្ហាបាន។

## ផ្នែកទី៤៖ បញ្ហាប្រឈមលើមធ្យោបាយនៃសេរីភាពបញ្ចេញមតិនៅកម្ពុជា

លទ្ធិប្រជាធិបតេយ្យ ទាមទារនូវប្រព័ន្ធផ្សព្វផ្សាយពហុបែបនូវសេរីភាពខាងការបញ្ចេញមកយោបល់ និងនូវសេរីភាពខាងការចែកចាយពត៌មាន ដើម្បីប្រយោជន៍សាធារណៈ។ ប្រព័ន្ធផ្សព្វផ្សាយពហុបែប នឹងបង្កើតលំហាដើម្បីជជែកវែកញែក ដោយអនុញ្ញាតអោយមតិយោបល់ខ្វែងគំនិតគ្នាអាចសម្តែងចេញបាន។ សារពត៌មានដោយឯករាជ្យពេញលេញ គឺជាស្នូលនៃលទ្ធិប្រជាធិបតេយ្យដោយសារវាបានផ្តល់អោយ ប្រជាពលរដ្ឋនូវការទទួលបានពត៌មាន។ ការទទួលបានពត៌មាន និងមានមតិខ្វែងគំនិតគ្នា ក្នុងវេទិកាសាធារណៈ អនុញ្ញាតអោយប្រជាពលរដ្ឋអាចធ្វើការជ្រើសរើសដោយត្រឹមត្រូវនិងកំនត់នូវប្រយោជន៍របស់ខ្លួនដោយខ្លួនឯង។ ប្រព័ន្ធផ្សព្វផ្សាយគឺមាន សារៈសំខាន់ដល់ការពង្រឹងរដ្ឋាភិបាលបែបប្រជាធិបតេយ្យតាមរយៈការត្រូវពិនិត្យតាមដានដោយដាក់ចេញនូវ អត្ថបទ និងរឿងរ៉ាវស្តីពីកិច្ចការសាធារណៈ និងបុគ្គលសាធារណៈដែលធានាអោយបាននូវគណនេយ្យភាព តម្លាភាព និងជាគ្រឹះនៃសង្គមប្រជាធិបតេយ្យ។

ទោះបីប្រព័ន្ធផ្សព្វផ្សាយដោយសេរីពហុបែប មានសារៈសំខាន់ដល់ការពង្រឹងលិទ្ធិប្រជាធិបតយ្យយ៉ាងណា គណៈកម្មការសិទ្ធិមនុស្សអាស៊ី បានរកឃើញថា សេរីភាពខាងសារពត៌មាននៅកម្ពុជា ចាប់ពីឆ្នាំ ១៩៩៣ ជាទូទៅមានការធ្លាក់ចុះជាលំដាប់ ដោយសេរីភាពនេះបានដុះដាល់តែមួយរយៈពេលខ្លីប៉ុណ្ណោះ។ ការរិតត្បិតនេះ បានធ្វើអោយយោគយល់រវាងសេរីភាព និងការគាបសង្កត់ដែលជាហេតុថា សារពត៌មាន មិនអាចចាត់ទុកថាមានសេរីភាព ពេញលេញបានឡើយ។ ជាក់ស្តែង អ្នកសារពត៌មានបន្តប្រឈមនឹងការគំរាម និងការរុកគួន តាមរយៈការប្រើប្រាស់បណ្តឹងបរិហាកេរ្តិ៍លើអ្នកសារពត៌មាន ក្នុងគោលបំណងបំបិទនូវការជជែកវែកញែកនិងការពិភាក្សា។ កាសែតជំទាស់ ត្រូវបានបង្ខំអោយបិទទ្វារ និងត្រូវតែអព្យាក្រឹត្យដូចក្នុងករណីកាសែត ស្រលាញ់ខ្មែរ កាលពីឆ្នាំ២០០៦។ កាលពីខែឧសភា ឆ្នាំ២០០៨ ក្រសួងពត៌មានបានបិទស្ថានីយ វិទ្យុអង្គរដ្ឋា ហើយព្យួរអាជ្ញាបណ្ណរបស់វិទ្យុនេះបន្ទាប់ពីវិទ្យុនេះ បានធ្វើការលក់ម៉ោងផ្សាយទៅអោយគណបក្សចំនួន ៤ ជាពិសេសការរាយការណ៍ពីប្រធានបទរសើប ឬពាក់ព័ន្ធនឹងនយោបាយ។ មើលពីខាងក្រៅ កម្ពុជាហាក់ដូចជាមានប្រព័ន្ធផ្សព្វផ្សាយពត៌មានចម្រុះដោយមានចំនួនស្ថានីយ ទូរទស្សន៍ និងវិទ្យុ ការបោះពុម្ពផ្សាយ និងការបើកអោយប្រើប្រាស់ប្រព័ន្ធអ៊ីធឺណេត។ ខណៈ ដែលនេះទំនាក់ទំនងបង្ហាញថាប្រទេសកម្ពុជាមានទម្រង់ប្រព័ន្ធផ្សព្វផ្សាយផ្សេងៗគ្នាជាច្រើន វាមិនមានន័យថានេះអាចបំពេញនូវពហុនិយមបានឡើយ។ ផ្ទុយទៅវិញពហុនិយមពិតប្រាកដនឹងត្រូវមានប្រព័ន្ធផ្សព្វផ្សាយដែលគ្របដណ្តប់បានទូលាយ និងបានច្រើនមុខខុសៗគ្នា ដែលនេះឆ្លុះបញ្ចាំងនូវក្រុមទាំឡាយ និងទស្សនៈនានាក្នុងសង្គម ហើយដែលអាច

ឬដល់មនុស្សទាំងអស់។ នៅកម្ពុជា ភាពពិតគឺថាលក្ខខណ្ឌដែលសហាគ្រាសពត៌មាន ត្រូវបានគេបង្ខំអោយធ្វើការតាមបញ្ហានេះវា ពិបាកនឹងអោយមានកាចែកចាយនូវទស្សនៈផ្សេងៗគ្នាណាស់។ ហេតុនេះ យើងសង្កេតឃើញថាកម្ពុជាបច្ចុប្បន្ន មានប្រព័ន្ធផ្សព្វផ្សាយចម្រុះគេ ប្រព័ន្ធផ្សព្វផ្សាយបែបប្រពៃណី និងប្រព័ន្ធផ្សាយបែបទំនើប។

## ១. ការរឹតបន្តឹងសេរីភាពបញ្ចេញមតិតាមបែបប្រពៃណី

វិស័យប្រព័ន្ធផ្សព្វផ្សាយនៅកម្ពុជា គឺជាការរស់រវើក និងគ្មានច្បាប់គ្រប់គ្រាន់យ៉ាងច្រើន។ ស្ថានភាពនេះបាននាំអោយមានការបង្កើតជាច្រើនកន្លែងវិទ្យុ ទូរទស្សន៍ និងប្រព័ន្ធផ្សព្វផ្សាយបោះពុម្ព។ ក្រុមហ៊ុនវិស័យឯកជនជាច្រើន បានផ្លាស់ប្តូរទៅក្នុងវិស័យប្រព័ន្ធផ្សព្វផ្សាយ ដែលតំណាងអោយការផ្លាស់ប្តូរដ៏សំខាន់ពីច្រើនឆ្នាំមកហើយនៃការផ្សព្វផ្សាយនិងការបោះពុម្ពផ្សាយរបស់រដ្ឋ។ ចាប់តាំងពីការដើបចេញពីរដ្ឋាភិបាលកុម្មុយនិស្តនៃរបបខ្មែរក្រហម និងសាធារណរដ្ឋប្រជាមានិកប្រទេសវៀតណាម ដែលគាំទ្រដោយប្រទេសនៃរបបកម្ពុជា វិស័យប្រព័ន្ធផ្សព្វផ្សាយកម្ពុជា បានក្លាយ ជាផ្នែកមួយនៃតំបន់អាស៊ីអាគ្នេយ៍ និងដោយឥតគិតថ្លៃបំផុត។ បើទោះបីជាការខ្វះការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈសារពត៌មាននិងក្រមសីលធម៌ និងការគំរាមកំហែងដោយទាំងរដ្ឋាភិបាល និងផលប្រយោជន៍ឯកជនកំណត់ឥទ្ធិពលប្រព័ន្ធផ្សព្វផ្សាយកម្ពុជា។ ដំណើរការលិទ្ធិប្រជាធិបតេយ្យដ៏ពេញលេញមួយអាចប្រព្រឹត្តទៅបានអាស្រ័យលើលទ្ធភាព ដែលពលរដ្ឋអាចគិតប្រកាន់មតិ និងចែករំលែកមតិរបស់ខ្លួនជាមួយអ្នកដទៃបាន។ សេរីប្រព័ន្ធផ្សព្វផ្សាយ គឺមានសារៈសំខាន់ណាស់សំរាប់ដំណើរការនេះ។ ប្រព័ន្ធផ្សព្វផ្សាយបែបប្រពៃណី ដែលមានដូចជាសារពត៌មាន បោះពុម្ពផ្សាយ វិទ្យុ និងទូរទស្សន៍ ជាទម្រង់សារពត៌មាន ដែលពេញនិយមនៅកម្ពុជា តែក៏ត្រូវបានគេរឹតបន្តឹងខ្លាំងណាស់ដែរ។

### ១.១ ការកាត់ទោសចំពោះការប្រើប្រាស់វិទ្យុ និងកាសែត

ថ្វីបើកិច្ចគាំពារនេះ ត្រូវបានចែងក្នុងច្បាប់ជាតិ អន្តរជាតិយ៉ាងណាក៏ដោយ ការគាបសង្កត់លើសារពត៌មាន គឺមានកម្រិតខ្លាំងនៅកម្ពុជា ហើយអ្នកសារពត៌មាន គឺតែងតែត្រូវបានគេគំរាមកំហែង និងយាយី។

ជាក់ស្តែងលោក ម៉ម សូណាង់ដូ អាយុ៧១ឆ្នាំ ជាប្រធានសមាគមប្រជាធិបតេយ្យនិងជាប្រធានវិទ្យុសំបុកឃ្មុំ ត្រូវបានចាប់ខ្លួននៅថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១២[79]។ លោក ត្រូវបាន

[79] អង្គការឃ្លាំមើលសិទ្ធិមនុស្សកម្ពុជាស្តីពី"បន្ទាប់ពីសហរដ្ឋអាមេរិក អាស៊ានចាកចេញ អ្នករិះគន់ជាអ្នកសារពត៌មានត្រូវបានចាប់ដាក់ពន្ធនាគារ (សេចក្តីប្រកាសពត៌មាន, ២០១២) http://hrw.org/news/2012/07/17/cambodia-after-us-asean-leave-media-critic-jailed (ថតចម្លងថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០១៦)

គេចោទប្រកាន់ពាក់ព័ន្ធនឹងមាត្រាចំនួន៦ផ្សេងៗ ដោយឡែកពីគ្នានៃក្រមព្រហ្មទណ្ឌ ដែល២ករណីជាបទល្មើសកម្រិតធ្ងន់ពាក់ព័ន្ធនឹងចលនាបះបោរ និងញុះញង់ឱ្យមានការកាន់អាវុធ។ បទល្មើសទាំងនោះ ផ្សាភ្ជាប់រូបគាត់ទៅនឹងការធ្វើអបគមន៍នៅភូមិប្រម៉ា ខេត្តក្រចេះ ដែលជាទីតាំងមានជំលោះដីធ្លីបន្តបន្ទាប់រវាងអ្នកភូមិ និងក្រុមហ៊ុនអភិវឌ្ឍន៍កសិកម្មឈ្មោះថា កាសូទីម ដែលជាជំលោះនោះឈានដល់ការផ្ទុះអំពើហិង្សា[80]។ ការកាត់ទោសប្រឆាំងមកលើលោកម៉ម សូណង់ដូ ត្រូវបានគេជឿជាក់ថា ជាការជម្រុញដោយចេតនានយោបាយ គាត់ត្រូវបានគេចាប់ខ្លួនពីរដងរួចទៅហើយ ដោយសារតែបានសម្តែងសិទ្ធិក្នុងការបញ្ចេញមតិ។ លើសពីនេះទៀត ថ្វីបើសវនាការប្រឆាំងរូបលោក ត្រូវបានមើលឃើញយ៉ាងច្បាស់មិនមានភស្តុតាងគ្រប់គ្រាន់ក៏ដោយលោកត្រូវកាត់ ទោសឱ្យជាប់ពន្ធនាគារចំនួន២០ឆ្នាំ។ ក្រុមសិទ្ធិមនុស្ស បានថ្កោលទោសលើរូបគាត់ស្របពេលដែលអង្គការលើកលែងទោសជាអន្តរជាតិ បានចាត់ទុកលោកជាអ្នកទោសមានមនសិការ។ លោកម៉ម សូណង់ដូ បានប្រឆាំងនឹងការកាត់ទោសនេះ ហើយបានប្តឹងសារទុកចំពោះបទចោទប្រកាន់របស់លោក ដែលត្រូវបានសម្រាលមកជាប់ទោសក្រោមច្បាប់ព្រៃឈើវិញ។ ជាលទ្ធផលការកាត់ទោសប្រឆាំងលោកម៉ម សូណង់ដូ ត្រូវបានសម្រាលមកជាប់ពន្ធនាគារមកត្រឹម៥ឆ្នាំហើយនៅសេសសល់ប៉ុន្មាន គឺត្រូវព្យួរទោស។ រូបលោក ត្រូវបានគេដោះលែងនៅថ្ងៃទី១៥ ខែមិនាបន្ទាប់ពីការជាប់ឃុំឃាំង៨ខែ ចាប់តាំងពីពេលដែលលោកត្រូវបានគេចាប់ខ្លួននោះ[81]។ ថ្វីបើមានការដោះលែងយ៉ាងនេះក៏ដោយសាលក្រមចំពោះពិរុទ្ធភាពប្រឆាំងមកលើរូបលោក គឺស្ថិតក្រោមការឃ្លាំមើលរបស់តុលាការនៅឡើយ។

រឺង នៅថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១០ ព្រះសង្ឃខ្មែរកម្ពុជាក្រោម រងការគំរាមកំហែងចំពោះការបោះពុម្ពផ្សាយកាសែត។ ព្រះសង្ឃ ថាច់ ព្រៃ ជា ខឿន ជាព្រះសង្ឃពុទ្ធសាសនាខ្មែរកម្ពុជាក្រោមនៅរាជធានីភ្នំពេញ ទទួលការគំរាមកំហែងពីប្រធានសង្ឃ និងតំណាងមកពី

---

[80] ម៉ៃ ទិត្យថារ៉ា និងដេវីដ ប៊ូល, ក្មេងស្រីជំទង់ម្នាក់ត្រូវបានកងកម្លាំងម្នាក់សន្តិសុខនៃការបណ្តេញចេញបាញ់ស្លាប់ (កាសែតភ្នំពេញប៉ុស្តិ៍, ២០១២) http://www.phnompenhpost.com/2012501756224.National/girl-killed-in-eviction.html (ថតចម្លងថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០១៦)

[81] អង្គការលើកលែងទោសជាអន្តរជាតិ, កម្ពុជា៖ ការផ្តន្ទាទោសដោយមិនមានមូលដ្ឋានប្រឆាំងនឹងអ្នករិះគន់រដ្ឋាភិបាលឆ្លុះបញ្ចាំងពីលំហសេរីភាពបញ្ចេញមតិដែលកំពុងធ្លាក់ចុះ (សេចក្តីថ្លែងការណ៍, ២០១២) http://www.amnesty.org/en/for-media/press-release/cambodia-baseless-conviction-government-critic-reflects-shrinking-space-fre> (ថតចម្លងថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០១៦)

ក្រសួងមហាផ្ទៃ ចំពោះការជាប់ពាក់ព័ន្ធរបស់នៅក្នុងការបោះពុម្ពផ្សាយពត៌មានព្រៃនគរ ដែលជាកាសែតតម្រង់ទិសទៅរកខ្មែរកម្ពុជាក្រោម។ ព្រះសង្ឃ ដែលបានកំពុងតែគង់នូវជាបណ្តោះអាសន្នឯវត្តអង្គតាមិញ ត្រូវបានប្រធានសង្ឃដកហូតយកលិខិតឆ្លងដែន។ តំណាងក្រសួងមហាផ្ទៃ បានប្រាប់ទៅព្រះអង្គថា ព្រះអង្គចាំបាច់ ត្រូវបញ្ឈប់ការបោះពុម្ពផ្សាយសារពត៌មាន និងបានទាមទារឱ្យព្រះអង្គ ចុះហត្ថលេខាលើឯកសារយល់ព្រមបញ្ឈប់ការបោះពុម្ពផ្សាយកាសែតនេះ។ អ្នកសារពត៌មាន បានបញ្ឈប់ការបោះពុម្ពផ្សាយពីមុនមកជាច្រើនខែ ហើយឆ្លើយតបទៅនឹងការគំរាមកំហែងពីដំបូងពីអាជ្ញាធរ។

លើសពីនេះទៀត អំពើហិង្សា មិនអាចត្រូវបានប្រើជាអំណះអំណាង ដើម្បីដាក់បទបញ្ជាលើការបញ្ចេញមតិនោះឡើយ ហើយទង្វើនេះបានបង្ហាញយ៉ាងច្បាស់នូវការបំពានលើសិទ្ធិសេរីភាពសម្រាប់បុគ្គលម្នាក់ៗ ដែលបានធានាដោយសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយផងដែរ។ ប៉ុន្តែនៅកម្ពុជាវិញ អ្នកសារពត៌មាន ត្រូវបំពេញការងារក្នុងមជ្ឈដ្ឋានភ័យខ្លាចប្រឈមនឹងការឃាយឺ និងបទចោទព្រហ្មទណ្ឌ ព្រមទាំងអំពើហិង្សា ដែលត្រូវបានប្រើប្រាស់ ដើម្បីសម្លុតគំរាមដល់ការរាយការណ៍ដែលមានលក្ខណៈរសើប ការចោទប្រកាន់ដែលមានចេតនានយោបាយ ដូចជាករណីរំលោភយកដីធ្លី អំពើពុករលួយ និងការកាប់ឈើខុសច្បាប់ ដែលទាំងអស់នេះ ជាបញ្ហាធំៗនៅកម្ពុជានាពេលបច្ចុប្បន្ន។ការប្រើប្រាស់បទចោទប្រកាន់កម្រិតព្រហ្មទណ្ឌ ដើម្បីដាក់កំហិតលើការបញ្ចេញមតិរបស់សារពត៌មាន ចាត់ទុកជាការបំពានដល់សិទ្ធិសេរីភាពបញ្ចេញមតិ ដែលបានធានាដោយច្បាប់ជាតិ និងអន្តរជាតិ។ នាឆ្នាំ២០១២ និង២០១៣ ត្រូវបានមើលឃើញថាជាឆ្នាំដែលផ្នែកខ្លះនៃតុលាការ ត្រូវបានគេបន្តប្រើប្រាស់ ដើម្បីកាត់ទោសទណ្ឌដល់អ្នកសារពត៌មានទាំងឡាយណា ដែលបានរាយការណ៍ពត៌មាន ដែលប៉ះពាល់ដល់រដ្ឋាភិបាល ឬអ្នកដែលបានរិះគន់ប្រឆាំងជាសាធារណៈដល់ស្ថាប័នរដ្ឋ និងគោលនយោបាយរបស់រដ្ឋជាដើម។ ម៉្យាងប្រព័ន្ធយុត្តិធម៌កម្រិតព្រហ្មទណ្ឌ ដែលបានបង្កជាវប្បធម៌មិនចាប់ពិរុទ្ធដោយខ្លួនឯងយ៉ាងទូលំទូលាយ ដែលក្នុងនោះអ្នកសារពត៌មាន នឹងព្យាយាមជៀសវាងប្រធានបទទាំងឡាយណា ដែលរសើបដើម្បីគេចផុតពីការឃាយឺពីសំណាក់អាជ្ញាធរ[82]។

ការទទួលបានពត៌មាន ពិតជាមានសារៈសំខាន់ណាស់ជុំវិញឱ្យការបញ្ចេញមតិនៅក្នុងប្រទេសប្រកាន់លិទ្ធិប្រជាធិបតេយ្យមានការរីកចំរើន។ ដូចដែលបានរៀបរាប់ខាងលើរួចមកហើយនោះ ការទទួលបានពត៌មាន ត្រូវបានធ្វើឡើងតាមគ្រប់មធ្យោបាយទាំងអស់រួមមានទូរទស្សន៍ វិទ្យុ

[82] លីកាដូ, សេរីភាពខាងបញ្ចេញមតិនៅកម្ពុជា: ប្រជាធិបតេយ្យផ្តិនភ្នែក (របាយការណ៍លីកាដូ, ២០១០), ថតចម្លងថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០១៦)

កាសែត ការធ្វើសិក្ខាសាលា ឬអ៊ីនធឺណេតជាដើម។ រដ្ឋជាតួអង្គស្នូលក្នុងការផ្តល់ឱ្យបាននូវព័ត៌មានជូនដល់ប្រជាពលរដ្ឋគ្រប់រូប ប៉ុន្តែបើយើងក្រឡេកមើលទៅលើលទ្ធិប្រជាធិបតេយ្យក្នុងប្រទេសកម្ពុជាវិញ សិទ្ធិទទួលបានព័ត៌មានទាំងអស់ហាក់ដូចជា នៅមានកម្រិត និងពុំបានពេញលេញនៅឡើយដោយផ្អែកទៅលើកត្តាជាច្រើន។ មូលហេតុដែលនាំមានបញ្ហាប្រឈម ដែលធ្វើឱ្យសិទ្ធិទទួលបានព័ត៌មានរបស់ប្រជាពលរដ្ឋមិនបានពេញលេញ ហើយឈានទៅរកការរអាក់រអួល ឬការបញ្ចេញមតិរបស់ប្រជាពលរដ្ឋមិនបានពេញលេញ គឺបណ្តាលមកពីកំហុសរបស់រាជរដ្ឋាភិបាល និងប្រជាពលរដ្ឋខ្លួនឯងផងដែរ។

ថ្វីត្បិតតែប្រព័ន្ធផ្សព្វផ្សាយបែបប្រពៃណីមានច្រើន ដែលបានផ្តល់ឱ្យដោយរដ្ឋាភិបាលកម្ពុជា ដែលរួមមានទូរទស្សន៍ វិទ្យុ កាសែត ការធ្វើសិក្ខាសាលា ការជួបប្រជុំគ្នា និងតាមមធ្យោបាយផ្សេងទៀតក៏ពិតមែន ប៉ុន្តែប្រជាពលរដ្ឋហាក់ដូចជា នៅតែពុំមានការពេញចិត្ត និងយល់ថាការទទួលបានព័ត៌មានរបស់ពួកគេនៅមានកម្រិត ហើយមិនបានឆ្លុះបញ្ចាំងពីព្រឹត្តិការណ៍សង្គមជាក់ស្តែង និងទុក្ខលំបាករបស់ពួកគេផ្ទាល់ឡើយ។ ដូចដែលយើងបានដឹងហើយថា ប្រជាពលរដ្ឋកម្ពុជាមួយចំនួនធំ បានពឹងផ្អែកទៅលើប្រព័ន្ធផ្សព្វផ្សាយបែបប្រពៃណីនេះ ដើម្បីទទួលបានព័ត៌មាន ប៉ុន្តែវាមិនមានលក្ខណៈពេញលេញ និងទូលំទូលាយឡើយ។

### ១.២. ការដាក់កម្រិតដល់ការជួបប្រជុំជាសាធារណៈដោយសន្តិវិធី

ប្រជាពលរដ្ឋកម្ពុជាគ្រប់រូប មានសិទ្ធិក្នុងការជួបប្រជុំដោយអនុលោមតាមមាត្រា៤១នៃរដ្ឋធម្មនុញ្ញដែលចែងថា ពលរដ្ឋខ្មែរ មានសេរីភាពខាងបញ្ចេញមតិរបស់ខ្លួន សេរីភាពខាងសារព័ត៌មាន សេរីភាពខាងការបោះពុម្ពផ្សាយ សេរីភាពខាងការប្រជុំ[83]។ ប៉ុន្តែបើយើងក្រឡេកមើលទៅក្នុងករណីជាក់ស្តែងវិញ អាជ្ញាធរមានសមត្ថកិច្ច ក៏ដូចជារដ្ឋាភិបាល ហាក់ដូចជាបានរឹតត្បិតនូវសេរីភាពខាងការជួបប្រជុំរបស់ពលរដ្ឋកម្ពុជាទៅវិញ ដែលជាហេតុធ្វើឱ្យមានការរារាំងដល់សេរីភាពបញ្ចេញមតិនៅកម្ពុជាផងដែរ។

ជាក់ស្តែង នៅខែកក្កដា ឆ្នាំ២០១០ មន្ត្រីជាប់ឆ្នោតមកពីគណបក្សជំទាស់គឺ គណបក្សសិទ្ធិមនុស្ស បានព្យាយាមរៀបចំវេទិកាសាធារណៈលើប្រធានបទ"សេរីភាពនៃការបញ្ចេញមតិ" ក្នុងតាកែវ។ អាជ្ញាធរ បានបិទវេទិកានោះ ព្រោះអ្នករៀបចំកម្មវិធីមិនមានការអនុញ្ញាតត្រឹមត្រូវ[84]។ វាជារឿងធម្មតាដែរ ដែលអាជ្ញាធរពន្យាពេលផ្តល់ការអនុញ្ញាតរហូតដល់ដំណាក់កាលចុងក្រោយ ដែលទំនងជាសង្ឃឹមថា នឹងមានមនុស្សចំនួនតិចតួចចូលរួម បើសិនជាគ្មានភាពប្រាកដប្រជាព្រឹត្តិការណ៍នោះ នឹងប្រព្រឹត្តទៅបាន។ នេះជាករណីដែលកើតឡើងក្នុងខែកក្កដា ឆ្នាំ២០១០ ជាពេល

[83] រដ្ឋធម្មនុញ្ញ លេខ នស/រកម/០៧០៩/០០១ ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ១៩៩៣ មាត្រា៤១

[84] លីកាដូ, សេរីភាពខាងបញ្ចេញមតិនៅកម្ពុជា: ប្រជាធិបតេយ្យថ្មីនគ្នែក (របាយការណ៍លីកាដូ, ២០១០), ថតចម្លងថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៦)

ដែលអាជ្ញាធរបានបដិសេធការអនុញ្ញាតពីពេលដំបូងមិនឱ្យសហជីព កម្មករ ធ្វើការតវ៉ាពីរឿងប្រាក់ឈ្នួលក្នុងរាជធានីភ្នំពេញ[85]។ រដ្ឋាភិបាល បានអះអាងថា ការតវ៉ាអាចគំរាម កំហែង សណ្តាប់ធ្នាប់សារណៈ និងបង្កការបំផ្លិចបំផ្លាញទ្រព្យសម្បត្តិ ប៉ុន្តែអ្នករៀបចំប្តេជ្ញាចិត្តថា នឹងធ្វើការតវ៉ា។ នៅទីបំផុតបំរាម ត្រូវបានលុបចេញវិញនាពេលព្រឹកនៃថ្ងៃកើតព្រឹត្តិការណ៍នោះ។ ទោះបីជាមានការយល់ព្រមក៏ព្រឹត្តិការណ៍ជាច្រើនរងការជ្រៀតជ្រែករំខានពីនគរបាល ដែលមានបែបផែនជំទាស់នឹងទំហំនៃក្រុមអ្នកតវ៉ា ខ្សែផ្លូវនៃក្បួនធ្វើដំណើរ ឬទីតាំងធ្វើសកម្មភាព។ ជួនកាលមានការចាប់ខ្លួនអ្នកចូលរួមពីបទញុះញង់ ឬធ្វើឱ្យប៉ះពាល់ដល់សន្តិសុខ បើទោះបីជាការតវ៉ាមើលទៅហាក់ដូចជាគ្រប់យ៉ាងប្រព្រឹត្តទៅដោយសន្តិវិធី។

## ១.៣. អំពើហិង្សាប្រឆាំងមកលើអ្នកសារព័ត៌មាន

អំពើហិង្សា មិនអាចត្រូវបានប្រើជាអំណះអំណាង ដើម្បីដាក់បទបញ្ជាលើការបញ្ចេញមតិនោះឡើយ ហើយទង្វើនេះបង្ហាញយ៉ាងនូវការបំពានលើសិទ្ធិសេរីភាពបញ្ចេញមតិ ដែលអ្នកសារពត៌មានគួរទទួលបាន ព្រមទាំងសិទ្ធិក្នុងការមានសុវត្ថិភាពសម្រាប់បុគ្គលម្នាក់ៗ ដែលបានធានាដោយសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស[86] និងកតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយផងដែរ[87] និងថែមទាំងរដ្ឋធម្មនុញ្ញ[88]។ ប៉ុន្តែនៅកម្ពុជាឆ្នាំ២០១២ និង២០១៣ ត្រូវបានគេមើលឃើញថា មានព្រឹត្តិការណ៍ជាច្រើនបានកើតឡើងពាក់ព័ន្ធនឹងអំពើហិង្សាប្រឆាំងមកលើអ្នកសារពត៌មាន ព្រមទាំងរបាយការណ៍ ដែលអ្នកសារពត៌មានមានការភ័យខ្លាចនឹងអំពើហិង្សា ដែលអាចកើតមានឡើងមកលើខ្លួន។ អ្វីដែលគួរឱ្យកត់សម្គាល់នោះគឺថា អំពើហិង្សាហាក់ដូចជា ត្រូវបានគេប្រើប្រាស់ជាកលវិធីប្រឆាំងតបនឹងអ្នកសារពត៌មាន ដែលធ្វើការស៊ើបអង្កេតលើករណីកាប់ឈើខុសច្បាប់ និងទំនាក់ទំនងរវាងអ្នកកាប់ឈើ និងបុគ្គល ដែលមានទំនាក់ទំនងជាមួយរដ្ឋាភិបាល។ មិនតែប៉ុណ្ណោះ អ្នកសារពត៌មានកម្ពុជា ត្រូវបានគេដាក់ចំណាត់ថ្នាក់ថាមានតួនាទីខ្សោយ ខណៈដែលការបំផ្លិចបំផ្លាញតាមក្រមសីលធម៌នៃឯករាជ្យភាព និងភាពមិនលំអៀង អាចបណ្តាលឱ្យពួកគាត់មានគ្រោះថ្នាក់។

[85] សេចក្តីថ្លែងសារពត៌មានរួម អង្គការលីកាដូ ថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១០ និងពត៌មានពីវិទ្យុអាស៊ីសេរី ថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០១០។

[86] សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស មាត្រា៣

[87] កតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ មាត្រា៩

[88] រដ្ឋធម្មនុញ្ញ លេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ១៩៩៣ មាត្រា៣៤

ឧទាហរណ៍៖ កាលពីខែមិនា ឆ្នាំ២០១២ លោកថេត សម្បត្តិ ជាអ្នកសារពត៌មាន និងជាអ្នកផលិតភាពយន្ត ដែលបានផលិតកម្រងឯកសារអំពីខ្មែរក្រហម ដែលបានជំទាស់នឹងប្រវត្តិសាស្ត្រ ដែលរដ្ឋាភិបាលបានអះអាង បានសម្តែងនូវការភ័យខ្លាចថា អាយុជីវិតរបស់ស្ថិតនៅក្នុងសភាពគ្រោះថ្នាក់ដោយសារតែលទ្ធផលការងាររបស់គាត់[89]។ គាត់ បានអះអាងថា គាត់ត្រូវបានភ្នាក់ងាររដ្ឋាភិបាលក្នុងឯកសណ្ឋានស៊ីវិលបានដេញតាម និងវាយប្រហារគាត់ជាពិសេសនៅពេលដែលគាត់ធ្វើដំណើរនៅតំបន់ជនបទដាច់ស្រយាល ហើយគោលបំណងរបស់ភ្នាក់ងារនោះ គឺចង់ឱ្យគាត់ក្លាយជាជនរងគ្រោះដោយសារការចាប់ជម្រិត ការប្លន់ ឬគ្រោះថ្នាក់ចរាចរណ៍ជាដើម។

ឧទាហរណ៍៖ លោកហង្ស សេរីឧត្តម ជាអ្នកសារពត៌មានឱ្យកាសែតវីរជនខ្មែរប្រចាំខេត្តរតនៈគិរី ត្រូវបានរកឃើញសាកសពនៅថ្ងៃទី១១ កញ្ញា ២០១២។ សាកសពរបស់លោកត្រូវបានរងគ្រោះដោយការវាយយ៉ាងខ្លាំងដោយ ត្រូវបានគេកាប់ជាច្រើនពូថៅនៅនឹងក្បាល។ ប៉ូលីស បានអះអាងថា មរណភាពរបស់លោកសារពត៌មានរូបនេះ គឺមិនមែនបណ្តាលមកពីការប្លន់ទេ ដោយសាររបស់ទ្រព្យរបស់ជនរងគ្រោះ មិនត្រូវបានគេដកហូតនោះទេ[90]។ គាត់ ត្រូវបានគេស្គាល់ថាបានរាយការណ៍អំពីរឿងកាប់ឈើខុសច្បាប់។ ទោះបីជាកម្ពុជា ត្រូវបានគេកំណត់ថាជាប្រទេសមួយ ដែលមានព្រៃឈើក្រាស់ អង្គការស្បៀងអាហារ និងកសិកម្មរបស់អង្គការសហប្រជាជាតិ បានប៉ាន់ស្មានថា ព្រៃឈើសរុបរបស់ប្រទេសកម្ពុជា បានធ្លាក់ចុះពី៧៣% កាលពីឆ្នាំ១៩៩០ នៅត្រឹម ៥៧% នៅឆ្នាំ២០១០[91] ដែលជាអត្រានៃការបំផ្លិចបំផ្លាញធនធានគួរឱ្យព្រួយបារម្ភ។ អត្ថបទរបស់លោកហង្ស សេរីឧត្តម ដែលបានបោះពុម្ពផ្សាយកាលពីថ្ងៃទី៦ ខែកញ្ញា បានចោទ

[89] អ្នកសារពត៌មានដែលស្វែងរកការពិតអំពីខ្មែរក្រហម ភ័យខ្លាចបាត់បង់អាយុជីវិត(កាសែតហ្គាដៀន, ២៥ មិនា ២០១២)
http://www.guardian.co.uk/world/2012/mar/25/journalist-khmer-rouge-fears-life?newsfeed=true
(ថតចម្លងថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១៦)

[90] សួយ សែ, អ្នកសារពត៌មានកម្ពុជាត្រូវបានគេរកឃើញថាត្រូវបានគេសំលាប់ (ភ្នាក់ងារសារពត៌មានបារាំង, ១២ កញ្ញា ២០១២)
http://google.com/hostednews/afp/article/ALegM5jkFxyH9dcOA0JGrh%iYB4uO5FRQ?docid-CNG.b113259f79b40609a864e1927c90fb.331 (ថតចម្លងថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១៦)

[91] អង្គការស្បៀងអាហារ និងកសិកម្ម, ការវាយតម្លៃធនធានព្រៃឈើជាសកលឆ្នាំ២០១០ (ទីក្រុងរ៉ូម, ២០១០)
http://www.fao.org/docrep/013/i1757e/i1757e.pdf (ថតចម្លងថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១៦)

ប្រកាន់កូនប្រុសរបស់ស្ទងការប៉ូលីសយោធាមូលដ្ឋានពាក់ព័ន្ធ ក្នុងការកាប់ព្រៃឈើខុសច្បាប់នៅតំបន់នោះ[92]។

### ១.៤. ប្រព័ន្ធផ្សព្វផ្សាយ ត្រូវបានគ្រប់គ្រងដោយរដ្ឋាភិបាល

ជាទូទៅប្រព័ន្ធផ្សព្វផ្សាយតាមរយៈទូរទស្សន៍ កាសែត វិទ្យុ ត្រូវបានប្រជាពលរដ្ឋមួយចំនួនធំពឹងផ្អែក ដើម្បីទទួលបានពត៌មាន ប៉ុន្តែប្រព័ន្ធផ្សព្វផ្សាយទាំងនោះហាក់ដូចជាគ្មានគណនេយ្យភាព ដោយសារមានការគ្រប់គ្រងពីរដ្ឋាភិបាលកម្ពុជា។ រាល់សកម្មភាព ដែលរិះគន់ ឬមតិដែលវាយ ប្រហាររដ្ឋាភិបាល ឬទង្វើមិនល្អ មិនត្រូវបានផ្សព្វផ្សាយតាមប្រព័ន្ធទាំងនោះឡើយ។ កាសែតក៏ដូចជាអ្នករាយការណ៍ជាច្រើន បានពឹងផ្អែកលើការទំនុកបម្រុងពីគណបក្សនយោបាយក្នុងនោះ នាយករដ្ឋមន្ត្រីកម្ពុជាបច្ចុប្បន្ន ក៏មិនបានកាន់កាប់ និងគ្រប់គ្រងទៅលើប្រព័ន្ធផ្សព្វផ្សាយមួយចំនួនផងដែរ[93]។

លើសពីនេះទៅទៀត ដោយសារតែមានការគ្រប់គ្រងពីសំណាក់រដ្ឋាភិបាលយ៉ាងដូចនេះ វាបានធ្វើឱ្យការទទួលបានពត៌មានរបស់ប្រជាពលរដ្ឋកម្ពុជា នៅមានលក្ខណៈមិនពេញលេញ និងជាពិសេស ពួកគេមិនបានយល់ច្បាស់ពីចំណុចខ្វះខាត ឬសកម្មភាពរិះគន់មួយចំនួនលើរដ្ឋាភិបាលនោះទេ។ គណបក្សប្រឆាំង និងបណ្តាសង្គមស៊ីវិល មិនមានលទ្ធភាព ឬឱកាសក្នុងការបង្កើតនូវស្ថានីយ ទូរទស្សន៍ វិទ្យុ ឯករាជ្យឡើយ។

## ២. ការរឹតបន្តឹងសេរីភាពបញ្ចេញមតិតាមបែបទំនើប

ចំណុចដែលគួរឱ្យបារម្ភបំផុតសម្រាប់អនាគតនៃបណ្តាញសារពត៌មានទំនើប គឺគោលបំណងរបស់រដ្ឋាភិបាល ដើម្បីអនុម័តច្បាប់ឧក្រិដ្ឋកម្មតាមអ៊ីនធឺណេតដំបូងបង្អស់មួយនៅកម្ពុជា។

### ២.១. សេចក្តីព្រាងច្បាប់ឧក្រិដ្ឋកម្មតាមប្រព័ន្ធអ៊ីនធឺណេត

ផែនការ ដើម្បីអនុម័តច្បាប់នេះត្រូវបានប្រកាសក្នុងខែឧសភា ឆ្នាំ២០១២ ហើយច្បាប់នេះកំពុងស្ថិតក្នុងដំណាក់កាលធ្វើសេចក្តីព្រាងដោយអាជ្ញាធរ ទទួលបន្ទុកកិច្ចការអភិវឌ្ឍវិស័យបច្ចេកវិទ្យា គមនាគមន៍ ពត៌មានវិទ្យា គណៈរដ្ឋមន្ត្រី ធនាគារជាតិនៃកម្ពុជា ក្រសួងពាណិជ្ជកម្ម និងក្រសួងទូរគមនាគមន៍។ ប៉ុន្តែនៅមិនទាន់ច្បាស់នៅឡើយថាតើសេចក្តីព្រាងនេះ នឹងផ្សព្វ

---

[92] សួយ សែ, អ្នកសារពត៌មានកម្ពុជាត្រូវបានគេរកឃើញថាត្រូវបានគេសំលាប់ (ភ្នាក់ងារសារពត៌មានបារាំង,១២ កញ្ញា ២០១២) http://google.com/hostdnews/afp/article/ALegM5jkFxyH9dcOA0JGrh%iYB4uO5FRQ?docid-CNG.b113259f79b40609a864e1927c90fb.331 (ថតចម្លងថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១៦)

[93] BBC News Asia, Cambodia Profile: Media [ទម្រង់នៃប្រទេសកម្ពុជា៖ ប្រព័ន្ធផ្សព្វផ្សាយ] (២០១៣) Cambodian Polic Clear Demonstrators From Freedom Park Amid Protest Ban (ថតចម្លងថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១៦)

ផ្សាយជាសាធារណៈនៅពេលណា ឬថាតើសេចក្ដីព្រាងនេះ នឹងផ្សព្វផ្សាយជាសាធារណៈ មុនពេលការអនុម័តដែរឬទេ ហើយថាតើមានបញ្ញត្តិច្បាប់អ្វីខ្លះនៅក្នុងច្បាប់នេះ។ ដោយសារការរឹតបន្តឹងយ៉ាងខ្លាំងមកលើសារពត៌មានបោះពុម្ពផ្សាយ វិទ្យុ និងទូរទស្សន៍ អ្នកតស៊ូមតិសិទ្ធិមនុស្សជាច្រើនបានព្រួយបារម្ភថា សេចក្ដីព្រាងច្បាប់ឧក្រិដ្ឋកម្មតាមប្រព័ន្ធបច្ចេកវិទ្យានេះ នឹងធ្វើឱ្យរដ្ឋាភិបាលបានពង្រីកការគាប់សង្កត់ទៅដល់ប្រព័ន្ធអ៊ីនធឺណេតថែមទៀត[94]។

ទោះជាយ៉ាងណាក្ដី អ្នកនាំពាក្យទីស្ដីការគណៈរដ្ឋមន្ត្រីលោកផៃ ស៊ីផាន បាននិយាយថា គោលបំណងតែមួយរបស់ច្បាប់ឧក្រិដ្ឋកម្មតាមប្រព័ន្ធបច្ចេកវិទ្យា គឺដើម្បីការពារអ្នកប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណេតកម្ពុជាពីការលួច និងបំផ្លាញទិន្នន័យ ហើយរដ្ឋាភិបាល នឹងពឹងផ្អែកលើច្បាប់លើប្រព័ន្ធបច្ចេកវិទ្យារបស់សហគមន៍អឺរ៉ុបសម្រាប់ធ្វើជាមគ្គុទេសក៍[95]។ ប៉ុន្តែគំនិតរបស់ឧបនាយករដ្ឋមន្ត្រីសុខ អាន ហាក់ដូចជាផ្ទុយពីគំនិតរបស់លោកផៃ ស៊ីផាន។ យោងតាមអត្ថបទផ្សព្វផ្សាយនៅលើវែបសាយអង្គភាពសារពត៌មាន និងប្រតិកម្មរហ័សលោកសុខ អាន បង្ហាញថាច្បាប់ឧក្រិដ្ឋកម្មតាមប្រព័ន្ធបច្ចេកវិទ្យា គឺចាំបាច់ ដើម្បីការពារប្រព័ន្ធផ្សព្វផ្សាយពត៌មានមិនពិត។

ទោះយ៉ាងណាក៏ដោយ ប្រសិនបើច្បាប់ឧក្រិដ្ឋកម្មតាមប្រព័ន្ធបច្ចេកវិទ្យាបង្ក្រាបមកលើបណ្ដាញសារពត៌មានទំនើប សមត្ថភាពរបស់រដ្ឋាភិបាល ក្នុងការគាបសង្កត់លើការប្រើប្រាស់ទូរស័ព្ទដៃ និងអ៊ីនធឺណេតឱ្យបានយ៉ាងមានប្រសិទ្ធិភាពនោះនៅតែមានចម្ងល់នៅឡើយ។ ការគាបសង្កត់យ៉ាងទូលំទូលាយ និងទាំងស្រុងទាមទារឱ្យមានធនធានហិរញ្ញវត្ថុ និងធនធានមនុស្សឱ្យគ្រប់គ្រាន់ នេះជាកត្តាចាំបាច់មួយ ដែលរដ្ឋាភិបាលកំពុងខ្វះខាត។ ប្រជាពលរដ្ឋកម្ពុជារំពឹងថារដ្ឋាភិបាល នឹងមិនប្រើប្រាស់ធនធានដ៏មានកម្រិតរបស់ខ្លួន ដើម្បីចំណាយលើការគាបសង្កត់លើបណ្ដាញពត៌មានទំនើបនោះទេ។ បន្ថែមពីលើនោះប្រជាពលរដ្ឋកម្ពុជា ក៏កាន់តែមានចំណេះដឹងផ្នែកបច្ចេកវិទ្យាច្រើនឡើង។

ឧទាហរណ៍ ក្រោយពីវែបសាយ ត្រូវបានបិទ ខេអាយមីឌៀ (KI Media) បានបង្កើតវែបសាយកញ្ចក់មួយនៅលើវើតប្រេស (Wordpress) ដែលអនុញ្ញាតឱ្យអ្នកអានអាចចូលទៅប្រើ

---

[94] ធារ៉ា យួន, អ្នកប្រើប្រាស់អ៊ីនធឺណេតភ័យខ្លាចថា សេចក្ដីព្រាងច្បាប់គ្រប់គ្រងលើប្រព័ន្ធអ៊ីនធឺណេតគាបសង្កត់លើប្រព័ន្ធអ៊ីនធឺណេត (វិទ្យុសំឡេងសហរដ្ឋអាមេរិក, ២០១២) http://www.voacambodia.com/content/internet-users-fear-online-suppression-with-draft-of-cyber-law/1556142.html (ថតចម្លងថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១៦)

[95] ហ្វ្រេន គ្រីនវូដ, ខណៈពេលដែលអ៊ីនធឺណេតបង្កើនសំឡេងពលរដ្ឋនៅកម្ពុជា ការខំពុះពារកើតមានលើការគាបសង្កត់លើប្រព័ន្ធអ៊ីនធឺណេត (សារពត៌មានទូរស័ព្ទលទ្ធិប្រជាធិតេយ្យ, ២០១៣) http://techpresident.com/news/wegov/23659-civiv-voices-cambodia-struggle-net-control (ថតចម្លងថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១៦)

ប្រាស់ប្លុកស្ពត (Blogspot) ក្នុងកំឡុងពេលបិទនោះបាន[96]។ ខណៈពេលដែលរដ្ឋាភិបាល បានបង្ហាញពីគោលបំណងយ៉ាងច្បាស់លាស់ ក្នុងការគាបសង្កត់លើបណ្តាញសារពតិមានទំនើប ប៉ុន្តែពួកគេមិនទាន់មានសមត្ថភាពបែបនោះបានទេ ក្នុងពេលអនាគតឆាប់ៗខាងមុខនេះ។

ជាក់ស្តែងក្នុងខែមករា ឆ្នាំ២០១៣ មន្ត្រីប៉ូលីសរាជធានីភ្នំពេញ បានចោទប្រកាន់ថា ការបង្ហោះជាសាធារណៈលើហ្វេសប៊ុក (facebook) របស់លោកភែល ភារុណ ជាការបរិហារកេរ្តិ៍។ នៅថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៣ លោកភែល ភារុណ បានជិះម៉ូតូតាមដងផ្លូវ នៅពេល ដែលលោកត្រូវបានមន្ត្រីប៉ូលីសចំនួនពីររូបបញ្ឈប់ម៉ូតូនៅជិតវត្តមហាមន្ត្រីក្នុងរាជធានីភ្នំពេញ។ លោកភែល ភារុណ មិនទាន់មានផ្លាកលេខម៉ូតូនៅឡើយ ហើយមន្ត្រីប៉ូលីសស្នើឱ្យលោកបង្ហាញ ពីភស្តុតាងដែលបញ្ជាក់ថា លោកពិតជាកាន់កាប់ម៉ូតូនេះដោយស្របច្បាប់មែន។ លោកភែល ភារុណ បានបង្ហាញឯកសារចាំបាច់មួយចំនួននៅឯប៉ុស្តិ៍ប៉ូលីស ប៉ុន្តែមន្ត្រីប៉ូលីសនៅតែសម្រេច ឃាត់ម៉ូតូរបស់លោករហូតដល់ព្រឹកថ្ងៃបន្ទាប់។ លោកភែល ភារុណ បានបង្ហាញពីភាពមិនពេញចិត្តនៅលើគណនីហ្វេសប៊ុករបស់លោក[97]។ ការបង្ហោះរបស់លោករួមមានទាំងមានទាំងរូបភាពនៃ លិខិតរបស់មន្ត្រីប៉ូលីស ដែលសរសេរថា ប៉ូលីស បានឃាត់របស់លោករួមនឹងពាក្យបរិយាយថា"សូមប្រយ័ត្នចំពោះនីតិវិធីនៃមន្ត្រីប៉ូលីសខណ្ឌចំការមន"[98]។ បន្ថែមពីលើនោះ ការបង្ហោះលើ ហ្វេសប៊ុករបស់លោកក៏មានសួរទៅអ្នកអានថាតើពួកគេគិតថាគួរធ្វើបែបណា ទើបធ្វើឱ្យនីតិវិធី របស់មន្ត្រីប៉ូលីសមានសភាពប្រសើរឡើង ដើម្បីធ្វើឱ្យស្ថានភាពកាន់តែងាយស្រួលសម្រាប់ប្រជាពលរដ្ឋ ដែលគោរពច្បាប់ដូចជារូបលោក។ កាលពីថ្ងៃទី២៦ ខែមករា វែបសាយពតិមាន សប្បាយ បានបោះពុម្ពផ្សាយអត្ថបទអំពីករណីលោកភែល ភារុណ។ ពតិមាននេះត្រូវបានចែក រំលែកយ៉ាងរហ័សលើអ៊ីនធឺណេត ហើយរយៈពេលមួយខែក្រោយមក មន្ត្រីប៉ូលីស បានកោះហៅ លោកភែល ភារុណ ទៅប៉ុស្តិ៍ប៉ូលីស ដើម្បីសាកសួរពតិមាននឹងបទចោទ ដែលអាចជាបណ្តឹង បរិហាកេរ្តិ៍[99]។ មន្ត្រីប៉ូលីស

[96] មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា, រដ្ឋាភិបាលកម្ពុជាកំពុងធ្វើសេចក្តីព្រាងច្បាប់គ្រប់គ្រងប្រព័ន្ធបច្ចេកវិទ្យាជំបូងបង្អស់ (សេចក្តីប្រកាសពតិមានបន្ទាន់, ២០១២) http://www.cchrcambodia.org/index_old.php?url=media/media.php&pp=reprot_detail.php&reid=79&id=5(ថតចម្លងថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១៦)

[97] មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា, លោកភែល ភារុណ រងការចោទការប្រកាន់ស្តីពីបទបរិហារកេរ្តិ៍ពាក់ព័ន្ធនឹងការបង្ហោះពតិមាននៅលើហ្វេសប៊ុក (សលាប័ត្រពតិមាន, ២០១៣) http://www.cchrcambodia.org/admin/media/factsheet/factsheet/english/2013_03_06_Phel-Phearun_Factsheet_ENG.pdf (ថតចម្លងថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១៦)

[98] ដូចខាងលើ

[99] ដូចខាងលើ

បានសម្រេចចិត្តនៅថ្ងៃទី១៩ ខែមិនាថា នឹងមិនបន្តដំណើរការដាក់ ពាក្យបណ្តឹងដោយយោងលើកិច្ចសន្យារបស់លោកភែល ភារុណថា លោកនឹងមិនធ្វើបែបនេះ ទៀតទេក្នុងពេលអនាគត[100]។

### ២.២. ការគ្រប់គ្រងប្រព័ន្ធអ៊ីនធឺណេតដោយរដ្ឋាភិបាល

រាជរដ្ឋាភិបាល មិនបានបិទការប្រើប្រាស់គេហទំព័រនេះដោយផ្ទាល់ទេ តែពួកគេបានចេញបញ្ជាមួយ ដើម្បីក្រុមហ៊ុនផ្តល់សេវាអ៊ីនធឺណេតឱ្យរារាំងពួកគេជំនួសវិញ។ រាជរដ្ឋាភិបាល មិនបានបញ្ជាក់ថា ជាការទទួលខុសត្រូវចំពោះការបិទទាំងនេះ និងបានព្យាយាមក្លែង បន្លំការចូលរួមរបស់ខ្លួន នៅក្នុងបំបិទគេហទំព័រទាំងនេះ ដើម្បីរឹតបន្តឹងសេរីភាពលើបណ្តាញ។ មានរបាយការណ៍ថា រដ្ឋាភិបាលកំពុងសម្លឹងមើលការគ្រប់គ្រងកាន់តែច្រើននៅលើអ៊ីនធឺណេត ជាពិសេសដោយប្រើប្រាស់មធ្យោបាយខាងលើ។ នៅក្នុងខែតុលា ឆ្នាំ២០០៩ ក្រសួងទូរគមនាគមន៍កម្ពុជា បានចេញជា "សេចក្តីប្រកាស" ដែលចែងថា "ការតភ្ជាប់បណ្តាញអន្តរ-រវាងប្រតិបត្តិករទូរគមនាគមន៍ទាំងអស់ នឹងត្រូវបានតាមរយៈការជាមួយមជ្ឈមណ្ឌលកណ្តាលនៃទូរគមនាគមន៍កម្ពុជា[101]។ មួយចំណុច ផ្លាស់ប្តូរអ៊ីនធឺណេតដូចជាថា បានពិពណ៌នានៅក្នុង"ប្រកាស" ដើរតួនាទីដ៏សំខាន់នៅក្នុងការ ធ្វើឱ្យលំហូរពត៌មាននៅលើអ៊ីនធឺណេតដោយបញ្ចូលទិន្នន័យរវាងក្រុមហ៊ុន ផ្តល់សេវាអ៊ីនធឺណេត ដាច់ដោយឡែក។ នៅក្នុងប្រសិទ្ធិភាពប្រភេទនៃប្រព័ន្ធទាំងនេះអនុញ្ញាតឱ្យអ្នកប្រើជាមួយ ISP មួយ ដើម្បីចូលដំណើរតាមមាតិកាបង្ហោះដោយអ្នកផ្តល់សេវាផ្សេងទៀត។ ប្រកាសនេះ បានចែងថាក្រសួង នឹងតម្រូវឱ្យក្រុមហ៊ុនក្នុងស្រុកទោះសហការជាមួយក្រុមហ៊ុនទូរគមនាគមន៍កម្ពុជា ដែលជាក្រុមហ៊ុនរបស់រដ្ឋក្នុងនាមជាតម្រងកណ្តាល[102]។ នេះមានន័យថាអ៊ីនធឺណេតទាំងអស់ ដែលត្រូវបានប្រតិបត្តិការណ៍ ត្រូវបានគេបញ្ជូនតាមរយៈសាជីវកម្ម ដែលគ្រប់គ្រងដោយរដ្ឋ។ នេះដូចជាការប្រើប្រាស់អ៊ីនធឺណេត ដែលនឹងបានក្លាយជាភាពងាយស្រួលបន្ថែមទៀតក្នុងការត្រួតពិនិត្យ និងបានហាមឃាត់។

នៅថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១០ ទូរគមនាគមន៍កម្ពុជា បានចង្អុលបង្ហាញជាផ្លូវការថាក្រុមហ៊ុន ដែលគ្រប់គ្រងដោយរដ្ឋនឹងស្វែងរកការរារាំងការចូលដំណើរការគេហទំព័រថា វាជាការដែល"ត្រឹមត្រូវ" វាគួរតែត្រូវបានផ្តល់ការគ្រប់គ្រងដោយប្រទេសរបស់ក្នុងស្រុក និងការផ្លាស់ប្តូរអ៊ីនធឺណេតជាអន្តរជាតិ[103]។ លោកជិន ដារ៉ូ នាយករងនៃទូរគមនាគមន៍កម្ពុជា បានមាន

---

[100] មជ្ឈមណ្ឌលកម្ពុជាដើម្បីប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ, ការចោទប្រកាន់ពីបទបរិហារកេរ្តិ៍មកលើអ្នកប្រើប្រាស់ហ្វេសប៊ុកត្រូវបានទម្លាក់ចូល (សេចក្តីថ្លែងការណ៍, ២០១០)

[101] ការគ្រប់គ្រងបណ្តាញអ៊ីនធឺណេតដោយរដ្ឋ (សារពត៌មានភ្នំពេញប៉ុស្តិ៍, ២០១០)

[102] ដូចខាងលើ

[103] រដ្ឋាភិបាលផ្តោតលើគម្រោងគ្រប់គ្រងអ៊ីនធឺណេត (សារពត៌មានភ្នំពេញប៉ុស្តិ៍, ១៣ មេសា ២០១០)

ប្រសាសន៍ដែរថា "ប្រសិនបើទូរគមនាគមន៍ដើរតួក្នុងការផ្លាស់ប្តូរបាន វានឹងផ្តល់ប្រយោជន៍ដល់សង្គមកម្ពុជាដោយសារតែរដ្ឋាភិបាល មានការជឿទុកចិត្តនៅលើយើង ហើយយើងអាចត្រួតពិនិត្យការប្រើប្រាស់អ៊ីនធឺណេតបាន"[104]។ ទោះជាយ៉ាងណា មន្ត្រីមកពីក្រុមហ៊ុនផ្តល់សេវាកម្មអ៊ីនធឺណេតប្រតិបត្តិការនៅក្នុងប្រទេសកម្ពុជា បានព្រមានថា ការផ្តេរនេះ អាចរាំងស្ទះដល់ដំណើរឧស្សាហកម្មរបស់ប្រទេសកម្ពុជា ដោយបង្កើនការចំណាយ និងមានការតវ៉ាជាច្រើនដោយសារវានឹងអាចផ្តល់ឥទ្ធិពលច្រើនដល់រាជរដ្ឋាភិបាលលើការគ្រប់គ្រងបណ្តាញអ៊ីនធឺណេត[105]។ នៅថ្ងៃទី ១៣ ខែមេសា ឆ្នាំ២០១០ កាសែតភ្នំពេញប៉ុស្តិ៍ បានរាយការណ៍ថា រដ្ឋាភិបាល បានទម្លាក់ចោលផែនការរបស់ខ្លួនក្នុងការបង្កើតការផ្លាស់ប្តូរបណ្តាញអ៊ីនធឺណេត។ យោងតាមអ៊ីនធឺណេតរបស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍នេះ សំណើនេះ ត្រូវលែងត្រូវបានចាត់ទុកជាបានការនាខែមេសា ឆ្នាំ២០១០ បើទោះបីជាវា ត្រូវបានគេរាយការណ៍ថា តម្រូវការផ្តល់អាជ្ញាប័ណ្ណថ្មីអាចត្រូវបានបង្កើតឡើងនៅក្នុងពេលអនាគតក៏ដោយ[106]។

### ៣. ការរឹតបន្តឹងក្នុងច្បាប់ជាតិ

ទោះបីជាត្រូវបានការពារនៅក្នុងច្បាប់ជាតិ និងច្បាប់អន្តរជាតិក៏ដោយ សេរីភាពសារពត៌មាន អាចនឹងត្រូវបានច្បាប់ជាតិមួយចំនួនរួមមាន ច្បាប់របបសារពត៌មាន និងក្រមព្រហ្មទណ្ឌរឹតបន្តឹងតាមរយៈការអនុវត្តជាក់ស្តែង និងខណៈពេលច្បាប់ស្តីពីរបបសារពត៌មាន បានកំណត់ពីការការពារអ្នកសារពត៌មានក្នុងការអនុវត្តវិជ្ជាជីវៈរបស់ខ្លួននោះ ច្បាប់នេះតែងតែមិនត្រូវបានគេយកចិត្តទុកដាក់ ឬប្រើទាំងបំពាន។ មានឧទាហរណ៍ជាច្រើននៃការដាក់កម្រិត ដែលត្រូវបានដាក់នៅលើប្រព័ន្ធផ្សព្វផ្សាយបែបប្រពៃណីដោយរាជរដ្ឋាភិបាល ដោយមានការចោទប្រកាន់បទល្មើសព្រហ្មទណ្ឌប្រឆាំងនឹងអ្នកបោះពុម្ពផ្សាយកាសែត និងកម្មវិធីនិពន្ធ ដែលបានផ្សព្វផ្សាយពត៌មាន ចាត់ទុកថាជាការបង្ខូចរាជរដ្ឋាភិបាល និងគណបក្សប្រជាជន និងអ្នកកាសែតអ្នកនយោបាយគណបក្សប្រឆាំង និងអ្នកការពារសិទ្ធិមនុស្ស ដែលជាចុងចោទបានប្រឈមមុខនឹងការយាយីរាងកាយ ក៏ដូចជាការចោទប្រកាន់បទល្មើសព្រហ្មទណ្ឌ និងពិន័យហិរញ្ញវត្ថុសម្រាប់ទស្សនៈតាមរយៈប្រព័ន្ធផ្សព្វផ្សាយបែបប្រពៃណី។ ខណៈដែលច្បាប់សារពត៌មានឆ្នាំ១៩៩៥ ក្នុងមាត្រា២០ ចែងថា"មនុស្សមិនត្រូវបានចាប់ខ្លួន ឬចោទប្រកាន់បទល្មើសព្រហ្មទណ្ឌដែលបណ្តាលមកពីការបញ្ចេញមតិនោះទេ និង/ឬអ្នកនិពន្ធនិងអ្នកសារពត៌មាន ត្រូវបានចាប់ខ្លួន

[104] ដូចខាងលើ

[105] រដ្ឋាភិបាលផ្តោតលើគម្រោងគ្រប់គ្រងអ៊ីនធឺណេត (សារពត៌មានភ្នំពេញប៉ុស្តិ៍, ១៣ មេសា ២០១០)

[106] ដូចខាងលើ

និងចោទប្រកាន់ពីបទបរិហារកេរ្តិ៍ និង/ឬ ផ្សាយពត៌មានមិនពិតសម្រាប់ការបបង្ហាញទស្សនៈរិះគន់លើរដ្ឋាភិបាលលើគោលនយោបាយរបស់ពួកគេនោះទេ[107]។

រាជរដ្ឋាភិបាល បានប្រើប្រាស់ច្បាប់ព្រហ្មទណ្ឌ ដើម្បីត្រួតពិនិត្យ និងគ្រប់គ្រងលើការផ្សព្វផ្សាយពត៌មានជាសាធារណៈ។ មុនពេលអនុម័តនៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩ រដ្ឋាភិបាល តែងតែប្រើប្រាស់មាត្រា៦២ (ផ្សាយពត៌មានមិនពិត)[108] និង៦៣ (បទបរិហាកេរ្តិ៍ និងបង្ខូចកេរ្តិ៍)[109] នៃអាជ្ញាធរបណ្តោះអាសន្នរបស់អង្គការសហប្រជាជាតិនៅក្នុងប្រទេសកម្ពុជា (អ៊ុនតាក់) ដើម្បីនាំយកការចោទប្រកាន់បទល្មើសព្រហ្មទណ្ឌប្រឆាំងនឹងអ្នកកាសែតដែលមានអត្ថបទ ដែលបានសរសេរថា ជាអ្នករិះគន់រាជរដ្ឋាភិបាល ឬសមាជិកនៃពួកឥស្សរជននយោបាយ។ នៅក្នុងករណីម៉ុង រិទ្ធី និងលោកកែវ សុធា ក្នុងឆ្នាំ២០០២ កម្មវិធីនិពន្ធនៃកាសែតដែកទំនាក់ទំនងជាមួយអ្នកប្រឆាំង ត្រូវបានចោទប្រកាន់ពីបទបរិហាកេរ្តិ៍តាមមាត្រា៦៣នៃក្រមអ៊ុនតាក់នោះទេ ប៉ុន្តែមាត្រានោះ ត្រូវបានគេជំនួសដោយមាត្រា១០នៃច្បាប់ស្តីពីរបបសារពត៌មានឆ្នាំ១៩៩៥ ដែលកំណត់ចេញបទល្មើសស៊ីវិលនៃបទបរិហារកេរ្តិ៍[110]។ ដូច្នេះ គាត់បានអះអាងថា គាត់អាចប្រឈមមុខនឹងការចោទប្រកាន់ពីបទបរិហារតែមួយប៉ុណ្ណោះ។

ជាក់ស្តែង ទោះជាយ៉ាងណាគំរូនេះ មិនត្រូវបានអនុវត្តនៅក្នុងករណីជាបន្តបន្ទាប់ជាមួយនឹងឧទាហរណ៍ថ្មីបំផុតក្នុងករណីលោកហង្ស ចក្រា ជាអ្នកបោះពុម្ពផ្សាយរបស់គណបក្សប្រឆាំងនៃកាសែត "ខ្មែរម្ចាស់ស្រុក" ។ គាត់ត្រូវបានគេចាប់ខ្លួននៅថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០០៩បន្ទាប់ពីកាសែតរបស់លោក បានបោះពុម្ពផ្សាយនូវអត្ថបទជាច្រើន ដែលចោទប្រកាន់ជំនួយការលោកឧបនាយករដ្ឋមន្ត្រីសុខ អាន ក្នុងរឿងពុករលួយ[111]។ បន្ទាប់ពីលោកហង្ស ចក្រា បានបដិសេធពីប្រភពរបស់លោកនាំឱ្យមានការបដិសេធ ក្នុងការអនុញ្ញាតឱ្យគាត់ស្ថិតនៅក្រោមមាត្រា២នៃច្បាប់ស្តីពីប្រកាសពត៌មានមួយលោក ត្រូវបានផ្តន្ទាទោសពីបទផ្សាយពត៌មានមិនពិតតាមមាត្រា៦២នៃក្រមព្រហ្មទណ្ឌអន្តរកាល ហើយត្រូវបានផ្តន្ទាទោសជាបន្តបន្ទាប់ជាមួយឆ្នាំនៅក្នុងពន្ធនាគារ និងបង្គាប់ឱ្យបង់ប្រាក់ពិន័យជាប្រាក់ពី៩.០០០.០០០រៀល (២២៥០ដុល្លាសហរដ្ឋអាមេរិក)។ បន្ទាប់មកលោក ត្រូវបានដោះលែងពីពន្ធនាគារកាលពីឆ្នាំ២០១១ ខ្មែរម្ចាស់ស្រុកបានប្រកាសថាពួកគេត្រូវបានចាប់ផ្តើមប្រតិបត្តិការណ៍របស់ពួកគេ។

---

[107] ច្បាប់ស្តីពីរបបសារពត៌មាន, នស/រកម/០៨៩៥/០០៧, ចុះថ្ងៃទី០១ ខែកញ្ញា ឆ្នាំ១៩៩៥ មាត្រា២០

[108] ច្បាប់ព្រហ្មទណ្ឌអន្តរកាល ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ១៩៩២ មាត្រា៦២

[109] ច្បាប់ព្រហ្មទណ្ឌអន្តរកាល ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ១៩៩២ មាត្រា៦៣

[110] ច្បាប់ស្តីពីរបបសារពត៌មាន, នស/រកម/០៨៩៥/០០៧, ចុះថ្ងៃទី០១ ខែកញ្ញា ឆ្នាំ១៩៩៥ មាត្រា១០

[111] លីកាដូ, សេរីភាពខាងការបញ្ចេញមតិនៅកម្ពុជា: ប្រជាធិបតេយ្យថ្លិនភ្នែក (របាយការណ៍លីកាដូ, ២០១០) ថតចម្លងថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០១៦

មិនតែប៉ុណ្ណោះបណ្តាសង្គមស៊ីវិលមួយចំនួន បានរិះគន់ទៅលើក្រមព្រហ្មទណ្ឌថ្មីថា បានគាបសង្កត់ និងហាក់បីដូចជាបានរឹតត្បឹតនូវសេរីភាពបញ្ចេញមតិជាងក្រមព្រហ្មទណ្ឌអន្តរកាល។ ជាក់ស្តែងអង្គការក្រៅរដ្ឋាភិបាលមួយឈ្មោះថា លីកាដូ (LICADHO) បានធ្វើការប្រៀបធៀប និងបង្ហាញពីគម្លាតខុសគ្នារវាងច្បាប់ព្រហ្មទណ្ឌអន្តរកាល និងក្រមព្រហ្មទណ្ឌថ្មីដូចខាងក្រោម[112]៖

| **បទល្មើស** | **ក្រមព្រហ្មទណ្ឌអន្តរកាល** | **ក្រមព្រហ្មទណ្ឌថ្មី** |
|---|---|---|
| បទបរិហារកេរ្តិ៍ | មាត្រា៦៣ | មាត្រា៣០៥ |
| បទល្មើសពត៌មានមិនពិត | មាត្រា៦២ | មិនមាន |
| បទជេរប្រមាថជាសាធារណៈ | មាត្រា៦៣ | មាត្រា៣០៧ |
| បទប្តឹងបរិហារបង្កាច់កេរ្តិ៍ | មិនមាន | មាត្រា៣១១ |
| បទញុះញង់ឱ្យប្រព្រឹត្តបទឧក្រិដ្ឋជាអាទិ៍ | មាត្រា៥៩-៦០ | មាត្រា៤៩៥ |
| បទញុះញង់ឱ្យមានការរើសអើង | មាត្រា៦១ | មាត្រា៤៩៦ |
| បទប្រមាថ | មិនមាន | មាត្រា៥០២ |
| បទផ្សព្វផ្សាយនូវការអត្ថាធិប្បាយដើម្បីធ្វើសម្ពាធលើយុត្តាធិការ | មិនមាន | មាត្រា៥២២ |
| បទធ្វើឱ្យបាត់ជំនឿលើសេចក្តីសម្រេចរបស់តុលាការ | មិនមាន | មាត្រា៥២៣ |
| បទបរិហារដោយភូតកុហកដល់អាជ្ញា-ធរតុលាការ | មិនមាន | មាត្រា៥២៤ |
| **ចំនួនបទឧក្រិដ្ឋ** | **៥** | **៩** |

បទបញ្ញត្តិនៃក្រមព្រហ្មទណ្ឌថ្មីនៃព្រះរាជាណាចក្រកម្ពុជា បានចូលជាធរមាននៅថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០១០។ ច្បាប់នេះ មានលក្ខណៈខុសគ្នាពីចំណុច គឺបទបញ្ញត្តិពីបទផ្សាយពត៌មានមិនពិតត្រូវបានលប់ចេញ ហើយក្រមនេះត្រូវឱ្យមានការដោះស្រាយករណីបទបរិហារកេរ្តិ៍ដោយប្រើប្រាស់ច្បាប់របបសារពត៌មានវិញ។ ប៉ុន្តែ ក្រមថ្មីនេះក៏មានបន្ថែមនូវ៩ចំណុចថ្មីទៀតផងដែរ។ អង្គការលីកាដូ បានរកឃើញបទឧក្រិដ្ឋចំនួន៩ រួមទាំងបទបញ្ញត្តិថ្មីចំនួន៥ ដែលចង្អុលបង្ហាញពីការគំរាមកំហែងយ៉ាងធ្ងន់ធ្ងរចំពោះសេរីភាពក្នុងការបញ្ចេញមតិនៅកម្ពុជា។ បញ្ញត្តិខ្លះគ្រាន់តែ

[112] លីកាដូ, សេរីភាពខាងការបញ្ចេញមតិនៅកម្ពុជា: ប្រជាធិបតេយ្យថ្មិនភ្នែក (របាយការណ៍លីកាដូ, ២០១០) ថតចម្លងថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០១៦

បង្ហាញនូវសក្តានុពលចំពោះការរំលោភបំពាន ចំណែកបញ្ញត្តិខ្លះទៀតបង្ហាញយ៉ាងជាក់ស្តែង ដូចជា ការហាមឃាត់លើការរិះគន់សេចក្តីសម្រេចរបស់តុលាការ និងសេចក្តីថ្លែងការណ៍ ជាសាធារណៈ ដែលបង្ហាញឱ្យកើតមានកោលាហលក្នុងសង្គម។ ចុងក្រោយក៏លេចចេញជាបទបញ្ញត្តិដែលមានលក្ខណៈរឹតបន្តឹងកាន់តែខ្លាំង ចំពោះបទផ្សាយពត៌មានមិនពិតក្រោមច្បាប់ព្រហ្មទណ្ឌអន្តរកាល។ ក្រមថ្មីនេះក៏តម្រូវឱ្យបង់ប្រាក់ជាចាំបាច់ និងបន្ថែមរបៀបនៃការដាក់ទោសទណ្ឌបន្ថែមដោយព្យួរសិទ្ធិពលរដ្ឋដោយមិនកំណត់ពេលវេលាច្បាប់លាស់ តាមរយៈការដកហូតសិទ្ធិមិនឱ្យបំពេញការងារ។

មិនតែប៉ុណ្ណោះរដ្ឋាភិបាល កំពុងធ្វើការលើសេចក្តីព្រាងច្បាប់ស្តីពីសមាគម និងអង្គការដែលមានបញ្ញត្តិទូលាយ និងមិនច្បាស់លាស់ ដែលអាចត្រូវបានប្រើប្រាស់តាមទំនើងចិត្ត ដើម្បីបដិសេធការចុះបញ្ជី ឬបិទអង្គការ ឬសមាគម ហើយច្បាប់នេះតម្រូវឱ្យសមាគម និងអង្គការទាំងអស់ ត្រូវចុះឈ្មោះមុននឹងត្រូវអនុញ្ញាតឱ្យអនុវត្តសកម្មភាពនៅប្រទេសកម្ពុជា។ បន្ថែមពីលើសនោះ ដំណើរការចុះបញ្ជីមិនមានការគាំពារ និងតម្លាភាពនោះទេ[113]។ លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បានព្យួរសេចក្តីព្រាងច្បាប់ស្តីពីសមាគម និងអង្គការក្នុងខែធ្នូ ឆ្នាំ២០១១ បន្ទាប់ពីមានការតវ៉ាពីបណ្តាសហគមន៍ជាតិ និងអន្តរជាតិ ប៉ុន្តែសេចក្តីព្រាងច្បាប់នេះ មិនត្រូវបានលុបចោលទាំងស្រុងនោះទេ ហើយជាប្រហែលជាអាចនឹងត្រឡប់ចូលមកក្នុងរបៀបវារៈផ្នែកច្បាប់ បន្ទាប់ពីរដ្ឋាភិបាលថ្មីបានស្បថចូលកាន់តំណែង។ ទោះបីជាការពិតសេចក្តីព្រាងច្បាប់នេះ ត្រូវបានទុកចោលវត្តមាននៃសេចក្តីព្រាងច្បាប់នេះ គឺជាការគំរាមកំហែងដ៏ធ្ងន់ធ្ងរមកលើសេរីភាពនៃការធ្វើសមាគម និងសេរីភាពបញ្ចេញមតិរបស់សង្គមស៊ីវិលរបស់កម្ពុជា។

### ៤. ការរឹតបន្តឹងលើស្ថាប័នផ្សេងៗ

### -សង្គមស៊ីវិលនៅកម្ពុជា

បើយោងតាមអង្គការសហប្រជាជាតិ បានឱ្យនិយមន័យអង្គការសង្គមស៊ីវិលថា "សមាគមប្រជាពលរដ្ឋ(ក្រៅពីក្រុមគ្រួសារ មិត្តភក្តិ និងអ្នកធ្វើជំនួញរួមគ្នា) ចូលរួមក្នុងសកម្មភាពស្ម័គ្រចិត្ត ដើម្បីអភិវឌ្ឍផលប្រយោជន៍ គំនិត និងមនោគមវិទ្យា។ ពាក្យនេះ មិនរាប់បញ្ចូលសកម្មភាព រកប្រាក់ចំណេញ (វិស័យឯកជន) ឬរដ្ឋាភិបាល (វិស័យសាធារណៈ)"[114]។ សង្គមស៊ីវិលរួមមានបណ្តា

---

[113] មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា, សេចក្តីព្រាងច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល (សលាក្រប័ត្រពតិមាន, ២០១១) http://www.cchrcambodia.org/index_old.php?url=media/media.php&p=factsheet_detail.php&fsid=1&id=5 (ថតចម្លងថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១៦)

[114] ក្រុមប្រឹក្សានៃអេមីនេន ភើសុន ស្តីពីទំនាកទំនងសង្គមស៊ីវិល និងអង្គការសហប្រជាជាតិ, យើងជាប្រជាពលរដ្ឋៈ សង្គមស៊ីវិល អង្គការសហប្រជាជាតិ និងអភិបាលកិច្ចសកល (កិច្ចប្រជុំទី៥៨ ថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០០៤, ឯកសាររបស់អង្គការសហប្រជាជាតិ A/៥៨/៨១៧),

អង្គការសង្គមស៊ីវិល អង្គការមិនមែនរដ្ឋាភិបាល សហជីព និងស្ថាប័នសាសនា ក៏ដូចជាសកម្មជនដែលជាបុគ្គលផងដែរ។

ដោយអនុលោមតាមរដ្ឋធម្មនុញ្ញមាត្រា៣៥ បានបង្កើតឪកាសសម្រាប់ឱ្យប្រជាពលរដ្ឋដើរតួនាទីយ៉ាងសកម្មក្នុងសង្គមកម្ពុជា និងដំណើរការលទ្ធិប្រជាធិបតេយ្យ[115]។ សិទ្ធិចូលរួមយ៉ាងសកម្មក្នុងជីវភាពនយោបាយ សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌របស់ប្រទេសជាតិ និងមាត្រា៤១ ស្តីពីសិទ្ធិសេរីភាពបញ្ចេញមតិ និងការជួបប្រជុំ និងសិទ្ធិសេរីភាពធ្វើសមាគម[116] ក្នុងមាត្រា៤២ គឺមានសារៈសំខាន់សម្រាប់សង្គមស៊ីវិលឯករាជ្យ អាចរីកលូតលាស់បាន[117]។ បើយោងតាមគណៈកម្មាធិការសហប្រតិបត្តិការណ៍ដើម្បីកម្ពុជាមកទល់ខែមិនា ឆ្នាំ២០១២ មានអង្គការសង្គមស៊ីវិល ដែលបានចុះបញ្ជីចំនួន៣,៤៩២ នៅកម្ពុជារួមមានអង្គការជាតិ និងអន្តរជាតិផងដែរ[118]។ ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) បានកត់សម្គាល់ថា រដ្ឋាភិបាល បានបង្ហាញឆន្ទៈគួរឱ្យសរសើរ ក្នុងការធ្វើការរួមជាមួយសង្គមស៊ីវិលលើការផ្តល់សេវាកម្ម ជាពិសេសវិស័យកសិកម្ម អប់រំ និងសុខភាព។ ប៉ុន្តែរដ្ឋាភិបាល ហាក់បីដូចជាចាត់ទុកថា អង្គការសង្គមស៊ីវិល និងសកម្មជនដែលតស៊ូមតិឱ្យមានកំណែទម្រង់ផ្នែកច្បាប់ ឬផ្នែកនយោបាយថាជាក្រុមប្រឆាំង។ មិនតែប៉ុណ្ណោះ កម្មវិធីអភិវឌ្ឍន៍នៃអង្គការសហប្រជាជាតិ បានលើកឡើងនូវការព្រួយបារម្ភក្នុងរបាយការណ៍ស្តីពីសង្គមស៊ីវិលនៅកម្ពុជាឆ្នាំ២០១០ ដែលបានអះអាងថា ទំនាក់ទំនងរវាងសង្គមស៊ីវិល និងរដ្ឋក្លាយជាក្រុមប្រឆាំងពេលដែលសង្គមស៊ីវិល ដើរតួជាអ្នកតស៊ូមតិ និងអ្នកឃ្លាំមើល។ ទំនាក់ទំនងបែបប្រឆាំងនេះ បានបង្កជាបញ្ហាសម្រាប់អង្គការសង្គមស៊ីវិល និងសកម្មជន។ ពួកគេ ត្រូវបង្ខំឱ្យប្រឈមមុខនឹងមជ្ឈដ្ឋានមួយ ដែលការរិះគន់ជាសាធារណៈលើគោលនយោបាយរបស់រដ្ឋាភិបាល ត្រូវបានបកស្រាយថាមិនមែនជាការអនុវត្តសិទ្ធិសេរីភាពបញ្ចេញមតិដោយស្របច្បាប់ និងជាការធ្វើឱ្យមានការសន្ទនាបែបស្ថាបនានោះទេ តែបែរមើលឃើញថា ជាការវាយប្រហារលើរដ្ឋាភិបាលលើទៅវិញ។

### ៤.១. ការរឹតបន្តឹងលើសង្គមស៊ីវិល

http://daccess-dds-ny.un.org/doc/UNDOC/GEN/N04/374/41/PDF/N0437641.pdf?OpenElement (ថតចម្លងថ្ងៃទី១២ ខែឧសភា ឆ្នាំ២០១៦

[115] រដ្ឋធម្មនុញ្ញ លេខ នស/រកស/០៧០៤/០០១ ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ១៩៩៣ មាត្រា៣៥

[116] រដ្ឋធម្មនុញ្ញ លេខ នស/រកស/០៧០៤/០០១ ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ១៩៩៣ មាត្រា៤១

[117] រដ្ឋធម្មនុញ្ញ លេខ នស/រកស/០៧០៤/០០១ ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ១៩៩៣ មាត្រា៤២

[118] គណៈកម្មាធិការសហប្រតិបត្តិការណ៍ដើម្បីកម្ពុជា, ការរួមចំណែករបស់សង្គមស៊ីវិលដើម្បីការអភិវឌ្ឍនៅកម្ពុជា
htt:/www.ccc-cambodia.org/downloads/publication/CCC-CSO%20Contribution%20Report.pdf (ថតចម្លងថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០១៦)

### ៤.១.១. ការរំខានដល់សកម្មភាពរបស់អង្គការសង្គមស៊ីវិល

ទោះបីជាអង្គការសង្គមស៊ីវិល មានសេរីភាពមួយចំនួន ដែលអាចធ្វើប្រតិបត្តិការណ៍នៅកម្ពុជា ប៉ុន្តែមានករណីមួយចំនួន ដែលបង្ហាញពីការបង្ក្រាបមកលើសកម្មភាពរបស់អង្គការសង្គមស៊ីវិលក្នុងឆ្នាំ២០១២ និង២០១៣ដែលបានរឹតបន្តឹងលើសេរីភាពបញ្ចេញមតិសេរីភាពធ្វើសមាគម និងការជួបប្រជុំ។

ជាក់ស្តែង នៅក្នុងឆ្នាំ២០១២ កំឡុងពេល៥ថ្ងៃនៃកិច្ចប្រជុំកំពូលអាស៊ាន ដែលត្រូវបានប្រារព្ធឡើងនៅទីក្រុងភ្នំពេញ អាជ្ញាធរមូលដ្ឋាន បានដាក់គំនាបលើអាជីវកម្មក្នុងស្រុក គឺសណ្ឋាគារឡាក់គីស្ការ ដើម្បីរំខានដល់សិក្ខាសាលាចំនួន៤ ដែលត្រូវបានរៀបចំជាផ្នែកមួយនៃសន្និសីទសង្គមស៊ីវិលអាស៊ាន/វេទិកាប្រជាជនអាស៊ាន[119]។ សិក្ខាសាលា ត្រូវបានរៀបចំឡើង ដើម្បីផ្តោតការយកចិត្តទុកដាក់លើប្រធានបទ ដែលមានលក្ខណៈរសើបផ្នែកនយោបាយ ដូចជាជម្លោះដីធ្លី ការបណ្តេញចេញដោយបង្ខំ និងបញ្ហាបរិស្ថាន។ ដោយមានការជ្រៀតជ្រែកពីរដ្ឋាភិបាល អង្គការសង្គមស៊ីវិល ដែលបានពាក់ព័ន្ធ ត្រូវបានបង្ខំឱ្យស្វែករកទីតាំងថ្មី ក្នុងរយៈពេលបន្ទាន់បំផុត ជាលទ្ធផល សិក្ខាសាលាមួយចំនួន ត្រូវបានលុបចោល។ ក្រោយមកក្នុងឆ្នាំដដែល សន្និសីទសង្គមស៊ីវិល អាស៊ាន/វេទិកាប្រជាជនអាស៊ាន នៅថ្ងៃទី១៤ ដល់ ១៦ ខែវិច្ឆិកា ជាពេលវេលាមួយស្របជាមួយនឹងកិច្ចប្រជុំកំពូលអាស៊ានមួយទៀត ត្រូវបានរំខានដោយអាជ្ញាធរមូលដ្ឋាន ដែលបានធ្វើឱ្យម្ចាស់ទីតាំងចំនួនពីរបដិសេធមិនព្រមផ្តល់ទីតាំងសម្រាប់ធ្វើកម្មវិធី[120]។

### ៤.១.២. ការសម្លុតបំភ័យមកលើតួអង្គសង្គមស៊ីវិល

តុលាការ តែងតែត្រូវបានប្រើទាំងបំពាន ដើម្បីជាឧបករណ៍បំបិទមាត់ បុគ្គលិកអង្គការ និងសកម្មជនសិទ្ធិមនុស្ស។

---

119 មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា, មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជាសម្តែងការសោកស្តាយចំពោះការបង្ក្រាបលើសេរីភាពមូលដ្ឋាន និងការបំបិទមាត់សង្គមស៊ីវិលក្នុងអំឡុងកិច្ចប្រជុំកំពូលអាស៊ាន (សេចក្តីថ្លែងការណ៍, ២០១២) http://www.cchrcambodia.org/index_old.php?url=media/media.php&p=press_detail.php&prid=237&id=5 (ថតចម្លងថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៦

120 មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា, អាជ្ញាធរកម្ពុជារាំងកម្មវិធីចំនួនពីររបស់សង្គមស៊ីវិលដែលមានគម្រោងរៀបចំស្របជាមួយនឹងកិច្ចប្រជុំកំពុលអាស៊ាន និងការគំរាមចាប់ខ្លួនអ្នកធ្វើបាតុកម្មណាមួយ ក្នុងអំឡុងពេលទស្សនកិច្ចផ្លូវការរបស់ប្រធានាធិបតីអាមេរិកលោក បារ៉ាក់ អូបាម៉ា (សេចក្តីប្រកាសពត៌មានបន្ទាន់គម្រោងសេរីភាពបញ្ចេញមតិ, ២០១២) http://www.cchrcambodia.org/index_old.php?url=media/media.php&p=alert_detail.php&alid=34&id=5 (ថតចម្លងថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១៦)

ជាក់ស្តែង សកម្មជន សិទ្ធិលំនៅដ្ឋាន អ្នកស្រីយ៉ោម បុប្ផា ជាអ្នកតំណាងរបស់សហគមន៍បឹងកក់ដ៏ល្បីឈ្មោះនៅទីក្រុងភ្នំពេញ ជាជនរងគ្រោះនៃជម្លោះដីធ្លីដ៏រ៉ាំរ៉ៃជាមួយនឹងក្រុមហ៊ុនរបស់បុគ្គលមានអំណាច និងមានទំនាក់ទំនងជាមួយរដ្ឋាភិបាល គឺក្រុមហ៊ុនស៊ូកាគូ អ៊ីន។ អ្នកស្រីយ៉ោម បុប្ផា បានក្លាយជាអ្នកតស៊ូមតិជួរមុខ ដើម្បីធ្វើការតស៊ូក្នុងសហគមន៍របស់លោកស្រីក្នុងឆ្នាំ២០១២ ពេលដែលអ្នកស្រី បានធ្វើការទាមទារឱ្យដោះលែងសកម្មជនសហគមន៍បឹងកក់ចំនួន១៣នាក់ ដែលជាប់ពន្ធនាគារក្នុងបទជាប់មួយដែលត្រូវបានរៀបចំឡើង។ អ្នកស្រីយ៉ោម បុប្ផា តែងតែរកការគំរាមកំហែងដោយមន្ត្រីប៉ូលីសដោយបានប្រាប់អ្នកស្រីថា អ្នកស្រីជាមនុស្សបន្ទាប់ ដែលគារនឹងចាប់ខ្លួន។ កាលពីថ្ងៃទី៤ ខែកញ្ញា អ្នកស្រីត្រូវបានចាប់ខ្លួន និងចោទប្រកាន់រួមជាមួយនឹងស្វាមីរបស់អ្នកស្រីពីបទ "អំពើហិង្សាដោយចេតនាមានស្ថានភាពទម្ងន់ទោស"[121] ។

### **៤.១.៣. ការប្រើអំពើហិង្សាមកលើតួអង្គសង្គមស៊ីវិល**

ក្នុងឆ្នាំ២០១២ មានការកើនឡើងនៃការប្រើប្រាស់អំពើហិង្សា ជាឧបករណ៍ ដើម្បីគ្រប់គ្រងលើសង្គមស៊ីវិល និងគាបសង្កត់លើសេរីភាពបញ្ចេញមតិ។ អំពើហិង្សា ជាហានិភ័យស្របច្បាប់សម្រាប់សមាជិកសង្គមស៊ីវិល ជាពិសេសសកម្មជនមូលដ្ឋានជាញឹកញាប់ បានចូលក្នុងបាតុកម្មដោយសន្តិវិធី ដែលត្រូវអាជ្ញាធររារាំងដោយប្រើអំពើហិង្សា។ ចន្លោះពីខែវិច្ឆិកា ឆ្នាំ២០១១ ដល់ខែធ្នូ ឆ្នាំ២០១២ យ៉ាហោចណាស់មាន៩ករណី ដែលមន្ត្រីយោធា បានបាញ់ប្រហារមកលើក្រុមបាតុករ ជាពិសេសសហជីព និងសកម្មជនសិទ្ធិដីធ្លី[122]។ ការគំរាមកំហែងប្រព្រឹត្តអំពើហិង្សាក៏ត្រូវបានអាជ្ញាធរប្រើប្រាស់ជាទៀងទាត់ ដើម្បីបំបិទមាត់សកម្មជន និងបុគ្គលិកអង្គការផងដែរ។

ជាកស្តែង កាលពីថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១២ សកម្មជនបរិស្ថានដ៏ល្បីឈ្មោះរបស់កម្ពុជាលោកឈុត វុទ្ធី ត្រូវបានមន្ត្រីយោធាបាញ់សំលាប់ក្នុងខេត្តកោះកុងខណៈពេលដែលលោកថតយកសកម្មភាពកាប់ឈើខុសច្បាប់[123]។ លោកឈុត វុទ្ធី បានអមដំណើរអ្នកសារពត៌មាន២នាក់

[121] មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា, ការវិភាគផ្នែកច្បាប់នៃការចោទប្រកាន់ និងការផ្តន្ទាទោសមកលើសកម្មជនដីធ្លីអ្នកស្រីយ៉ោម បុប្ផា (២០១៣) http://www.cchrcambodia.org/index_old.php?url=media/media.php&p=analysis_detail&anid=35&id=5 (ថតចម្លងថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១៦)

[122] លីកាដូ, សិទ្ធិមនុស្សឆ្នាំ២០១២៖ ឆ្នាំក្នុងការត្រួតពិនិត្យឡើងវិញ (របាយការណ៍ទាំងមូល, ២០១៣) http://www.licadho-cambodia.org/reports/flies/176LICADHOReportHumanRightsReview2012English.pdf (ថតចម្លងថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១៦)

[123] ម៉ៃ ទិត្យថារ៉ា និងដេវីដ ប៊ិល, សកម្មជនបរិស្ថាន លោក ឈុត វុទ្ធីត្រូវបានបាញ់សម្លាប់ (សារពត៌មាន ឌឹ ភ្នំពេញប៉ុស្តិ៍, ២០១២)

ពេលនោះរថយន្តរបស់លោកត្រូវបានមន្ត្រីយោធាបញ្ឈប់ ហើយបញ្ជាឱ្យលោកប្រគល់មេម៉ូរីកាត (Memory Card) ពីកាមេរ៉ារបស់លោក តែលោកបដិសេធក្រោយមកលោកក៏ ត្រូវបានគេបាញ់សំលាប់។ មន្ត្រីយោធាលោកអ៊ីន រតនា ក៏ត្រូវបានសំលាប់ក្នុងហេតុការណ៍នោះដែរ។ អ្នកសារពត៌មានទាំងពីរ ត្រូវបានឃុំខ្លួនក្រោយមកក៏បានឮពួកយោធានោះពិគ្រោះគ្នាតែសំលាប់ពួកគេដើម្បីបំបិទមាត់[124]។ សំណាងល្អ ដែលក្រោយមកពួកគេទាំងពីរត្រូវបានដោះលែង។

http://www.phnompenhpost.com/2012042655803/National/environment-activist-chut-wutty-shot-dead.html (ថតចម្លងថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១៦)

124 អូលេសៀ ផ្លុកគី, ការសម្លាប់ក្នុងព្រៃ (រ៉យទ័រស៍, ២០១២) http://blogs.reuters.com/great-debate/2012/09/02/murders-in-the-forest (ថតចម្លងថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១៦)

# សេចក្តីសន្និដ្ឋាន

សេរីភាពក្នុងការបញ្ចេញមតិ គឺជាមូលដ្ឋានគ្រឹះនៃលទ្ធិប្រជាធិបតេយ្យ ដែលបានចូលរួមចំនែកយ៉ាងសកម្ម ក្នុងការធ្វើអោយមានដំណើរការល្អផ្នែកការពារ និងការគោរពសិទ្ធិមនុស្សតាមរយៈការប្រើប្រាស់នូវមធ្យោបាយបញ្ចេញសំខាន់ៗ។ មុនងារនៃសេរីភាពនេះរួមមាន ការបង្កើតនូទំនាក់ទំនងការចូលរួមពីប្រជាពលរដ្ឋការទទួលខុសត្រូវខ្ពស់ និងការសំរេចចិត្តធ្វើអោយមានតម្លាភាព នៅក្នុងសង្គមនឹងនាំកម្ពុងឆ្ពោះទៅរកសង្គមប្រជាធិបតេយ្យមួយ។ ដូចគ្នានឹងសិទ្ធិសេរីភាពដទៃទៀតដែរ សេរីភាពក្នុងការបញ្ចេញមតិមិនអាចប្រើប្រាស់ដោយប្រាសចាកពីព្រំដែនកំនត់របស់ច្បាប់បានឡើយ។ ការកំរិតផ្នែកទៅលើទស្សនៈពិសេសមួយចំនួន ដែលគេឃើញកំនត់ក្នុងរដ្ឋធម្មនុញ្ញានៃព្រះរាជាណាចក្រកម្ពុជាចំពោះសេរីភាពនេះ គឺដើម្បីការពារសិទ្ធិ និងសេចក្តីថ្លៃថ្នូរបស់អ្នកដទៃការពារប្រពៃណីល្អរបស់សង្គមច្បាប់ និងសណ្តាប់ធ្នាប់សាធារណៈ និងការពារសន្តិសុខជាតិ។ ទោះជាយ៉ាងណាការកំរិតផ្សេងៗទៅលើសេរីភាពនេះ ត្រូវតែមានធម្មនុញ្ញាភាពរបស់ខ្លួនព្រមទាំងមានភាពសមាមាត្រ ដែលគេត្រូវតែថ្លឹងថ្លែងមើលពីភាពសមស្របនិងភាពស្របច្បាប់នៃការដាក់កំរិតទាំងនេះ។

ការអនុវត្តសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិបច្ចុប្បន្នហាក់ដូចជា មានចំនុចវិជ្ជមានផងអវិជ្ជផង។ ថ្វីបើមានច្បាប់ជាតិ និងអន្តរជាតិជាច្រើនការពារសេរីភាពនេះយ៉ាងទូលំទូលាយក៏ដោយក៏ករណីរំលោភសិទ្ធិមនុស្សនៅតែកើតមានជាហូរហែរក្នុងសង្គមស្របគ្នានឹងយន្តការការពារសិទ្ធិមនុស្សរបស់រដ្ឋាភិបាលរដ្ឋសភាព្រឹទ្ធសភា មិនមានប្រសិទ្ធភាពគ្រប់គ្រាន់ និងខ្វះឆន្ទៈក្នុងការធ្វើសកម្មភាពក្នុងវិស័យនេះ។ ប្រព័ន្ធតុលាការ ដែលជាក្តីសង្ឃឹមរបស់ប្រជាពលរដ្ឋត្រូវគេមើលឃើញថាមានឱនភាព និងគ្មានអព្យាក្រឹត្យ។ការខិតខំប្រឹងប្រែងរបស់រដ្ឋាភិបាល ដើម្បីធ្វើកំណែទំរង់ផ្សេងៗ រួមទាំងកំណែទំរង់ប្រព័ន្ធយុត្តិធម៌ផងនោះ បានកំពុងនាំកម្ពុជាឆ្ពោះទៅរកលទ្ធិប្រជាធិបតេយ្យ ប៉ុន្តែបែរជាមានដំណើរធាក់ថយក្រោយវិញ ក្នុងពេលដែលមានភាចំរូងចំរាសថ្មីចុងក្រោយស្តីពីការដកអភ័យឯកសិទ្ធិសភាពពីតំណាងរាស្ត្របីរូបរបស់គណបក្សប្រឆាំង។

ការអនុវត្តសេរីភាពក្នុងការបញ្ចេញមតិ ត្រូវបានប្រឈមមុខនឹងការទទួលខុសត្រូវផ្សេងៗដោយសារមធ្យោបាយនានានៃការប្រើប្រាស់សេរីភាពនេះដែរគេមើឃើញថារំលោភទៅលើកេរ្តិ៍ឈ្មោះ និងសេចក្តីថ្លៃថ្នូររបស់អ្នកដទៃ ឬពាក់ព័ន្ធទៅនឹងការមិនគោរសីលធម៌វិជ្ជាជីវៈរបស់អ្នកសារពត៌មានខ្លួនឯង។ ការទទួលខុសត្រូវសំខាន់ៗមានការទទួលខុសត្រូវព្រហ្មទណ្ឌរដ្ឋប្បវេណីរដ្ឋបាល។ ស្របពេលគ្នានឹងមានការទទួលខុសត្រូវនេះ គេពិនិត្យឃើញមានផលវិបាកមួយចំនួនដែលកើតចេញពីការអនុវត្តសេរីភាពក្នុងការបញ្ចេញមតិ។ ផលវិបាកទាំងនេះ អាចជាការភ័យខ្លាចចំពោះសន្តិសុខផ្ទាល់ខ្លួនការគំរាមកំហែងការសំលាប់ ការចាប់ឃុំខ្លួនការអនុវត្តច្បាប់ធូររលុង និងការខ្វះខាតច្បាប់ដើម្បីអនុវត្តពិសេសច្បាប់ស្តីពីសេរីភាពទទួលពត៌មាន ដែលតំរូវការចាំបាច់របស់ប្រជាពលរដ្ឋ។ កត្តាអន់ថយមួយចំនួនដែលជាឧបសគ្គសំរាប់សេរីភាពក្នុងការបញ្ចេញមតិនេះដែរ គឺភាពក្រីក្រកំរិតយល់ដឹងទាបរបស់ប្រជាពលរដ្ឋអំពើពុករលួយប្រព័ន្ធផ្សព្វផ្សាយមានភាពលំអៀង។

ដោយមានទស្សនៈវិស័យដោយសុទិដ្ឋិនិយម ខ្ញុំមានក្តីសង្ឃឹម និងជឿជាក់ថាកម្ពុជានឹងធ្វើដំណើរឆ្ពោះទៅរកលទ្ធិប្រជាធិបតេយ្យពិតប្រាកដ បើប្រជាពលរដ្ឋអង្គការសង្គមស៊ីវិល និងរដ្ឋាភិបាលរួមគ្នាអនុវត្តច្បាប់អោយមានប្រសិទ្ធិភាព។ ពិសេសជាងនេះទៅទៀតតម្លាភាព និងនីតិរដ្ឋនឹងកើតមានយ៉ាងប្រត្យក្សក្នុងសង្គមកម្ពុជានាពេលអនាគតដ៏ខ្លីជាមិនខាន។

# អនុសាសន៍

យោងទៅតាមស្ថានភាពនាពេលបច្ចុប្បន្ននៅក្នុងប្រទេសកម្ពុជា យើងសង្កេតឃើញថា ការបញ្ចេញមតិរបស់ប្រជាពលរដ្ឋនៅមានកម្រិតនៅឡើយ បើទោះបីជាមានការចូលរួមពីប្រព័ន្ធផ្សព្វផ្សាយ អង្គការសង្គមស៊ីវិល និងអង្គការដែលជាប់ទាក់ទងជាច្រើនយ៉ាងណាក៏ដោយ។ ដូច្នេះ ក្នុងនាមខ្ញុំ ជាពលរដ្ឋខ្មែរមួយ ដែលចង់ឱ្យប្រទេសកម្ពុជាមានសុខសន្តិភាព ភាពសម្បូរសប្បាយ ការរីកចំរើន និងមានលទ្ធិប្រជាធិបតេយ្យពិតប្រាកដ ខ្ញុំសូមផ្តល់អនុសាសន៍មួយចំនួនទៅដល់ រាជរដ្ឋាភិបាលកម្ពុជា ប្រព័ន្ធផ្សព្វផ្សាយ និងអង្គការសម្គមស៊ីវិល ដើម្បីធ្វើអោយសេរីភាពនៃការបញ្ចេញមតិនៅកម្ពុជាមានភាពប្រសើរជាងពេលបច្ចុប្បន្ន និងធានាអោយមានការប្រើប្រាស់នូវសេរីភាពរបស់ពលរដ្ឋគ្រប់រូបដោយពេញលេញ។

**ចំពោះរាជរដ្ឋាភិបាល ឬថ្នាក់ដឹកនាំគ្រប់ជាន់ថ្នាក់:**

- ត្រូវធានាអោយបាននូវការគ្រប់គ្រងសារពត៌មានដោយឯករាជ្យ ដែលមិនលម្អៀងទៅកាន់គណបក្សកាន់អំណាច នៅពេលដែលពាក់ព័ន្ធនឹងការផ្តល់អាជ្ញាបណ្ណ និងសេរីភាពក្នុងការធ្វើប្រតិបត្តិការ ដើម្បីនាំឱ្យ មានបរិស្ថានសារពត៌មានចម្រុះ និងដើម្បីលើកកម្ពស់វិជ្ជាជីវៈ និងភាពមិនលម្អៀងក្នុងចំណោមអ្នកសារពត៌មាន
- ធ្វើអោយមានការស៊ើបអង្កេត និងដាក់ទណ្ឌកម្មទៅលើអ្នក ដែលបានប្រព្រឹត្តការគំរាមកំហែង ការសម្លុត បំភ័យ និងអំពើហិង្សាមកលើអ្នកសារពត៌មាន។
- សម្រួលដល់ការប្រើប្រាស់អ៊ីនធឺណែត សម្រាប់ប្រជាជនកម្ពុជាទាំងអស់ និងបង្កើតគោលនយោបាយ ដើម្បីធានាថាហេដ្ឋារចនាសម្ព័ន្ធសម្រាប់ការចែកចាយធំនៃការប្រើប្រាស់អ៊ីនធឺណែតអាចត្រូវបានបង្កើតឡើង។
- រដ្ឋាភិបាល ត្រូវទទួលយកសេរីភាពពត៌មានលើបណ្តាញ ដោយការទាញយកប្រយោជន៍លទ្ធភាពបណ្តាញ ដែលមានដើម្បីបង្កើតម្លាភាព និងគណនេយ្យភាពនៃសកម្មភាពរដ្ឋាភិបាល និងការបោះពុម្ពផ្សាយជាផ្លូវការព័តមានលើបណ្តាញ។
- រដ្ឋាភិបាលត្រូវតែធានាថា ច្បាប់បាតុកម្ម មិនត្រូវបានប្រើប្រាស់ដោយរបៀបរើសអើង ដើម្បីរារាំងដល់ ក្រុមដែលមិនពេញចិត្តណាមួយពីការជួបប្រជុំដោយសន្តិវិធី ឬបញ្ចេញមតិយោបល់ដែលផ្ទុយទៅនឹង ទស្សនៈរបស់គណបក្សកាន់អំណាច។ ការជួបប្រជុំដោយសន្តិវិធីដើម្បីបញ្ចេញមតិមិនយល់ស្រប ជាមួយនឹងបុគ្គលនានាស្ថិតក្នុងអំណាច មិនគួរត្រូវបានមើលឃើញជាស្វ័យប្រវត្តិថាជាការគំរាមកំហែង ដល់សណ្តាប់ធ្នាប់សារធារណៈ ឬសន្តិសុខជាតិទេ។

**ចំពោះប្រព័ន្ធផ្សព្វផ្សាយនានា**

- ធានាថាច្បាប់ឧក្រិដ្ឋកម្មតាមប្រព័ន្ធបច្ចេកវិទ្យា ប្រសិនបើបានអនុម័តដំបូងត្រូវចំណាយពេលបញ្ចូលអង្គការសង្គមស៊ីវិលចូលទៅក្នុងគណនី និងទីពីរមិនមានបទប្បញ្ញត្តិណាមួយ

ឬពាក្យមិនច្បាស់លាស់ ដែលអាចត្រូវបានប្រើដើម្បីរារាំងសេរីភាពនៃការបញ្ចេញមតិនៅលើបណ្តាយសង្គម។

- ហាងលក់ប្រព័ន្ធផ្សព្វផ្សាយ គួរតែត្រូវបានអនុញ្ញាតិអោយផ្សព្វផ្សាយព័ត៌មានសេរី និងយុត្តិធម៌នៅក្នុងការរត់រហូតដល់ការបោះឆ្នោត និងមិនគួរត្រូវបានដាក់កម្រិតនៅក្នុងការធ្វើរបាយការណ៍ស្តីពីសកម្មភាព ឬគំនិតរបស់គណបក្សនយោបាយណាមួយ។
- ការគំរាមកំហែងឃាយី និងអំពើហិង្សាប្រឆាំង និងអ្នកសារព័តមានគួរតែត្រូវបានស៊ើបអង្កេត និងការផ្តន្ទាទោស។

**ចំពោះអង្គការសង្គមស៊ីវិល**

- ធ្វើអោយការប្តេជ្ញាចិត្តដ៏រឹងមាំក្នុងការស៊ើបអង្កេតយ៉ាងហ្មត់ចត់អំពើហិង្សា ឬការបំភិតបំភ័យបានធ្វើឡើងប្រឆាំងនឹងភ្នាក់ងារសង្គមស៊ីវិល និងដើម្បីនាំជនល្មើសទៅកាត់ទោស។
- ផ្តល់ការអប់រំដល់អាជ្ញាធរដើម្បីធានាថា ពួកគេបានដឹងអំពីបទប្បញ្ញត្តិនៃច្បាប់បាតុកម្ម និងថាពួកគេនឹងមិនបន្តស្នើសុំលិខិតអនុញ្ញាតពីអង្គការសង្គមស៊ីវិល ដែលមិនចាំបាច់នៅក្រោមច្បាប់។
- ចៀសវាងពីការដើម្បីបំបិទសំលេង សង្គមស៊ីវិលតាមរយៈប្រព័ន្ធតុលាការ។
- ត្រូវបង្កើតស្ថាប័នសិទ្ធិមនុស្សឯករាជ្យជាតិស្រប តាមគោលការណ៍ទីក្រុងប៉ារីស ដើម្បីការពារតួនាទីនៃសង្គមស៊ីវិលក្នុងប្រទេសកម្ពុជា និងដើម្បីផ្តល់នូវមធ្យោបាយនៃពាក្យបណ្តឹងមួយសម្រាប់ភ្នាក់ងារសង្គមស៊ីវិល ដែលមានសិទញធិរបស់ពួកគេ ដើម្បីសេរីភាពខាងការបញ្ចេញមតិ សមាគម និង ឬ ការជួបប្រជុំគ្នារំលោភ។

# ឯកសារយោង

## បទដ្ឋានគតិយុត្តជាតិ

- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា លេខ នស/រកម/០៧០៥/០០១ ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ១៩៩៣
- ច្បាប់ស្តីពីរបបសារពត៌មាន លេខ នស/រកម/០៨៩៥/០០៧ ចុះថ្ងៃទី០១ ខែកញ្ញា ឆ្នាំ១៩៩៥
- ច្បាប់ស្តីពីការធ្វើបាតុកម្មដោយសន្តិវិធី លេខ នស/រកម/១២០៩/០២៥
- ច្បាប់ព្រហ្មទណ្ឌអន្តរកាល ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ១៩៩២
- ច្បាប់ព្រហ្មទណ្ឌ និងនីតិវិធីព្រហ្មទណ្ឌសម្រាប់អនុវត្តនៅប្រទេសក្នុងសម័យអន្តរកាល ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ១៩៩២ របស់ក្រុមប្រឹក្សាជាតិជាន់ខ្ពស់នៃកម្ពុជា

## បទដ្ឋានគតិយុត្តអន្តរជាតិ

- កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ អនុម័តថ្ងៃទី១៦ ខែធ្នូ ឆ្នាំ១៩៦៦ ចូលជាធរមានថ្ងៃទី២៣ ខែមិនា ឆ្នាំ១៩៧៦ មាត្រា៩
- សេចក្តីថ្លែងការណ៍ជាសកលស្តីពីសិទ្ធិមនុស្ស ប្រកាសដោយមហាសន្និបាទនៃអង្គការសហប្រជាជាតិ នៅថ្ងៃទី១០ ខែធ្នូ ឆ្នាំ១៩៤៨
- កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ អនុម័តថ្ងៃទី១៦ ខែធ្នូ ឆ្នាំ១៩៦៦ ចូលជាធរមាននៅថ្ងៃទី០៣ ខែមករា ឆ្នាំ១៩៧៦

## ប្រភពបោះពុម្ព និងផ្សព្វផ្សាយឯកសារ

- មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជាស្តីពីសារពត៌មាន និងការលើកកម្ពស់សិទ្ធិមនុស្សនៅកម្ពុជា (ភ្នំពេញ ឆ្នាំ២០១២) http://www.cchrcambodia.org/admin/media/report/report/english/2012_07_24-New_Media_and_the_Promotion_of_Human_Right_in_Cambodia-ENG.pdf (ថតចម្លងថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១៦)

- មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជាស្តីពីបណ្តាញសារពត៌មានទំនើប និងការលើកកម្ពស់សិទ្ធិមនុស្សនៅកម្ពុជា (២០១២) ថតចម្លងថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១៦
- មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជាស្តីពីសេចក្តីព្រាងច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល (ពត៌មាន ២០១១) http://www.cchrcambodia.org/index_old.php?url=media/media.php&p=factsheet_detail.php&fsid=1&id=5 (ថតចម្លងថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៦)
- ក្រុមប្រឹក្សាសិទ្ធិមនុស្សអង្គការសហប្រជាជាតិស្តីពីការលើកកម្ពស់ ការការពារ និងការរីករាយក្នុងការទទួលបានសិទ្ធិមនុស្សលើប្រព័ន្ធអ៊ីនធឺណេត (កិច្ចប្រជុំទី២០ ខែមិថុនា ឆ្នាំ២០១២)

  http://www.regeringen.se/content/1/c6/19/64/51/6999c512.pdf (ថតចម្លងថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៦)
- អង្គការលើកកម្ពស់ពាណិជ្ជកម្ម និងការវិនិយោគ ស្តីពីការបង្កើតទូរស័ព្ទខ្សែ ទូរស័ព្ទដៃ និងអ៊ីនធឺណេត (ស្ថានទូតព្រះរាជាណាចក្រកម្ពុជាទីក្រុងឡុងដ៍ ២០១៣) http://cambodianembassy.org.uk/indes_main.php?lang=&kc=0&mct=0&menu=0&k=0&menu1=0&menu2=0&menu3=&link=0&link1=0&locate=&page=&topic=Telecoms&topic_cat=Business&readmore=3 (ថតចម្លងថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១៦)
- លីកាដូស្តីពីសេរីភាពខាងបញ្ចេញមតិនៅកម្ពុជា និយាយពីប្រជាធិបតេយ្យថ្មិនភ្នែក (លីកាដូ ២០១០) ថតចម្លងថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៦)
- មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជាស្តីពីការវិភាគផ្នែកច្បាប់នៃការចោទប្រកាន់ និងការផ្តន្ទាទោសមកលើសកម្មជនដីធ្លីអ្នកស្រី

## ឯកសារជាសៀវភៅសាស្រ្តាចារ្យ

- សាស្រ្តាចារ្យ ឈុន ណារ៉េត សៀវភៅប្រវត្តិគំនិតនយោបាយ និងទ្រឹស្តីរដ្ឋ ទំព័រ១១៧
- សាស្រ្តាចារ្យ ឈុន ណារ៉េត សៀវភៅប្រវត្តិគំនិតនយោបាយ និងទ្រឹស្តីរដ្ឋ ទំព័រ១៣០-១៣២
- សាស្រ្តាចារ្យ ឈុន ណារ៉េត សៀវភៅប្រវត្តិគំនិតនយោបាយ និងទ្រឹស្តីរដ្ឋ ទំព័រ១៤១-១៤៣

- សាស្ត្រាចារ្យ នួន សុធិមន្ត សៀវភៅវិទ្យាសាស្ត្រនយោបាយ ស្ដីពីគំនិតនយោបាយរបស់អ្នកប្រាជ្ញល្បីៗ (២០១០) ទំព័រ៥១-៥២
- សាស្ត្រាចារ្យ នួន សុធិមន្ត សៀវភៅវិទ្យាសាស្ត្រនយោបាយ ស្ដីពីគំនិតនយោបាយរបស់អ្នកប្រាជ្ញល្បីៗ (២០១០) ទំព័រ៦០


## ឯកសារដកស្រង់ពីអត្ថបទកាសែត ទស្សនាវដ្ដី និងសារពត៌មានផ្សេងៗ


- ស៊ុយហ៊ាមខេមរា, ទិន្នន័យតម្លៃថោកបច្ចេកវិទ្យាល្អជាងមុនធ្វើឲ្យប្រជាពលរដ្ឋកម្ពុជាជាច្រើនអាចប្រើប្រាស់អ៊ីនធឺណេត (វិទ្យុសំឡេងសហរដ្ឋអាមេរិកៈ២០១៣) http://www.voaccambodia.com/content/cheap-data-better-tech-putting-more-cambodians-online/1624617.html (ថតចម្លងថ្ងៃទី ០១ មេសា ២០១៤)
- សូស៊ិលម៉េកគ័រ, http://www.socialbakers.com/facebook-statistics/cambodia(ថតចម្លងថ្ងៃទី ១១ មេសា ២០១៤)
- អែន រ៉េប៊េនប្រ៊ីង ស្ដីពីជម្រើសការវិនិយោគសំរាប់ទូរគមនាគមន៍កម្ពុជា(សារពត៌មាន ឌី ភ្នំពេញ៖ ២០១៣) http://www.phnompenhpst.com/2013022061463/Business/investment-options-for-camboidan-telcos.html (ថតចម្លងថ្ងៃទី០៣ ឧសភា ២០១៦)
- អ៊ឹម សុធារិទ្ធិ បណ្ដាញសារពត៌មានសង្គមផ្លាស់ប្ដូរទិដ្ឋភាពឌីជីថលនៅកម្ពុជា(វិទ្យុសំឡេងសហរដ្ឋអាមេរិចៈ ២០១៣) http://voacambodia.com/content/cambodia-social-media-changing-cambodia-informatiom-landscape/1571656.html%6C (ថតចម្លងថ្ងៃទី១ មេសា ២០១៤)
- ចក់ សុភា រៀបរាប់ស្ដីពីលិទ្ធិប្រជាធិបតេយ្យឌីជីថលកើនឡើងនៅក្នុងប្រទេសកម្ពុជា (ភ្នំពេញ ២០១១) http://sopheapfocus.com/index.php/2009/11/dligital-democracy-emerging-in-cambodia/ (ថតចម្លងថ្ងៃទី២៩ ខែមេសា ២០១៦)
- http://www.blogger.com/tour_start.g (ចូលទស្សនាថ្ងៃទី ០១ មេសា ២០១៤)
- លីហ្សា គីម,អ្នកសរេរប្លុកពិភាក្សាពីសេរីភាពអ៊ីនធឺណេតនៅប្លុកហ្វេស អាស៊ីឆ្នាំ ២០១២ នៅកម្ពុជាកម្មវិធីប្លុក ហ្វេសអាស៊ីៈ ២០១២)

http://2012.blogfest.asia/ (ថតចម្លងថ្ងៃទី ០២ មេសា ២០១៤)

- ដានីញ៉េលដឺខាធឺរេត, អាជីកម្មនៅកម្ពុជាចាប់ផ្ដើមប្រើប្រាស់ការផ្សព្វផ្សាយនៅ លើហ្វេសប៊ុក(សារពត៌មានឌឹភ្នំពេញប៉ុស្ដិ៍ ២០១៣) http://www.phnompenhpost.com/2013021261301/Business/cambodia-business-embrace-facebook-advertising.html (ថតចម្លងថ្ងៃទី ២៣ មេសា ២០១៤)